សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES
THE ROYAL UNIVERSITY OF LAWS AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# របបនៃការគ្រប់គ្រងសំណល់រឹង

## ករណីសិក្សាប្រៀបធៀប៖ កម្ពុជា និង ជប៉ុន

ស្រាវជ្រាវពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២០ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ៖ លោក **ឡុង ចាន់**
ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២០**

សាស្ត្រាចារ្យណែនាំ
លោកស្រី ៖ **ប៉ូលី បញ្ញា**
ឆ្នាំចូលសិក្សា **២០១៦**
ឆ្នាំសរសេរសារណា **២០២០**

# លិខិតថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ឡុង ចាន់** និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២០នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមសម្តែងនូវគារវៈកិច្ច គោរពប្រណិបត្តិ ថ្លែងអំណរគុណ និងដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ៖ **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់កូន ចិញ្ចឹមបីបាច់ អប់រំ ទូន្មាន ប្រៀនប្រដៅកូន ផ្តល់ភាពកក់ក្តៅដល់កូន ទាំងកាយទាំងចិត្ត ជាពិសេសបានផ្តល់លទ្ធភាពឱ្យកូនអាចបានរៀនសូត្រតាំងពីបឋមសិក្សារហូតដល់សាកលវិទ្យាល័យដូចសព្វថ្ងៃនេះ ទោះត្រូវលះបង់និងហត់នឿយយ៉ាងណាក្តី ដើម្បីឱ្យកូនក្លាយជាមនុស្សល្អ ពលរដ្ឋល្អ និងអាចក្លាយជាបុគ្គលមានប្រយោជន៍ក្នុងសង្គមជាតិ។ មហាគុណរបស់លោកឪពុក អ្នកម្តាយពិតជាគ្មានអ្វីអាចកាត់ថ្លៃនិងប្រៀបផ្ទឹមបានឡើយហើយកូននឹងចងចាំនិងដឹងគុណជារហូតរៀងទៅ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រមទាំងលោក លោកស្រីដែលជាសាស្ត្រាចារ្យ បុគ្គលិក និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀន ណែនាំ និងជួយជ្រោមជ្រែង សម្រួលគ្រប់បែបយ៉ាងឱ្យមានភាពងាយស្រួលដើម្បីឱ្យខ្ញុំបាទបានសិក្សា និងបន្តការសិក្សាតាំងពីឆ្នាំមូលដ្ឋានរហូតដល់សរសេរសារណាបញ្ចប់ការសិក្សានេះ។

សាស្ត្រាចារ្យដឹកនាំសរសេរសារណាលោកស្រី **ប៉ូលី បញ្ញា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការ ផ្តល់ជាមាតិយោបល់ អនុសាសន៍ និងគំនិតល្អៗសម្រាប់ជាមូលដ្ឋានក្នុងការស្វែងរក ពិចារណា និងវិភាគ ដើម្បីដឹកនាំការសរសេរសារណារបស់ខ្ញុំបាទឱ្យប្រកបដោយភាពរលូន សម្រេចបានលទ្ធផលល្អ និងជោគជ័យ។

ខ្ញុំបាទសូមលើកហត្ថាបង្គំវន្ទាសូមទេវតា វត្ថុសាកស័ក្តិសិទ្ធិទាំងឡាយ ម្ចាស់ទឹកម្ចាស់ដីដែលថែរក្សានៅក្នុងចក្រវាលទាំងមូល សូមលោកជួយបីបាច់ថែរក្សាលោកឪពុកអ្នកម្តាយនិងអ្នកមានគុណទាំងឡាយដែលបានរៀបរាប់ខាងលើ សូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ សំណាងល្អនិងជោគជ័យគ្រប់ភារកិច្ចព្រមទាំងជួបនូវពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឃ្លៀនឡើយ។

## អារម្ភកថា

ដោយមើលឃើញពីការរអ៊ូរទាំ ជជែកវែកញែកពិភាក្សាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងក្នុងប្រទេសកម្ពុជា ជាពិសេសប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកបញ្ហាគ្រប់គ្រងសំណល់រឹងជាបញ្ហាប្រឈមចម្បងដើម្បីយកដោះស្រាយជាបន្ទាន់ផងដែរនោះ ទើបធ្វើឱ្យប្រធានបទមួយនេះមានការចាប់អារម្មណ៍សម្រាប់ខ្ញុំបាទក្នុងការសិក្សា និងស្រាវជ្រាវដើម្បីស្វែងយល់ពីកត្តាចម្បងដែលបង្កឱ្យបញ្ហាគ្រប់គ្រងសំណល់រឹងដែលជាបញ្ហាប្រឈមក្នុងសង្គមរាំរ៉ៃមកជាយូរហើយ នៅតែមិនទាន់មានដំណោះស្រាយណាមួយឱ្យមានប្រសិទ្ធភាពនៅឡើយនោះ ម៉្យាងវិញទៀតក្នុងនាមជាប្រជាពលរដ្ឋ ជាកោសិកាសង្គមមួយរូបក៏ចង់ចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាសង្គមដែលកំពុងកើតមានរាល់ថ្ងៃនេះ ជាពិសេសក៏ដើម្បីចង់បន្សល់ទុកជាឯកសារជាចំណេះដឹង ជាគំនិតខ្លះៗសម្រាប់ដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តៗអ្នកអានផងដែរ។

សារណានេះ ចង់លើកមកបង្ហាញពីទិដ្ឋភាពក្នុងការគ្រប់គ្រងសំណល់រឹងដែលកម្ពុជាបាននឹងកំពុងប្រើប្រាស់មកសព្វថ្ងៃ មិនតែប៉ុណ្ណោះដោយសារតែមើលឃើញពីបញ្ហាអវិជ្ជមានជាច្រើនកើតឡើងជុំវិញការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា និងចង់ចូលរួមស្វែងរកចំណុចល្អៗមួយចំនួនពីប្រទេសដទៃដើម្បីបង្កើតឱ្យមានដំណោះស្រាយ ក៏ដូចជា ឱកាសដល់ប្រទេសកម្ពុជាផងដែរនោះ ទើបខ្ញុំសម្រេចធ្វើការសិក្សាពីរបបក្នុងការគ្រប់គ្រងសំណល់រឹងនៅប្រទេសជប៉ុនបន្ថែមទៀត ក៏ព្រោះថាប្រទេសជប៉ុនជាប្រទេសដែលមានភាពល្អប្រសើរខ្លាំងពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង និងជាដៃគូរសហការមួយយ៉ាងជិតស្និតជាមួយកម្ពុជាផងដែរ។

ខ្ញុំបាទ ក៏សូមអភ័យទោសទុកជាមុននូវកំហុសខុសឆ្គងដោយអចេតនាណាមួយដែលបានកើតមានឡើងនៅក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្ររបស់ខ្ញុំបាទមួយនេះ ហើយខ្ញុំបាទក៏ត្រៀមខ្លួនជានិច្ចដើម្បីរង់ចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សិស្ស និស្សិត អ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់ និងសង្ឃឹមថាមិត្តៗអ្នកអានទាំងអស់នឹងចូលរួមផ្តល់ជាមតិ និងគំនិត ជាពិសេសអាចយកពុទ្ធិពីសារណាមួយនេះដើម្បីអាចចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងសង្គមដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ---------- ១

## ជំពូកទី១
## ស្ថានភាពទូទៅនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន

**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃសំណល់រឹងនៅប្រទេសកម្ពុជា** ---------- ៥

កថាខណ្ឌទី១ ៖ ការកំណត់និយមន័យនៃសំណល់រឹង ---------- ៥

កថាខណ្ឌទី២ ៖ ប្រភពនៃការបញ្ចេញសំណល់រឹង ---------- ៥

កថាខណ្ឌទី៣ ៖ ប្រភេទនៃសំណល់រឹង ---------- ៦

**ផ្នែកទី២ ៖ សញ្ញាណទូទៅនៃសំណល់រឹងនៅប្រទេសជប៉ុន** ---------- ៨

កថាខណ្ឌទី១ ៖ ការកំណត់និយមន័យនៃសំណល់រឹង ---------- ៨

កថាខណ្ឌទី២ ៖ ប្រភពនៃការបញ្ចេញសំណល់រឹង ---------- ៨

កថាខណ្ឌទី៣ ៖ ប្រភេទនៃសំណល់រឹង ---------- ៩

**ផ្នែកទី៣ ៖ ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា និង ជប៉ុន** ---------- ៩

កថាខណ្ឌទី១ ៖ កត្តាប្រជាជន និង សេដ្ឋកិច្ចចំពោះការគ្រប់គ្រងសំណល់រឹង ---------- ៩

កថាខណ្ឌទី២ ៖ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងសំណល់រឹង ---------- ១០

កថាខណ្ឌទី៣ ៖ បរិមាណនៃសំណល់រឹង ---------- ១២

## ជំពូកទី២
## របបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន

**ផ្នែកទី១ ៖ របបនៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា** ---------- ១៤

កថាខណ្ឌទី១ ៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយប្រជាពលរដ្ឋ ---------- ១៤

វាក្យខណ្ឌទី១ ៖ ការដុតបំផ្លាញសំណល់រឹង និងផលប៉ះពាល់ ---------- ១៤

វាក្យខណ្ឌទី២ ៖ ការបែងចែកសំណល់រឹងមិនត្រឹមត្រូវ និងផលប៉ះពាល់ ---------- ១៥

វាក្យខណ្ឌទី៣ ៖ ការវេចខ្ចប់ទុកដាក់សំណល់រឹងបណ្តោះអាសន្ន និងផលប៉ះពាល់ ---------- ១៥

វាក្យខណ្ឌទី៤ ៖ ការចោលសំណល់រឹងតាមទីសាធារណៈ និងផលប៉ះពាល់ ---------- ១៦

កថាខណ្ឌទី២ ៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយរដ្ឋាភិបាល/អាជ្ញាធរ ---------- ១៧

វាក្យខណ្ឌទី១ ៖ ការប្រមូល និងដឹកជញ្ជូនសំណល់រឹង (ក្រុមហ៊ុនឯកជន) ---------- ១៧

វាក្យខណ្ឌទី២ ៖ ទីលានចាក់សម្រាម ---------- ២០
វាក្យខណ្ឌទី៣ ៖ ការកែច្នៃ / ការធ្វើជីកំប៉ុស ---------- ២២
កថាខណ្ឌទី៣ ៖ ក្របខ័ណ្ឌគតិយុត្តនៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា ---------- ២៣
វាក្យខណ្ឌទី១ ៖ ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង ---------- ២៣
វាក្យខណ្ឌទី២ ៖ ការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ---------- ២៣
**ផ្នែកទី២ ៖ របបនៃការគ្រប់គ្រងសំណល់រឹងនៅជប៉ុន** ---------- ២៨
កថាខណ្ឌទី១ ៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយប្រជាពលរដ្ឋ ---------- ២៨
វាក្យខណ្ឌទី១ ៖ ការបែងចែកសំណល់រឹងនៅប្រភពដើម ---------- ២៨
វាក្យខណ្ឌទី២ ៖ ការរៀបចំ និងវេចខ្ចប់សំណល់រឹង ---------- ២៩
វាក្យខណ្ឌទី៣ ៖ ការបោះចោលសំណល់រឹង ---------- ៣០
កថាខណ្ឌទី២ ៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយរដ្ឋាភិបាល/អាជ្ញាធរ ---------- ៣១
វាក្យខណ្ឌទី១ ៖ ការប្រមូល និងដឹកជញ្ជូន (ស្ថានីយ៍ផ្ទេរសំណល់រឹង) ---------- ៣១
វាក្យខណ្ឌទី២ ៖ ទីលានចាក់សម្រាម ---------- ៣២
វាក្យខណ្ឌទី៣ ៖ រោងចក្រដុតសម្រាម ---------- ៣៣
វាក្យខណ្ឌទី៤ ៖ ការកែច្នៃឡើងវិញ ---------- ៣៤
កថាខណ្ឌទី៣ ៖ ក្របខ័ណ្ឌគតិយុត្តនៃការគ្រប់គ្រងសំណល់រឹងនៅជប៉ុន ---------- ៣៥
វាក្យខណ្ឌទី១ ៖ ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង ---------- ៣៦
វាក្យខណ្ឌទី២ ៖ តួនាទី និងទំនួលខុសត្រូវរបស់អង្គភាព និងអ្នកពាក់ព័ន្ធនានា ---------- ៣៧
**ផ្នែកទី៣ ៖ ប្រៀបធៀបរបបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និងជប៉ុន** ---------- ៤២

**ជំពូកទី៣**

**ឱកាស និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា**

**ផ្នែកទី១ ៖ ឱកាសក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា** ---------- ៤៥
កថាខណ្ឌទី១ ៖ ការញែក ឬបែងចែកសំណល់រឹងនៅប្រភពដើម ---------- ៤៥
កថាខណ្ឌទី២ ៖ ការអនុវត្តយុទ្ធសាស្ត្រ ៣R នៅក្នុងសហគមន៍ ---------- ៤៦
វាក្យខណ្ឌទី១ ៖ ការកាត់បន្ថយ ---------- ៤៦
វាក្យខណ្ឌទី២ ៖ ការប្រើប្រាស់ឡើងវិញ ---------- ៤៧
វាក្យខណ្ឌទី៣ ៖ ការកែច្នៃឡើងវិញ ---------- ៤៧

កថាខណ្ឌទី៣ ៖ ការបង្កើតស្ថានីយផ្ទេរសំណល់រឹងក្នុងក្រុង ---------------------------------------------- ៤៧
កថាខណ្ឌទី៤ ៖ ការសាងសង់ទីលានចាក់សម្រាមអនាម័យបន្ថែម---------------------------------------- ៤៨
កថាខណ្ឌទី៥ ៖ ការសិក្សាពីគម្រោងក្នុងការបង្កើតរោងចក្រដុតសម្រាម---------------------------------- ៥០
កថាខណ្ឌទី៦ ៖ ការពង្រឹងប្រព័ន្ធច្បាប់ និងគោលនយោបាយនានារបស់ស្ថាប័នពាក់ព័ន្ធ-------------- ៥១
**ផ្នែកទី២ ៖ បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា** ------------------------------ ៥២
កថាខណ្ឌទី១ ៖ កត្តាប្រជាជន ----------------------------------------------------------------------------- ៥២
កថាខណ្ឌទី២ ៖ កត្តាប្រមូល និងដឹកជញ្ជូនសំណល់រឹង------------------------------------------------ ៥៤
កថាខណ្ឌទី៣ ៖ ការគ្រប់គ្រងសំណល់រឹងតាមបែបមជ្ឈការ --------------------------------------------- ៥៤
កថាខណ្ឌទី៤ ៖ លិខិតបទដ្ឋានគតិយុត្តមិនគ្រប់គ្រាន់ និងការអនុវត្តនៅមានកម្រិតទាប--------------- ៥៥
**សេចក្តីសន្និដ្ឋាន**------------------------------------------------------------------------------------ ៥៧
**អនុសាសន៍** ------------------------------------------------------------------------------------------ ៥៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការគ្រប់គ្រងសំណល់រឹង គឺជាបញ្ហាសាកល និងជះឥទ្ធិពលដល់មនុស្សគ្រប់រូបនៅលើពិភពលោក។ នៅពេលដែលប្រទេសនានាដែលមានការអភិវឌ្ឍន៍ពីប្រាក់ចំណូលទាបរហូតដល់ប្រាក់ចំណូលមធ្យម និងខ្ពស់ នោះកំណើននៃសេដ្ឋកិច្ច នគរូបនីយកម្ម ប្រជាជន ភាពសម្បូររបស់មនុស្សម្នាក់ៗនឹងធ្វើឱ្យបរិមាណនៃសំណល់រឹងមានការកើនឡើងផងដែរ ហើយពេលនោះបញ្ហានៃការគ្រប់គ្រងសំណល់រឹងក៏កាន់តែមានភាពលំបាក់។ ប្រទេសនីមួយៗមានស្ថានភាពខុសៗគ្នាទាំងភូមិសាស្ត្រ វប្បធម៌ ទំនៀមទម្លាប់ ផ្នត់គំនិត និងជីវិតរស់នៅ ដែលហេតុទាំងនេះហើយជាផ្នែកមួយក្នុងការធ្វើឱ្យវិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលនៃប្រទេសនីមួយៗក៏ខុសគ្នាផងដែរ។

យ៉ាងណាមិញ ព្រះរាជាណាចក្រកម្ពុជាក្រោយពីឆ្លងកាត់នូវរបបប្រល័យពូជសាសន៍ឆ្នាំ១៩៧៥-១៩៧៩មក ប្រមុខរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីរៀបចំ និងស្តារប្រទេសឡើងវិញរហូតបាននាំប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសកំពុងអភិវឌ្ឍន៍យ៉ាងសកម្ម និងមានឈ្មោះបោះសម្លេងលើឆាកអន្តរជាតិដូចសព្វថ្ងៃនេះក្នុងរយៈពេលដ៏ខ្លីមួយ។ ទន្ទឹមនឹងការរីកចម្រើនគ្រប់វិស័យយ៉ាងឆាប់រហ័ស ទាំងវិស័យសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ នគរូបនីយកម្ម ព្រមទាំងមានការកើនឡើងនៃចំនួនប្រជាជនជាបន្តបន្ទាប់ ដែលកត្តាទាំងនេះហើយបានជំរុញឱ្យកម្ពុជាប្រឈមមុខនឹងបញ្ហាចម្បងបំផុតមួយក្នុងចំណោមបញ្ហាប្រឈមផ្សេងៗទៀតគឺ **ការគ្រប់គ្រងសំណល់រឹង**។

ជាក់ស្តែង ចំពោះការគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជាហាក់បីដូចជាផ្តោតទៅលើការប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈប្រពៃណីដូចជា៖ ការចោលសំណល់រឹងនៅទីលានចាក់សម្រាម ការដុតសំណល់រឹង ការធ្វើជីកំប៉ុស លើសពីនេះទៅទៀតចំពោះវិធីសាស្ត្រឡដុតសម្រាម គឺមិនទាន់មានការប្រើប្រាស់ឱ្យទូលំទូលាយនោះទេ ភាគច្រើនមានតែប្រើនៅក្នុងមន្ទីរពេទ្យ។ បើយើងប្រៀបធៀបជាមួយប្រទេសដែលមានការគ្រប់គ្រងសំណល់រឹងល្អប្រសើរដូចជាករណីប្រទេសជប៉ុន យើងឃើញថាប្រទេសជប៉ុនក៏ធ្លាប់ជួបប្រទះបញ្ហាគ្រប់គ្រងសំណល់រឹងស្រដៀងនឹងបញ្ហាដែលកំពុងប្រឈមនៅបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍សព្វថ្ងៃ ក៏ដូចជាកម្ពុជាផងដែរ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះប្រទេសជប៉ុនមានប្រព័ន្ធរឹងមាំសម្រាប់ការគ្រប់គ្រងសំណល់រឹង និងកែច្នៃឡើងវិញរួចទៅហើយ។

បញ្ហាប្រឈមដែលពាក់ព័ន្ធចំពោះការគ្រប់គ្រងសំណល់រឹងនៅក្នុងប្រទេសកម្ពុជា គឺមិនមែនជាប្រធានបទអ្វីថ្មីនោះទេ ក៏ប៉ុន្តែដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហាដែលកើតមានឡើងនៅដដែលៗនិងជារៀងរាល់ថ្ងៃនេះហាក់ដូចជាគ្មានប្រសិទ្ធភាពនៅឡើយ។ ក្រៅពីកត្តាអនុវត្តច្បាប់ដែលនៅមានភាពធូររលុង និងយន្តការគ្រប់គ្រងសំណល់រឹងនៅមានភាពខ្វះខាតហើយនោះ ការមិនផ្លាស់ប្តូរទម្លាប់ចាស់របស់ប្រជាជនកម្ពុជា កង្វះការយល់ដឹង

និងកង្វះការផ្សព្វផ្សាយក៏ជាបញ្ហាចម្បងដែលបង្កឱ្យមានបញ្ហាគ្រប់គ្រងសំណល់រឹងនៅកម្ពុជាផងដែរ។ បើងាកទៅប្រទេសជប៉ុនវិញដែលជាប្រទេសមានកំណើនសេដ្ឋកិច្ចជឿនលឿនខ្លាំងនិងជាប្រទេសមានការផលិត ការនាំចូល និងនាំចេញដ៏មមាញឹកមួយ ជាពិសេសជាប្រទេសមានប្រជាជនច្រើនប៉ុន្តែមានផ្ទៃដីតិចតួចសម្រាប់ការគ្រប់គ្រងសំណល់រឹង តែបែរជាប្រទេសនេះក្លាយជាប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងសំណល់រឹងល្អក្នុងពិភពលោកទៅវិញ។ ដូច្នេះហើយចំពោះចំណោទបញ្ហាជុំវិញប្រធានបទនេះគឺថា តើរបបនៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា និង ជប៉ុនមានលក្ខណៈដូចម្តេចខ្លះ? តើមានកត្តាប្រឈមអ្វីខ្លះចំពោះការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា? ហើយទន្ទឹមនឹងការសិក្សាស្វែងយល់ពីរបបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និងជប៉ុន តើយើងអាចមានលទ្ធភាពក្នុងការបង្កើតឱកាសអ្វីខ្លះក្នុងការអភិវឌ្ឍន៍ការគ្រប់គ្រងសំណល់រឹងនៅកម្ពុជាឱ្យកាន់តែប្រសើរជាងនេះ?

## គ. គោលបំណងក្នុងការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវជុំវិញប្រធានបទ**«របបនៃការគ្រប់គ្រងសំណល់រឹង»(ករណីសិក្សារវាងកម្ពុជា និង ជប៉ុន)** នេះ ដោយសារខ្ញុំយល់ឃើញថា នេះគឺជាប្រធានបទមួយថ្មីហើយពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមក្នុងសង្គមយើងសព្វថ្ងៃ ហេតុដូចនេះហើយខ្ញុំបាទមានគោលបំណងចង់ស្វែងយល់បន្ថែមពីបញ្ហាដែលកំពុងកើតមាននេះ ជាពិសេសចង់ បង្ហាញឱ្យមិត្តៗអ្នកអានទាំងឡាយបានឃើញនូវទិដ្ឋភាពនៃវិធីសាស្ត្រក្នុងការគ្រប់គ្រងសំណល់រឹង ទាំងការគ្រប់គ្រងសំណល់រឹងរបស់ប្រជាពលរដ្ឋ របស់រដ្ឋាភិបាល/អាជ្ញាធរ និងក្របខណ្ឌគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងដែលមាននៅក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន។ ម្យ៉ាងវិញទៀត ក៏ចង់សិក្សាស្វែងយល់អំពីទិដ្ឋភាពរវាងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា និងជប៉ុន ព្រមទាំងបញ្ហាប្រឈមនានានៅកម្ពុជាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងដើម្បីមានជាពុទ្ធិក្នុងការស្វែងរកនូវឱកាសនានាក្នុងការស្តារ ក៏ដូចជាបង្កើតគំនិត ឬសកម្មភាពផ្សេងៗក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹងល្អមួយនៅក្នុងសង្គមកម្ពុជាយើងនេះផងដែរ។

## ខ. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ឆ្លុះបញ្ចាំងជុំវិញប្រធានបទនេះ ចំពោះទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺខ្ញុំបាទបានធ្វើការសិក្សាចាប់ពីថ្ងៃ០៨ ខែកុម្ភៈ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយផ្តោតសំខាន់ទៅលើទិដ្ឋភាពទូទៅនៃវិធីសាស្ត្រក្នុងការគ្រប់គ្រងសំណល់រឹងដែលបានកំពុងប្រើប្រាស់ក្នុងប្រទេសកម្ពុជានិងជប៉ុន និងបញ្ហាប្រឈមមួយចំនួនដែលបានកើតមានក្នុងប្រទេសកម្ពុជា ព្រមទាំងទំនួលខុសរបស់អង្គភាព ឬអ្នកពាក់ព័ន្ធដល់ការគ្រប់គ្រងសំណល់រឹងដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តនៃប្រទេសកម្ពុជា និងជប៉ុនប៉ុណ្ណោះ ដោយពុំបានផ្តោតសំខាន់លើការសិក្សាឱ្យបានស៊ីជម្រៅខ្លាំងដល់បច្ចេកទេសនៃការគ្រប់គ្រងសំណល់រឹង ក៏ដូចជាដំណើរការ

ឬប្រតិបត្តិការផ្សេងៗនោះទេ។ ឧទាហរណ៍ដូចជា៖ បច្ចេកទេស ឬគោលការណ៍នៃការសាងសង់ទីលានចាក់សម្រាម , បច្ចេកទេសនៃការទាញយកផលប្រយោជន៍ពីរោងចក្រឡដុតសម្រាម។ល។

### គ. សារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ខ្ញុំអាចចាត់ថាបានជាប្រយោជន៍សម្រាប់ទុកជាឯក-សារដល់សិស្ស និស្សិត និងមិត្តៗអ្នកអានទាំងឡាយដែលមានគោលបំណងចង់ស្វែងយល់ ឬសិក្សាស្រាវជ្រាវបន្តដែលពាក់ព័ន្ធដល់របបនៃការគ្រប់គ្រងសំណល់រឹង ជាពិសេសផងដែរនោះគឺមានសារៈសំខាន់ណាស់ក្នុងការចូលរួមជួយ និងអភិវឌ្ឍសង្គមដែលកំពុងជួបនូវបញ្ហាក្នុងការគ្រប់គ្រងសំណល់រឹងនេះ។ ដោយសារតែខ្លឹមសារនៅក្នុងអត្ថបទនេះ បានរំលេចឡើងនូវចំណេះដឹងនៃបញ្ហាគ្រប់គ្រង់សំណល់រឹង និងបានបង្ហាញអំពីស្ថានភាព ក៏ដូចជាផលវិបាក់នៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជាយើងសព្វថ្ងៃ មិនតែប៉ុណ្ណោះអត្ថបទនេះបានធ្វើការសិក្សាដល់ការគ្រប់គ្រងសំណល់រឹងនៅប្រទេសជប៉ុន ដែលជាប្រទេសមានការគ្រប់គ្រងសំណល់រឹងរឹងមាំ និងល្អប្រសើរក្នុងពិភពលោក។ ដូច្នេះហើយអាចចាត់ទុកថាជាចំណេះដឹងថ្មីមួយបន្ថែមទៀតសម្រាប់យកមកពិចារណា និង ស្វែងយល់បន្ថែមព្រមទាំងអាចបង្កើតជាឱកាសសម្រាប់ការគ្រប់គ្រងសំណល់រឹងក្នុងសង្គមកម្ពុជាយើងឱ្យកាន់តែល្អប្រសើរ។

### ឃ. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដោយហេតុថាប្រធានបទខាងលើនេះ ជាប្រធានបទមួយថ្មីព្រមទាំងបានធ្វើការសិក្សាលើពីរប្រទេសផ្សេងគ្នា ហើយម៉្យាងទៀត បើទោះបីជាបញ្ហាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងវាជាបញ្ហាដ៏រ៉ាំរ៉ៃមួយនៅក្នុងប្រទេសកម្ពុជាពិតមែន ក៏ប៉ុន្តែមិនមានឯកសាគ្រប់គ្រាន់ ឬឯកសារគោលណាមួយដែលសរសេរបង្ហាញអំពីរបបនៃការគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជាឱ្យបានទូលំទូលាយឡើយ។ ទន្ទឹមនឹងនេះ ខ្ញុំបាទត្រូវសិក្សាលើករណីប្រទេសជប៉ុនជាភាសាបរទេសផងដែរនោះ ហេតុដូច្នេះហើយវាមានផលលំបាក់ខ្លាំងគួរសម ព្រមទាំងចំណាយពេលវេលាក្នុងការអាន ការពិចារណា និងវិភាគច្រើន។ទោះជាយ៉ាងណាក៏ដោយ ចំពោះអត្ថបទមួយនេះខ្ញុំបានខិតខំសិក្សាស្រាវជ្រាវដោយពិនិត្យលើលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជាជាមូលដ្ឋាន និងធ្វើការស្វែងយល់ព្រមទាំងវិភាគលើទ្រឹស្តីចំពោះឯកសានានាដែលមានក្នុងបណ្ណាល័យ ឬបណ្ណាគារ និងមានការចែករំលែកបទពិសោធន៍មួយចំនួនពីសំណាក់សាស្ត្រាចារ្យផងដែរ។ ក្រៅពីនេះ គឺខ្ញុំក៏បានសិក្សាស្រាវជ្រាវតាមរយៈប្រព័ន្ធអ៊ីន-ធឺណែត ប្រព័ន្ធវេបសាយនានា ក៏ដូចជាវេបសាយរបស់ក្រសួងពាក់ព័ន្ធក្នុងប្រទេសកម្ពុជា បណ្តាញសង្គម និងប្រព័ន្ធព័ត៌មាននានាជាដើម។

## ខ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនីតិសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលមានប្រធានបទ**«របបនៃការគ្រប់គ្រងសំណល់រឹង»(ករណីសិក្សារវាង៖ កម្ពុជា និង ជប៉ុន)** របស់ខ្ញុំបាទនេះ ខ្ញុំបានធ្វើការបែងចែករចនាសម្ព័ន្ធជា ៣ជំពូក ដូចខាងក្រោម៖

- **ជំពូកទី១. ស្ថានភាពទូទៅនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និងជប៉ុន៖** ក្នុងជំពូកទី១នេះ ខ្ញុំបានលើកឡើងពីសញ្ញាណទូទៅនៃសំណល់រឹងរវាងប្រទេសទាំងពីរ មិនតែប៉ុណ្ណោះមានការបរិយាយសង្ខេបផងដែរនូវទិដ្ឋភាពទូទៅក្នុងការគ្រប់គ្រងសំណល់រឹង ក៏ដូចជាហេតុផលចម្បងដែលនាំឱ្យមានការកើនឡើងនៃបរិមាណសំណល់រឹង ព្រមទាំងបង្ហាញពីទិន្នន័យនៃបរិមាណសំណល់រឹងដែលប្រទេសទាំងពីរបានបង្កើតកន្លងមកផងដែរ។

- **ជំពូកទី២. របបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និងជប៉ុន៖** ដោយឡែកជំពូកទី២នេះ ជាជំពូកស្នូលនៃអត្ថបទទាំងមូលដែលខ្ញុំនឹងលើកពី របបនៃការគ្រប់គ្រងសំណល់រឹងរវាងប្រទេសទាំងពីរយកមកសិក្សា ដែលក្នុងនោះរួមមាន៖ វិធីសាស្រ្តគ្រប់គ្រងសំណល់រឹងដោយប្រជាពលរដ្ឋ,ដោយរដ្ឋាភិបាល/អាជ្ញាធរ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងរវាងប្រទេសទាំងពីរ។

- **ជំពូកទី៣. ឱកាស និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា៖** រីឯជំពូកទី៣នេះជាជំពូកបញ្ចប់ ដែលខ្ញុំនឹងធ្វើការសិក្សាក្នុងការរកនូវឱកាសនានាដែលអាចឱ្យប្រទេសកម្ពុជាធ្វើការសិក្សាបន្ថែមដើម្បីដាក់ឱ្យមានការអនុវត្ត ឬបង្កើតជាគម្រោង និងគោលនយោបាយផ្សេងៗសម្រាប់ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹងនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ មិនប៉ុន្តែប៉ុណ្ណោះខ្ញុំក៏បានរំលេចឡើងនូវបញ្ហាប្រឈមនានាក្នុងការរារាំងដល់ការគ្រប់គ្រងសំណល់រឹងដែលបាននឹងកំពុងកើតមាននៅទូទាំងប្រទេសកម្ពុជាផងដែរ។

# ជំពូកទី១

# ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន

## ផ្នែកទី១៖ សញ្ញាណទូទៅនៃសំណល់រឹងក្នុងប្រទេសកម្ពុជា

### កថាខណ្ឌទី១៖ ការកំណត់និយមន័យនៃសំណល់រឹង

ការឱ្យនិយមន័យនៃពាក្យសំណល់រឹង និងការចែកចំណាត់ថ្នាក់សំណល់រឹងគឺធ្វើឡើងទៅតាមការកំណត់របស់ប្រទេសនីមួយៗ។ ដោយឡែកនៅប្រទេសកម្ពុជាក៏មានការកំណត់និយមន័យលើពាក្យសំណល់រឹងនេះផងដែរ។

**សំណល់រឹង** (Solid Waste) គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង សម្ភារៈ ឬកំទេចកំទីដែលគេលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះចោល មានបំណងនឹងបោះចោល ឬតម្រូវឱ្យបោះបង់ចោល[1]។ ជាទូទៅពាក្យថា **សំណល់រឹង** មិនសូវពេញនិយមក្នុងការប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជាក្នុងជីវភាពប្រចាំថ្ងៃនោះ ទ្បើយ។ភាគច្រើនត្រូវបានគេប្រើប្រាស់ជំនួសវិញដោយពាក្យថា **សម្រាម** សម្រាប់សំដៅទៅដល់ន័យពាក្យថាសំណល់រឹងនេះ។ ប៉ុន្តែពាក្យថាសម្រាមមិនមែនមានន័យដូចសំណល់រឹងឡើយ។ **សម្រាម** គឺជាផ្នែកមួយនៃសំណល់រឹងដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបានបញ្ចេញពីលំនៅឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល[2]។

### កថាខណ្ឌទី២៖ ប្រភពនៃការបញ្ចេញសំណល់រឹង

បរិមាណសំណល់រឹងដែលបានបង្កើតរាល់ថ្ងៃ គឺមានប្រភពចេញពីកន្លែងផ្សេងៗគ្នា។ ការសិក្សាពីប្រភពសំណល់រឹងនេះគឺមានប្រយោជន៍ណាស់ក្នុងការវិភាគ វាយតម្លៃ និងបែងចែកនូវប្រភេទសំណល់រឹងដើម្បីឈានទៅដល់ការគ្រប់គ្រងរបស់វា។ យោងតាមការសិក្សាស្រាវជ្រាវប្រភពដែលបង្កើតសំណល់រឹងនៅកម្ពុជា គឺមានប្រភពមកពីកន្លែងផ្សេងៗគ្នាដូចជា៖

- សំណល់រឹងតាមផ្ទះ
- សំណល់រឹងនៅតាមផ្សារ
- សំណល់រឹងតាមភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ កន្លែងលំហែកាយ និងកន្លែងគោរពបូជា
- សំណល់រឹងតាមរយៈសេវាសុខភាពដូចជា តាមមន្ទីរពេទ្យ ពហុព្យាបាល មណ្ឌលសុខភាព
- សំណល់រឹងនៅតាមអាគាររដ្ឋបាល និងសាលារៀន

[1] មាត្រា៣ (ក) នៃអនុក្រឹត្យលេខ៣៦ អនុក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង។

[2] មាត្រា៣ (ខ) នៃអនុក្រឹត្យលេខ៣៦ អនុក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង។

- សំណល់រឹងនៅកន្លែងសេវាកម្មលាង ឬជួសជុលរថយន្ត និងជួសជុលគ្រឿងអេឡិចត្រូនិច
- សំណល់រឹងដែលកើតចេញពីកន្លែងសត្តឃាដ
- សំណល់រឹងដែលកើតចេញពីសកម្មភាពកសិកម្ម
- សំណល់រឹងឧស្សាហកម្ម និងរ៉ែ
- សំណល់រឹងសំណង់
- សំណល់រឹងចេញពីមន្ទីរពិសោធន៍
- សំណល់រឹងនៅតាមថ្នល់ និងសួនច្បារ ។ល។

ចំពោះប្រភេទផ្សេងៗនៃសំណល់រឹង ដែលកើតចេញពីប្រភពខាងលើនេះមានចែងនៅក្នុងឧបសម្ព័ន្ធទី៣នៃអត្ថបទនេះ។

**កថាខណ្ឌទី៣៖ ប្រភេទនៃសំណល់រឹង**

នៅកម្ពុជា សំណល់រឹងត្រូវបានចាត់ចំណាត់ថ្នាក់ជា ២ក្រុមធំៗគឺ៖ សំណល់រឹងប្រកបដោយគ្រោះថ្នាក់ និង សំណល់រឹងមិនបង្កគ្រោះថ្នាក់។

- សំណល់រឹងប្រកបដោយគ្រោះថ្នាក់(Hazadious Solid Waste)៖ គឺសំដៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជម្ងឺមហារីក ចម្លងជម្ងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីផ្សេងទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន[3]។
- សំណល់រឹងមិនបង្កគ្រោះថ្នាក់(Non-hazardous Solid Waste)៖ ជាសំណល់រឹងដែលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វនិងរុក្ខជាតិ ដូចជាសំណល់រឹងទូទៅតាមផ្ទះ,ទីផ្សារ ទីសាធារណៈ ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ សួនច្បារ អាគារពាណិជ្ជកម្ម[4]។ល។

ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា ការិយាល័យគ្រប់គ្រងសំណល់រឹងនិងសារធាតុប្រកបដោយគ្រោះថ្នាក់បានធ្វើការបែងចែកប្រភេទសំណល់រឹងជា ៥ប្រភេទបន្ថែមទៀតដូចខាងក្រោម ៖

**១.សំណល់រឹងលំនៅដ្ឋាន៖** ភាគច្រើនជាប្រភេទសំណល់រឹងចេញពីផ្ទះបាយដែលជាប្រភេទសរីរាង្គងាយពុករលួយ អាចយកទៅធ្វើជាជីកំប៉ុសបានដូចជាបន្លែ សំណល់ផ្លែឈើ សំណល់ម្ហូបអាហារ ប្លាស្ទិក ក្រដាស ដែក ក្រណាត់ និងសម្ភារៈវេចខ្ចប់។ល។ សំណល់រឹង លំនៅដ្ឋានក៏មានប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

[3] សមាសធាតុសំណល់រឹងប្រកបដោយគ្រោះថ្នាក់មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៣៦ អនុក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង។

[4] សមាសធាតុសំណល់រឹងមិនបង្កគ្រោះថ្នាក់មានចែងនៅក្នុងឧបសម្ព័ន្ធទី៣ នៃអត្ថបទនេះ។

ផងដែរដូចជាសំណល់រឹងថ្មពិល អាគុយ អំពូលភ្លើង ទូរទស្សន៍ ម៉ាស៊ីនត្រជាក់ដែលខូចលែងប្រើប្រាស់កើត ។ល។

**២.សំណល់រឹងពាណិជ្ជកម្ម៖** ជាប្រភេទសំណល់រឹងចេញពីទីផ្សារ ហាងទំនិញ សណ្ឋាគារ រង្គសាល ភោជនីយដ្ឋាន។ល។ ភាគច្រើននៃប្រភេទសំណល់រឹងនេះជាប្រភេទដែលពុំមានគ្រោះថ្នាក់ ដូចជាប្រភេទសំណល់លំនៅដ្ឋានដែរ។ ចំពោះប្រភេទដែលគ្រោះថ្នាក់មាន ដូចជាសម្ភារៈដែលសេសសល់ពីការវេចខ្ចប់ ថ្នាំសម្លាប់សត្វល្អិត សំណល់សម្ភារៈជជុះដូចជាថ្មពិល ទូរទស្សន៍ ម៉ាញ៉េ វិទ្យុ និងគ្រឿង បន្លាស់អេឡិចត្រូនិក ម៉ាស៊ីនត្រជាក់ ទូទឹកកក និងសំណល់រឹងកង់ឡានចាស់ៗ។ល។

**៣.សំណល់រឹងមន្ទីរពេទ្យ៖** ជាប្រភេទសំណល់រឹងប្រកបដោយគ្រោះថ្នាក់។ សំណល់រឹងមន្ទីរពេទ្យចែកចេញជាប្រភេទដូចខាងក្រោម ៖

- សំណល់រឹងដែលបង្កឱ្យមានការឆ្លង៖ ជាប្រភេទដែលមានភ្នាក់ងារចម្លងជម្ងឺដូចជា សំណល់សម្ភារៈចេញពីមន្ទីរពិសោធន៍ បណ្តុះមេរោគ សំណល់ជាលិកាតាមផ្នែកផ្សេងៗ សម្ភារៈ ឬឧបករណ៍ធ្លាប់បានប៉ះពាល់ផ្ទាល់ជាមួយនឹងសំណល់របស់អ្នកជម្ងឺមាន មេរោគឆ្លង។
- សំណល់រឹងរោគសាស្ត្រ៖ ជាលិកាមនុស្ស ឬវត្ថុរាវ។ ឧទាហរណ៍៖ បំណែកសរពាង្គកាយ ឈាម និងទឹករំអិលផ្សេងៗទៀត(ទឹកភ្លោះ)។
- សំណល់រឹងដែលបង្កឱ្យមានការមុត(របួសស្នាម)៖ ម្ជុល ប្រដាប់សម្រាប់ផុងទឹក កាំបិតវះកាត់ ឡាម ផ្លែកាំបិត អំបែង ដប។
- សំណល់រឹងឱសថ៖ សំណល់រឹងដែលមានឱសថ។ ឧទាហរណ៍៖ ឱសថហួសកាលបរិច្ឆេទ ឬឈប់ប្រើប្រាស់ វត្ថុសម្រាប់ដាក់ឱសថ ដូចជាដប ប្រអប់របស់វាជាដើម។
- សំណល់រឹងពុលសែន៖ សំណល់រឹងដែលមានសារធាតុបំពុលសែន។ ឧទាហរណ៍៖ សំណល់រឹងជាតិថ្នាំពុលកោសិកា(ដែលប្រើប្រាស់ក្នុងការព្យាបាលជម្ងឺមហារីក) សារធាតុគីមីបំពុលសែន និងសារធាតុវិទ្យុសកម្ម។
- សំណល់រឹងសារធាតុគីមី៖ សំណល់រឹងដែលមានសារធាតុគីមី។ ឧទាហរណ៍៖ ប្រតិករប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ សារធាតុគីមី លាងហ្វីល សារធាតុដែលប្រើសម្រាប់សម្លាប់មេរោគដែលហួសកាលបរិច្ឆេទ ឬឈប់ប្រើ និងសារធាតុរំលាយ។
- សំណល់រឹងលោហៈ៖ ថ្មពិល អាគុយ ឧបករណ៍វាស់កម្តៅដែលបាក់បែក ឬប្រដាប់វាស់សម្ពាធឈាម។
- សំណល់រឹងធុងឧស្ម័ន៖ ធុងឧស្ម័ន និងកំប៉ុងថ្នាំបាញ់អាអេរ៉ូសុល។

- សំណល់រឹងវិទ្យុសកម្មៈ សំណល់រឹងដែលមានសារធាតុវិទ្យុសកម្ម ដូចជាសារធាតុរាវចេញពីការព្យាបាលដោយប្រើកាំរស្មី ឬ ការស្រាវជ្រាវក្នុងមន្ទីរពិសោធន៍ ប្រដាប់ការពារកាំរស្មី ទឹកនោម ឬឈាមក្នុងជម្ងឺព្យាបាលដោយកាំរស្មី។

**៤.សំណល់រឹងកសិកម្មៈ** ដែលសេសសល់ពីការប្រើប្រាស់នៃថ្នាំសម្លាប់សត្វល្អិត និងសម្ភារៈវេចខ្ចប់ថ្នាំពុល។ សំណល់រឹងចេញពីផ្នែកនេះជា ប្រភេទសំណល់រឹងដែលប្រកបដោយគ្រោះថ្នាក់បំផុត។

**៥.សំណល់រឹងឧស្សាហកម្មៈ** សំណល់រឹងផ្នែកនេះភាគច្រើនជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់។

## ផ្នែកទី២៖ សញ្ញាណទូទៅនៃសំណល់រឹងក្នុងប្រទេសជប៉ុន

### កថាខណ្ឌទី១៖ ការកំណត់និយមន័យនៃសំណល់រឹង

នៅប្រទេសជប៉ុន សំណល់រឹងជាទូទៅត្រូវបានគេសំដៅទៅដល់សម្ភារៈទាំងឡាយដែលត្រូវបានគេបោះចោលដោយមិនត្រូវបានលក់ទៅឱ្យបុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយ ហើយវាបង្កើតឱ្យមានថ្លៃសេវាក្នុងការប្រមូល ដឹកជញ្ជូន និងបោះចោល។តែទោះជាយ៉ាងណាក៏ដោយ យោងតាមន័យដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹង និងការសម្អាតសាធារណៈ (WASTE MANAGEMENT AND PUBLIC CLEANSING LAW) បានកំណត់និយមន័យនៃសំណល់រឹងដូចខាងក្រោម៖

**សំណល់រឹង** សំដៅទៅលើសម្ភារៈដែលគេបោះចោល(ទាំងសម្ភារៈដែលមានទំហំតូចនិងធំ) ផេះ ភក់ សំណល់ប្រេង សំណល់អាស៊ីត និងអាកាលី សំណល់សាកសពសត្វ ឬឆ្អឹងសត្វ និងសំណល់កខ្វក់និងមិនចាំបាច់ផ្សេងៗទៀតដែលមានសភាពរឹង ឬរាវ(មិនរាប់បញ្ចូលសំណល់ដែលមានជាតិពុលវិទ្យុសកម្ម)[5]។

### កថាខណ្ឌទី២៖ ប្រភពនៃការបញ្ចេញសំណល់រឹង

ប្រភពនៃការបញ្ចេញសំណល់រឹងនៅប្រទេសជប៉ុនរួមមាន ៖

- លំនៅឋាន(រួមមាន លំឋានទោល និងបណ្តុំនៃលំនៅឋាន...)។
- ឧស្សាហកម្ម(រួមមាន រោងចក្រផលិតកម្មធុនស្រាល និងធ្ងន់, ការដ្ឋានសំណង់, រោងចក្រថាមពល និងគីមី...)។
- ពាណិជ្ជកម្ម(រួមមាន ហាងទំនិញ,ផ្សារ,ភោជនីយដ្ឋាន,សណ្ឋាគារ,អាគារការិយាល័យ...)។
- ស្ថាប័ន(រួមមាន សាសារៀន,មន្ទីពេទ្យ,មជ្ឈមណ្ឌលរដ្ឋាភិបាល,ពន្ធធនាគារ...)។
- ទីតាំងសាងសង់ និងកម្ទេចចោល(រួមមាន ទីតាំងសាងសង់ថ្មី, ការជួសជុលផ្លូវ, ទីតាំងកែលម្អឡើងវិញ, ទីតាំងរុះរើអាគារ...)។

[5] "waste" refers to refuse, bulky refuse, ashes, sludge, excreta, waste oil, waste acid and alkali, carcasses and other filthy and unnecessary matter, which are in solid or liquid state (excluding radioactive waste and waste polluted by radioactivity).

- សេវាកម្មក្រុង(រួមមាន ការសម្អាតដងផ្លូវ, សួនច្បារ, ឧទ្យាន, ឆ្នេរ, តំបន់កំសាន្តផ្សេងៗ, រោងចក្រប្រព្រឹត្តកម្មទឹក និងទឹកស្អុយ...)។
- កសិកម្ម(រួមមាន ដំណាំ, ចម្ការ, កសិដ្ឋានចិញ្ចឹមសត្វ...)។

**កថាខណ្ឌទី៣៖ ប្រភេទនៃសំណល់រឹង**

នៅក្នុងច្បាប់ស្តីពី ការគ្រប់គ្រងសំណល់រឹងនិងការសម្អាតសាធារណៈ (WASTE MANAGEMENT AND PUBLIC CLEANSING LAW) បានចែកសំណល់រឹងជា ២ក្រុមធំៗរួមមាន៖

- សំណល់រឹងទីក្រុង(municipal solid waste)៖ ជាសំណល់រឹងដែលមិនមែនជាសំណល់រឹងឧស្សា- ហកម្ម ពោលគឺសំដៅទៅលើសំណល់រឹងដែលមានប្រភពចេញពីលំនៅឋាន និងសកម្មភាពអាជីវកម្ម។
- សំណល់រឹងឧស្សាហកម្ម(industrial waste)៖សំដៅទៅលើសំណល់រឹងដែលមានប្រភពចេញពីសកម្មភាពឧស្សាហកម្ម ហើយដែលមានសារជាតិបំពុល ឬ ឆ្លង (មានប្រមាណ ២០ប្រភេទសំណល់រឹង[6]) ។

**ផ្នែកទី៣៖ ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា និង ជប៉ុន**

**កថាខណ្ឌទី១៖ កត្តាប្រជាជន និងសេដ្ឋកិច្ចចំពោះការគ្រប់គ្រងសំណល់រឹង**

នៅក្នុងឆ្នាំ២០១៩ ប្រជាជននៅកម្ពុជាមានចំនួនប្រមាណ**១៥,២លាននាក់**(យោងតាមលទ្ធផលបណ្តោះអាសន្ននៃជំរឿនប្រជាជនក្នុងឆ្នាំ២០១៩ កាលពីថ្ងៃទី៣ ខែមិនាកន្លងមក)ដែលតួលេខនេះមិនបានរាប់បញ្ចូលប្រជាពលរដ្ឋកម្ពុជាដែលចំណាកស្រុកទៅបម្រើការងារនៅប្រទេសក្រៅនោះឡើយ[7] និងមានដង់ស៊ីតេប្រជាជនស្មើនឹង ៨៦នាក់ក្នុងផ្ទៃដី ១គីឡូម៉ែត្រការ៉េ។ បើប្រៀបធៀបនឹងតួលេខជំរឿនឆ្នាំ២០០៨ ប្រជាជនកម្ពុជាបានកើនឡើងប្រមាណជាង ១លាន៨សែននាក់ ឬស្មើ១៤,១%។ **រាជធានីភ្នំពេញ** ជាភូមិសាស្ត្រដែលមានចំនួនប្រជា-ជនច្រើនជាងគេបំផុត គឺមានដល់ទៅ **២,១២៩,៣៧១នាក់** ដែលបន្តឈរលំដាប់ទី១។ រីឯសេដ្ឋកិច្ចប្រទេស កម្ពុជាវិញ គឺសម្រេចបានកំណើនសេដ្ឋកិច្ច ៧,៥%នៅក្នុងឆ្នាំ២០១៨ ដែលជាអត្រាកំណើនល្អជាងការរំពឹងទុកទៅទៀត ដោយមានការជម្រុញមួយផ្នែកធំពីការកើនយ៉ាងរហ័សនៃការនាំចេញ និងការបន្តលូតលាស់នៃ វិស័យសំណង់ (យោងតាមធនាគារពិភពលោកនៅក្នុងរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាដែលចេញផ្សាយថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩)[8]។ក្នុងឆ្នាំ២០១៩កន្លងទៅនេះ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា

[6] សំណល់រឹង២០ប្រភេទនោះរួមមាន ៖ Waste paper , Livestock excreta , Waste wood , Animal carcass , Waste textile , Cinder , Animal and plant residues , Sludge , Unwanted animal solid matter , Waste oil , Waste rubber , Waste acid , Waste metal , Waste alkali , Waste glass, concrete and ceramic, Waste plastics , Waste casting sand and slag Dust , Bricks , Waste generated by the treatment of the above 19 industrial wastes។

[7] https://khmer.voanews.com/a/census-shows-population-growth-decreases/5032779.html

[8] https://www.worldbank.org/km/news/press-release/2019/05/06/world-bank-cambodias-economy-achieves-robust-growth-in-2018

(ផ.ស.ស.ឬGDP) នឹងកើនឡើងដល់ ២៧,២២២លានដុល្លារអាមេរិក ខណៈចំណូលសម្រាប់មនុស្សម្នាក់ៗនឹងកើនឡើងដល់ ១,៧០៦ដុល្លារអាមេរិក(នេះបើយោងតាមខ្លឹមសារសង្ខេបប្រតិបត្តិស្តីពី សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)[9]។

ដោយឡែកប្រទេសជប៉ុនវិញ បើគិតត្រឹមឆ្នាំ២០១៩កន្លងទៅនេះគឺមានប្រជាជនជាង **១២៦,៨៩០,៣០១ នាក់**។ **តូក្យូ**[10]ជាទីក្រុងដែលមានប្រជាជនច្រើនជាងគេ គឺមានចំនួន **៨,៣៣៦,៩៩៩នាក់**ក្នុងឆ្នាំ២០២០នេះ។ ចំពោះសេដ្ឋកិច្ចរបស់ប្រទេសជប៉ុនវិញ គឺជាសេដ្ឋកិច្ចទីផ្សារសេរីដែលមានការអភិវឌ្ឍន៍ខ្ពស់ ហើយជាប្រទេសដែលមានសេដ្ឋកិច្ចខ្ពស់ធំលំដាប់ទី៣នៅលើពិភពលោក នៅពីក្រោយសហរដ្ឋអាមេរិកនិងចិន និងបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ១,៨%នៅក្នុងត្រីមាសទី២នៃឆ្នាំ២០១៩ (នេះបើយោងតាមទិន្នន័យដែលបានចេញផ្សាយដោយគណៈរដ្ឋមន្ត្រីរបស់ប្រទេសនេះ)។ យោងតាមទិន្នន័យផ្លូវការរបស់ធនាគារពិភពលោក និងការព្យាករណ៍ពីសេដ្ឋកិច្ចពាណិជ្ជ-កម្មបានបង្ហាញថា ផលិតផលក្នុងស្រុកសរុបនៅប្រទេសជប៉ុន(ផ.ស.ស.ឬGDP) មានតម្លៃ ៥.១១០ ពាន់លានដុល្លារនៅឆ្នាំ២០១៩[11] ខណៈចំណូលសម្រាប់មនុស្សម្នាក់ៗមានចំនួន៤៥.៥៤៦ដុល្លារ[12]។ នៅឆ្នាំ២០១៨ ប្រទេសជប៉ុន គឺជាប្រទេសនាំចូលធំលំដាប់ទី៤ នៅលើពិភពលោក និងជាអ្នកនាំចេញធំជាងគេទី៤ផងដែរ។ ប្រទេសជប៉ុនគឺជាប្រទេសផលិតរថយន្តធំជាងគេទី៣នៅលើពិភពលោកនិងមានឧស្សាហកម្មទំនិញអេឡិចត្រូនិចធំជាងគេ ហើយជារឿយៗត្រូវបានជាប់ចំណាត់ថ្នាក់ក្នុងចំណោមប្រទេសច្នៃប្រឌិតថ្មីបំផុតរបស់ពិភពលោក។

ដោយសារការកើនឡើងនៃសេដ្ឋកិច្ចនិងកំណើននៃចំនួនប្រជាជន នាំឱ្យបញ្ហាបរិស្ថាន និងអនាម័យ ជាពិសេសបរិមាណនៃសំណល់រឹងជាច្រើនបានលេចរូបរាងឡើងនៅប្រទេសកម្ពុជា និងជប៉ុន។ កត្តាទាំងនេះបានចូលរួមចំណែកធ្វើឱ្យមានការកើនឡើងនូវសំណល់រឹងជាច្រើនក្នុងទម្រង់ជា សំណល់រឹងសរីរាង្គ(ចំណីអាហារ) សម្ភារៈវេចខ្ចប់ដែលបោះចោល សំណល់រឹងកើតពីដំណើរការផលិតកម្មឧស្សាហកម្ម ពេលខ្លះអាចមានសំណល់រឹងដែលមានសមាសធាតុគ្រោះថ្នាក់ផងដែរ។ ទន្ទឹមនឹងនោះ កំណើនGDP និងការប្រើប្រាស់ផលិតផលរបស់មនុស្សម្នាក់ៗក៏មានការជះឥទ្ធិពលលើទំហំនៃសំណល់រឹងផងដែរ។

### កថាខណ្ឌទី២៖ និន្នាការនៃការគ្រប់គ្រងសំណល់រឹង

ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ដោយមានការរីកចម្រើននៃកំណើនប្រជាជន និងការរីកចម្រើននៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មព្រមទាំងសេដ្ឋកិច្ចដែលកំពុងតែអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស បានធ្វើឱ្យប្រជាជន

[9] http://freshnewsasia.com/index.php/en/localnews/102968-2018-10-26-06-09-44.html

[10] រដ្ឋធានីនៃប្រទេសនេះមិនមានកំណត់ច្បាស់លាស់នៅក្នុងច្បាប់ឡើយ តែតាមសភាពជាក់ស្តែងទីក្រុង **តូក្យូ** ជាមណ្ឌលសេដ្ឋកិច្ចនយោបាយ និងជាកន្លែងស្នាក់នៅរបស់ព្រះចៅអធិរាជ។

[11] https://knoema.com/atlas/Japan/GDP-per-capita-based-on-PPP

[12] https://knoema.com/atlas/Japan/GDP-per-capita-based-on-PPP

កម្ពុជាមានជីវិតរស់នៅបែបសម្ភារៈនិយមដែលវាជាកត្តានាំឱ្យមានការបោះចោលសំណល់រឹងកាន់តែច្រើន។ ការទិញផលិតផលថ្មីៗ បានក្លាយទៅជាជម្រើសមួយយ៉ាងទាក់ទាញសម្រាប់ប្រជាជនកម្ពុជា ជាជាងការជួសជុលរបស់ចាស់ៗដើម្បីប្រើប្រាស់ឡើងវិញ។

នៅក្នុងបញ្ញត្តិនៃក្រសួងបរិស្ថាន ការគ្រប់គ្រងសំណល់រឹងទីក្រុងជាកាតព្វកិច្ចរបស់រដ្ឋ ឬអាជ្ញាធរមូលដ្ឋានក្នុងការគ្រប់គ្រងសំណល់រឹង ទាំងការផ្ដល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់រឹង និងអាចចុះកិច្ចសន្យាបន្តទៅឱ្យក្រុមហ៊ុនឯកជនជាអ្នកគ្រប់គ្រង។ នៅក្នុងការគ្រប់គ្រងសំណល់រឹងកន្លងមកមិនបានអនុលោមតាមបទដ្ឋានបរិស្ថានទេ ដោយសារបញ្ហាថវិកា,ធនធានមនុស្សនៅមានកម្រិត និងសំខាន់បំផុតនោះគឺកង្វះទំនាក់ទំនងសាធារណៈ។ នៅកម្ពុជា គេនិយមយកសំណល់រឹងទៅចាក់ចោលនៅទីលានចាក់សម្រាមតែម្ដងដែលជាដំណោះស្រាយមិនមាន ចីរភាព។ លើសពីនេះទៅទៀត សំណល់រឹងដែលប្រមូលនិងដឹកជញ្ជូនយកទៅចាក់ចោលនៅទីលានសម្រាមជាសំណល់រឹងដែលមិនមានការញែកជាមុន នៅលាយគ្នាជាមួយសំណល់រឹងសរីរាង្គ សំណល់រឹងអាចកែឆ្នៃបាន និងសំណល់រឹងដទៃទៀត[13] មួយវិញទៀតទីលានចាក់សម្រាមជាទីលានជំហរផងដែរ។ សំណល់រឹងស្ទើរតែទាំងអស់ដែលប្រមូលបានត្រូវបានយកទៅចាក់ចោលនៅទីលានជំហរ ដែលមានទីតាំងជាតំបន់លិចទឹក និងមិនមានប្រព័ន្ធបំពង់ទាញយកឧស្ម័នទីលានបម្លែងជាថាមពលយកមកប្រើប្រាស់ឡើយ។ គេមិនឃើញមានការញែកសំណល់រឹងនៅប្រភពដើមឡើយ លើកលែងតែនៅតាមផ្ទះមួយចំនួនដែលមានការញែករក្សាទុកសម្រាប់អេតចាយដែលអាចលក់បាន។

ចំពោះការគ្រប់គ្រងសំណល់រឹងនៅជប៉ុនវិញ កាលពីអតីតកាល សំណល់រឹងនៅជប៉ុនត្រូវបានគេយកទៅបំផ្លាញចោលដោយអ្នកបង្កើតរឹងសំណល់រឹងនោះដោយខ្លួនឯង ឬដោយប្រតិបត្តិការសម្អាតសម្រាមឯកជន។ ជាធម្មតា គេបោះចោលសំណល់រឹងនៅតាមដងផ្លូវ ឬនៅកន្លែងទំនេរ។ នៅឆ្នាំ១៩០០ សកម្មភាពសម្អាតសំណល់រឹងត្រូវបានរដ្ឋអនុម័តឡើងដោយកំណត់ថា ការប្រមូលសំណល់រឹងនិងការចោលសំណល់រឹង គឺជាកាតព្វកិច្ចរបស់អាជ្ញាធរមូលដ្ឋាននានា ដែលបានដាក់ឱ្យប្រតិបត្តិការសម្អាតសំណល់រឹងដោយស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាលដោយបានបញ្ជាក់ថា សំណល់រឹងគួរតែត្រូវបានដុតចោល។

ក្រោយសង្គ្រាមលោកលើកទី២ សំណល់រឹងជាច្រើនត្រូវបានកើនឡើងគរពេញនៅតាមទីវាល ឬត្រូវបានបោះចោលក្នុងទន្លេ។ រដ្ឋាភិបាលជប៉ុនបានអនុម័តច្បាប់សម្អាតសាធារណៈនៅឆ្នាំ១៩៥៤ ដែលបានកំណត់កាតព្វកិច្ចរបស់រដ្ឋាភិបាល និងអាជ្ញាធរនានាក្នុងការផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកវិទ្យាដល់អាជ្ញាធរដែនដីទាក់ទងនឹងការប្រមូល និងការចោលសំណល់រឹងក៏ដូចជាកាតព្វកិច្ចរបស់អ្នកស្រុក ដើម្បីសហការជាមួយអាជ្ញាធរក្នុងដំណើរការនេះ។

---

[13] មានទាំងសំណល់រឹងប្រកបដោយគ្រោះថ្នាក់ និង សំណល់រឹងមិនបង្កគ្រោះថ្នាក់

ដើម្បីបញ្ជាក់ពីទំនួលខុសត្រូវ និងស្តង់ដាសំរាប់ការគ្រប់គ្រងសំណល់រឹងទាំងអស់រួមទាំងសំណល់រឹងឧស្សាហកម្ម និងដើម្បីបង្កើតប្រព័ន្ធមូលដ្ឋានសម្រាប់ការគ្រប់គ្រងសំណល់រឹង រដ្ឋាភិបាលជប៉ុនបានធ្វើការកែប្រែយ៉ាងទូលំទូលាយលើច្បាប់សំអាតសាធារណៈ និងបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងឆ្នាំ១៩៧០។ យុគសម័យសេដ្ឋកិច្ចកើនឆាប់រហ័ស (សេដ្ឋកិច្ចពពុះ) ចុងទសវត្សឆ្នាំ១៩៨០ដល់ដើមទសវត្សឆ្នាំ១៩៩០ នាំឱ្យមានការកើនឡើងនៃការប្រើប្រាស់ និងការពង្រីកសកម្មភាពផលិតកម្មជាច្រើនក្នុងប្រទេសជប៉ុន។ បរិមាណនៃសំណល់រឹងជាច្រើនដែលពិបាកកែច្នៃបានបន្តកើនឡើងយ៉ាងខ្លាំង ហើយវាមានការលំបាក់ក្នុងការការពារសំណល់រឹងដែលអាចឆេះបានពីការចាក់សំណល់រឹងដោយមិនចាំបាច់ដុត(ឥន្ធនៈ)។ ដើម្បីការពារការបំពុលបរិស្ថាន បង្កើនការប្រើប្រាស់ឡដុត និងលើកកម្ពស់ការបំផ្លាញសំណល់រឹង និងការបោះចោលសំណល់រឹងអេឡិចត្រូនិច រដ្ឋាភិបាលបានបង្កើតវិធានសម្រាប់ការចាត់ចែងសំណល់រឹងក្នុងដំណើរការប្រមូលសំណល់រឹង (សំណល់រឹងចំហេះ សំណល់មិនងាយឆេះ និងប្លាស្ទិក និងសំណល់រឹងអេតចាយជ័រ) ក្នុងផែនការគ្រប់គ្រងសំណល់រឹងដែលបង្កើតដោយមូលដ្ឋាន ដោយរដ្ឋាភិបាលផ្អែកលើច្បាប់ដោយលើកកម្ពស់ការប្រមូលសំណល់រឹងតាមប្រភេទ។

នៅឆ្នាំ២០០០ រដ្ឋាភិបាលជប៉ុនបានបង្កើតសកម្មភាពមូលដ្ឋានសម្រាប់ការបង្កើតវដ្តក្នុងការប្រើប្រាស់ធនធានសម្ភារៈឱ្យត្រឹមត្រូវ(មូលដ្ឋាននៃការកែឆ្នៃដោយសុវត្ថិភាព) ឬហៅថា the development of a sound material-cycle society ដើម្បីលើកកម្ពស់ក្នុងការប្រើប្រាស់ធនធានសម្ភារៈឱ្យត្រឹមត្រូវ ដែលត្រូវបានរៀបចំឡើងដើម្បីធានាបាននូវការអនុវត្តយុទ្ធសាស្ត្រ (៣R) ដែលតម្រូវឱ្យមានជំរើសទាំងនេះតាមលំដាប់អាទិភាពដូចខាងក្រោម៖ កាត់បន្ថយ-ប្រើប្រាស់ឡើងវិញ-ប្រើប្រាស់ឡើងវិញ(៣R)-ទាញយកថាមពល និងបោះចោលសំណល់រឹងឱ្យបានត្រឹមត្រូវ។

**កថាខណ្ឌទី៣៖ បរិមាណនៃសំណល់រឹង**

យោងតាមក្រសួងបរិស្ថាន បរិមាណសំរាមសរុបដែលបានបង្កើតឡើងនៅកម្ពុជាគឺមានជាង ១ម៉ឺនតោននៅក្នុង១ថ្ងៃ និងសរុបកម្ពុជាបង្កើតសំណល់រឹងប្រមាណជិត ៤លានតោនក្នុង១ឆ្នាំ(២០១៩) ដែលក្នុងនោះ ៦៥% ជាសំណល់សរីរាង្គ,២០%ជាសំណល់ថង់ប្លាស្ទិកនិងនៅសេសសល់ជាសំណល់រឹងផ្សេងទៀត។ ក្នុងចំណោមសំណល់រឹងដែលបង្កើតឡើងគឺមានត្រឹមតែប្រមាណ៥១%ប៉ុណ្ណោះ ដែលត្រូវបានយកទៅចាក់នៅទីលានចាក់សំរាម ក្រៅពីនោះត្រូវបានយកទៅបោះចោលអនាធិបតេយ្យនៅតាមដងផ្លូវ ខ្លះបោះចោលក្នុងប្រភពទឹក និងខ្លះទៀតត្រូវបានដុត។

នៅក្នុងរាជធានីភ្នំពេញចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១៤ បរិមាណសំណល់រឹងដែលបញ្ចេញមកប្រចាំថ្ងៃបានកើនឡើងពីប្រមាណ៨០០ទៅ១.៤៧៥តោន ដែលក្នុងនោះជាងពាក់កណ្តាល(៦៥,៦%)នៃសំណល់រឹងបាន

ប្រមូលមកពីតាមផ្ទះនីមួយៗ ខណៈដែល(២៤%)ប្រមូលបានមកពីសកម្មភាពអាជីវកម្ម។ មិនតែប៉ុណ្ណោះ បរិមាណសំណល់រឹងនេះនៅតែបន្តកើនពីរង្វង់២.៦០០តោន/មួយថ្ងៃនៅឆ្នាំ២០១៨ ដល់រង្វង់២.៩០០តោន/មួយថ្ងៃនៅឆ្នាំ២០១៩កន្លងមកនេះ ពោលគឺកើនឡើង៣.០០០តោន/ក្នុងមួយថ្ងៃ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះគេសង្កេតឃើញថា មានសមាសភាពនៃសំណល់រឹងដែលបង្កើតឡើងក្នុងរាជធានីភ្នំពេញរួមមាន៖ សំណល់រឹងអាចផុយរលួយ(៥៦,៧០%),ប្លាស្ទិក(១៩,៣២%), ក្រដាស(១៤,៨៤%), អសរីរាង្គ(៨,១៤%), វាយនភ័ណ្ឌនិងស្បែកជើង(១,២៥%), កៅស៊ូនិងស្បែក (០,២៥%) ព្រមទាំងជាក្រមួន (០,០១%)[14]។

សម្រាប់បរិមាណសំណល់រឹងនៅប្រទេសជប៉ុន យើងឃើញថានៅពេលដែលការរីកចម្រើនសេដ្ឋកិច្ចក្រោយសង្គ្រាម រោងចក្របានចាប់ផ្តើមបញ្ចេញសំណល់រឹងឧស្សាហកម្មយ៉ាងច្រើនហើយតំបន់អភិវឌ្ឍន៍ទីក្រុងក៏ចាប់ផ្តើម ផលិតកំទេចកំទីសំណង់យ៉ាងច្រើនផងដែរ។ បរិមាណសំណល់រឹងនៅប្រទេសជប៉ុនបានកើនឡើងប្រមាណ៥ដងក្នុងរយៈពេល២០ឆ្នាំ គឺពី៨,៩លានតោនក្នុងឆ្នាំ១៩៦០ ដល់៤៣,៩លានតោនក្នុងឆ្នាំ១៩៨០។

គិតតាំងពីឆ្នាំ១៩៩៤ ដល់២០១៤ យើងឃើញថាចំនួននៃសំណល់រឹងសរុបនៅជប៉ុនមានការធ្លាក់ចុះខ្លះ ប៉ុន្តែមិនមានការផ្លាស់ប្តូរអ្វីគួរឱ្យកត់សម្គាល់នោះក្នុងក្នុងរយៈពេល២០ឆ្នាំ។ បរិមាណនៃសំណល់ទីក្រុងក៏មិនមានការផ្លាស់ប្តូរច្រើនដែរ ប្រហែលយ៉ាងច្រើនត្រឹមរង្វង់១០%ប៉ុណ្ណោះ ប៉ុន្តែបរិមាណសំណល់រឹងបោះចោលចុងក្រោយត្រូវបានថយចុះជាលំដាប់។ បរិមាណសំណល់រឹងសរុបរបស់ជប៉ុនក្នុងឆ្នាំ២០១៤ មានចំនួន៤៣៧លានតោន ដោយមានសំណល់រឹងឧស្សាហកម្ម៨៩,៩% ស្មើនឹង៣៩៣លានតោន និងសំណល់រឹងទីក្រុង១០,១% ស្មើនឹង ៤៤លានតោន។ បរិមាណធនធានដែលបានកែឆ្នៃឡើងវិញដែលបានមកពីសំណល់រឹងនេះគឺ៥០,៦% នៃបរិមាណសំណល់រឹងសរុបរីឯបរិមាណចាក់សំណល់រឹងចុងក្រោយនៃសំណល់រឹងសរុបមានត្រឹមតែ ៣,៤% ប៉ុណ្ណោះ។

[14] http://teangtnaut.org/wp-content/uploads/2015/10/20150916_SWM_Khm-vers_Publication_Advisor-Sarom-FV3.pdf

# ជំពូកទី២
# របបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន

## ផ្នែកទី១៖ របបនៃគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

### កថាខណ្ឌទី១៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយប្រជាពលរដ្ឋ

#### វាក្យខណ្ឌទី១៖ ការដុតបំផ្លាញសំណល់រឹង និងផលប៉ះពាល់

នៅប្រទេសកម្ពុជា ការដុតសំណល់រឹងដោយប្រជាពលរដ្ឋផ្ទាល់នៅតែជាវិធីសាស្ត្រនៃការបំផ្លាញសំណល់រឹងដែលមានការអនុវត្តជាទូទៅ ជាពិសេសនៅតាមជនបទដោយសារកង្វះខាតទីកន្លែងចាក់សំណល់រឹង ឬសេវាប្រមូលសំណល់រឹង។ ការដុតសំណល់រឹងដោយប្រជាពលរដ្ឋផ្ទាល់ត្រូវបានគេទទួលស្គាល់ថា ជាវិធីសាស្ត្រនៃការបំផ្លាញសំណល់រឹងដ៏ងាយស្រួលបំផុត ប៉ុន្តែវាបានក្លាយជាបញ្ហាប្រឈមមួយផ្សេងទៀតផងដែរ ព្រោះថាជាទូទៅក្នុងការដុតសំណល់រឹងរបស់ប្រជាជនខ្មែរ គឺពួកគេមិនមានការបែងចែកប្រភេទសំណល់រឹងឱ្យបានត្រឹមត្រូវនោះឡើយ មានន័យថា ក្នុងគំនរសំណល់រឹងរបស់ពួកគេគឺមានសមាសធាតុនៃសំណល់រឹងជាច្រើនប្រភេទនៅក្នុងនោះដូចជា កំប៉ុង, ប្លាស្ទិក, សំណល់រឹងសរីរាង្គ, សំណល់រឹងអេឡិចត្រូនិច។ល។ ហើយដែលពួកគេធ្វើការដុតបំផ្លាញទាំងអស់ជាមួយគ្នាជាហេតុនាំឱ្យមានការបំពុលដល់សុខភាពរបស់មនុស្សដោយសារក្លិន ឬផ្សែងគីមី ជាពិសេសគឺផ្សែងពុលដែលចេញពីការដុតសំណល់រឹងប្លាស្ទិក។

មានផលប៉ះពាល់ជាច្រើនចំពោះបញ្ហាសុខភាពដោយឥទ្ធិពលនៃផ្សែងភ្លើង ដែលគេបានដុតសំណល់រឹង ជាពិសេសជ័រប្លាស្ទិកដែលវាបានបម្លែងទៅជាឧស្ម័នកាបូនិច($CO_2$) ដែលមានជាតិពុលនៅក្នុងផ្សែងដែលប្រជាពលរដ្ឋមិនបានដឹងនោះទេ។ បញ្ហានេះបង្កឱ្យអ្នកស្រូបក្លិន និងផ្សែងនេះមានជម្ងឺសួតរ៉ាំរ៉ៃ ជម្ងឺរបេង រលាកបំពង់ក ក្តៅខ្លួន និងជម្ងឺផ្តាសសាយជាដើម[15]។ មិនតែប៉ុណ្ណោះផ្សែងដែលកើតចេញពីចំហេះប្លាស្ទិកមានផ្ទុកសារធាតុPM2.5ដែលសារធាតុបង្កឱ្យកើតជម្ងឺដង្ហើមនិងមហារីកហើយនៅពេលសារធាតុនេះអណ្តែតក្នុងបរិយាកាសវាអាចចូលក្នុងសួតតាមរយៈការដកដង្ហើម[16]។ មួយវិញទៀតការសាយភាយផ្សែងពីភ្នក់ភ្លើងក៏មានឥទ្ធិពលដែលធ្វើឱ្យប៉ះពាល់ភ្លាមៗដល់ខួរក្បាលមនុស្សផងដែរ ព្រោះថាខួរក្បាលមនុស្សយើងត្រូវការអុកស៊ីសែនគ្រប់គ្រាន់ ពេលណាឧស្ម័នកាបូនិចវាបុកចូលខ្លាំង នោះដង្ហើមយើងដកអត់បានគ្រប់គ្រាន់ ជាតិពុលមកចប់ពេញអស់ ហើយអាចធ្វើឱ្យមនុស្សសន្លប់ ឬខ្យល់គរជាដើម[17]។ មិនតែប៉ុណ្ណោះ ផេះដែលកើតចេញពីការដុតសំណល់រឹង និងផ្ទុកសារធាតុពុល វានឹងជ្រាបចូលក្នុងដី និងក្នុងទឹក នៅពេលដែលមានភ្លៀងធ្លាក់ ដែលបណ្តាលឱ្យមានការ

[15] https://www.rfa.org/khmer/program/health/health-affects-due-to-garbage-burn-01192017033815.html

[16] https://www.facebook.com/watch/?v=1116949418696328 (ជាវីឌីអូ ដែលបង្ហោះក្នុងបណ្តាញសង្គម Facebook របស់ក្រសួង បរិស្ថានកម្ពុជា)

[17] https://www.rfa.org/khmer/program/health/health-affects-due-to-garbage-burn-01192017033815.html

បំពុលដី និងទឹកផងដែរ ហើយធ្វើឱ្យសារធាតុពុលទាំងនោះចូលក្នុងបន្លែ ផ្លែឈើ ឬ ត្រី និងសត្វផ្សេងៗទៀត ហើយនៅពេលដែលមនុស្សបរិភោគបន្លែ ផ្លែឈើ ឬសាច់សត្វទាំងនោះ ពួកគេនឹងនាំយកសារធាតុពុលទាំងនោះចូលក្នុងខ្លួនពួកគេដែរ។

**វាក្យខណ្ឌទី២៖ ការបែងចែកសំណល់រឹងមិនត្រឹមត្រូវ និងផលប៉ះពាល់**

មកដល់ពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំនៅតែមិនទាន់យល់ដឹងពីសារៈសំខាន់នៃការញែកសំណល់រឹង ឬបែងចែកសំណល់រឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវនោះទេ។ យើងដឹងហើយថា សំណល់រឹងចែកចេញជា ២ក្រុមធំៗ គឺសំណល់រឹងប្រកបដោយគ្រោះថ្នាក់ និងសំណល់រឹងមិនបង្កការគ្រោះថ្នាក់ ដែលក្នុងនោះមានសមាធាតុសំណល់រឹងផ្សេងៗទៀតជាច្រើន ប៉ុន្តែចំពោះប្រជាពលរដ្ឋកម្ពុជាមិនបានធ្វើការញែកសមាសធាតុសំណល់ទាំងនោះតាមប្រភេទនីមួយៗនោះទេ។ ប្រជាពលរដ្ឋកម្ពុជា បានធ្វើការវេចខ្ចប់ទុកដាក់សំណល់រឹងគ្រប់ប្រភេទជាមួយគ្នានៅក្នុងថង់ប្លាស្ទិចតែមួយ ដែលធ្វើឱ្យមានការលំបាកក្នុងការញែកសំណល់រឹងទាំងនោះចេញពីគ្នាសម្រាប់កែច្នៃ ឬទុកដាក់ និងបំផ្លាញចោល។ សំណល់រឹងក្នុងគេហដ្ឋានដែលប្រជាពលរដ្ឋកម្ពុជាវេចខ្ចប់សម្រាប់បោះចោលនោះ វាមិនមែនជាប្រភពនៃសំណល់រឹងដែលអាចឱ្យមានគ្រោះថ្នាក់ផ្ទាល់ក៏ដោយ ប៉ុន្តែវានឹងបង្កឱ្យមានគ្រោះថ្នាក់ក្នុងវេលាណានាពេលអនាគតដូចជា៖ ថ្មពិល អាគុយ កំប៉ុងបាញ់សម្លាប់សត្វ កំប៉ុងដែលមានសារធាតុគីមីមួយចំនួនទៀត គឺសុទ្ធតែផ្ទុកនូវសារធាតុពុល ដូច្នេះសំណល់រឹងប្រភេទទាំងនេះគួរតែធ្វើការញែកចេញពីសំណល់ធម្មតាផ្សេងៗ។

ពិតណាស់ ការញែកសំណល់រឹងភាគច្រើនយើងឃើញថាធ្វើឡើងតាមរយៈអ្នករើសអេតចាយ ដែលការធ្វើបែបនេះដោយសារពួកគេងាយយកទៅដើម្បីលក់សម្រាប់ចំណូលប្រចាំថ្ងៃ។ ក្រុមអ្នករើសអេតចាយមានតួនាទីសំខាន់លើការងារញែក ឬបែងចែកសំណល់រឹងកែច្នៃដែលគេចោលតាមធុងសម្រាម តាមទីសាធារណៈ ឬនៅតាមទីលានចាក់សម្រាម មិនតែប៉ុណ្ណោះពួកគេមានតួនាទីសំខាន់ក្នុងការកាត់បន្ថយបរិមាណសំណល់រឹងផងដែរ។

**វាក្យខណ្ឌទី៣៖ ការវេចខ្ចប់ទុកដាក់សំណល់រឹងបណ្ដោះអាសន្ន និងផលប៉ះពាល់**

ការវេចខ្ចប់ទុកដាក់សំណល់រឹងបណ្ដោះអាសន្ន គឺសំដៅលើការស្តុកទុកក្នុងរយៈពេលខ្លីមួយមុនពេលយកទៅចាក់ចោលនៅទីលានចាក់សម្រាម។ ការវេចខ្ចប់ទុកដាក់សំណល់រឹងបណ្ដោះអាសន្ននេះ អាចមានជាការវេចខ្ចប់ទុកដាក់សំណល់រឹងបណ្ដោះអាសន្ននៅតាមលំនៅឋាន និងនៅតាមទីសាធារណៈរង់ចាំសេវានៃការប្រមូលមកដល់។

ជាធម្មតា ប្រជាពលរដ្ឋភាគច្រើនបានរក្សាសំណល់រឹងរបស់ខ្លួននៅមុខផ្ទះរបស់ពួកគេ ដោយរង់ចាំអ្នកប្រមូលតាមកាលវិភាគ។ ប្រសិនបអ្នកប្រមូលខកខានមិនបានមកប្រមូលតាមពេលវេលា នោះសំណល់រឹងទាំងនោះត្រូវទុកចោលទីនោះតែម្តង។ កាន់តែអាក្រក់ជាងនេះទៅទៀត ប្រជាពលរដ្ឋមួយចំនួនពុំរក្សាសំណល់រឹង

របស់ខ្លួននៅមុខផ្ទះរបស់ពួកគេទេ ប៉ុន្តែពួកគេបានបោះចោលនៅលើចិញ្ចើមផ្លូវ និងទីកន្លែងទំនេរ សាធារណៈផ្សេងៗទៀត។ នេះជារឿងធម្មតាទៅហើយ គេតែងតែឃើញគំនរសំណល់រឹងធំៗ ត្រូវបានដាក់ចោលលើផ្លូវសាធារណៈទាំងពេលថ្ងៃនិងពេលយប់។ នៅតាមគេហឋានក៏ដូចជាទីតាំងផ្សេងៗទៀត ការវេចខ្ចប់ទុកដាក់សំណល់រឹងរបស់ប្រជាពលរដ្ឋ គឺពុំមានធុងដែលមានគម្របត្រឹមត្រូវនោះឡើយ បើទោះបីទីតាំងខ្លះមានធុងស្តុកសំណល់រឹងក៏ដោយ ក៏ទំហំនៃធុងនោះមិនសមទៅបរិមាណនៃសំណល់រឹងដែលពួកគេបានចោលនោះទេ ដែលជាហេតុធ្វើឱ្យមានការរ៉ាយប៉ាយគ្មានសណ្តាប់ធ្នាប់ និងគ្មានអនាម័យ។ គេឃើញមានអ្នកដើររើកកាយសំណល់រឹង ដែលដើររើកកាយសំណល់រឹងផ្សេងៗ ដើម្បីអាចយកទៅកែឆ្នៃសម្រាប់លក់ដូរ ហើយទង្វើនេះធ្វើឱ្យសំណល់រឹងត្រូវបានខ្ចាត់ខ្ចាយនៅគ្រប់ទីកន្លែង និងធ្វើឱ្យសំណល់រឹងខ្លះប៉ើងតាមខ្យល់ ហើយជះក្លិនមិនល្អដល់បរិស្ថានជុំវិញនោះមិនតែប៉ុណ្ណោះវានឹងធ្វើឱ្យមានការលំបាកមួយក្នុងការប្រមូលផងដែរ[18]។

**ខ. វាក្យខណ្ឌទី៤៖ ការចោលសំណល់រឹងតាមទីសាធារណៈ និងផលប៉ះពាល់**

ការចោលសំណល់រឹងនៅតាមទីសាធារណៈ មិនមែនជាអ្វីដែលថ្មីប្លែកនោះទេសម្រាប់ប្រជាពលរដ្ឋកម្ពុជា វានៅតែជារឿងអវិជ្ជមានដែលមិនអាចមានដំណោះស្រាយណាមួយឱ្យល្អប្រសើរបាន។ ជាទូទៅគេសម្គាល់ឃើញថា ការបន្សល់សំណល់រឹងតែងតែកើតមានឡើងនៅពេលដែលមានការប្រមូលផ្តុំមនុស្សច្រើននៅកន្លែងសាធារណៈណាមួយដូចជា ការប្រគុំតន្ត្រី ការប្រកួតកីឡា ការជួបជុំកម្មវិធីកំសាន្ត ឬតាមរម្មណីយដ្ឋាននានាជាដើម។ វាមិនមែនជារឿងចម្លែកនោះទេ ដោយឃើញសម្រាមជាថង់ប្លាស្ទិកហោះហើរពាសវាលពាសកាលជាមួយនឹងគំនរសំណល់រឹង ផ្សេងៗជាច្រើនទៀតតាមទីកន្លែងសាធារណៈ។ មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែបានបោះសំណល់រឹងក្នុងធុងត្រឹមត្រូវនោះទេ។ ជាក់ស្តែងធុងសម្រាមត្រូវបានដាក់តាមផ្លូវសាធារណៈស្ទើរតែគ្រប់ទិសទីក៏ដោយ ក៏ប្រជាពលរដ្ឋនៅតែបន្តការចោលសម្រាមនៅកន្លែងណាដែលពួកគេចង់ចោលដោយគ្មានសណ្តាប់ធ្នាប់ដដែល ហើយអ្នកខ្លះទៀតបានបោះចោលសំណល់រឹងចេញពីរថយន្ត ឬមធ្យោបាយធ្វើដំណើររបស់ពួកគេខណៈដែលពួកគេកំពុងបើកបរ ឬកំពុងធ្វើដំណើរក៏មាន។ ចំណែកឯអ្នកខ្លះទៀតបានចោលសំណល់រឹងរបស់ពួកគេនៅលើសួនសាធារណៈក្បែរធុងសម្រាម ដោយមិនបានដាក់ចូលធុងសម្រាមឱ្យបានត្រឹមត្រូវនោះឡើយ ព្រមទាំងការចោលសំណល់រឹងជុំវិញផ្ទះ ឬទីតាំងឯកជននានាទៀតផងដែរ ។

នៅពេលដែលការបោះចោលសំណល់មិនត្រឹមត្រូវ ឬតាមទីសាធារណៈដោយគ្មានសណ្តាប់ធ្នាប់ ជាលទ្ធផល សំណល់រឹងទាំងនោះមួយចំនួនធំមិនត្រូវបានប្រមូល និងសម្អាតនោះទេ។ កាចោលសំណល់រឹងគ្រប់ប្រភេទតាមទីសាធារណៈពាសវាលពាសកាលមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស គឺធ្វើឱ្យប៉ះពាល់ដល់អនាម័យ បរិស្ថាន និងសោភ័ណភាព។ វាអាចជះឥទ្ធិពលអាក្រក់ទៅដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ជា

[18] https://urbanvoicecambodia.net/waste-management-in-phnom-penh/

ពិសេសអាចនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ខូចនូវសោភ័ណភាពដល់ទីក្រុង ឬទីប្រជុំជនរបស់ប្រទេសយើងដែលបញ្ហាទាំងអស់នេះ វានឹងប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ជាពិសេសវិស័យទេសចរណ៍ក៏ប៉ះពាល់ខ្លាំងផងដែរនៅពេលដែលស្ថានភាពអនាម័យ និងបរិស្ថានមិនស្អាត[19]។

**កថាខណ្ឌទី២៖ វិធីសាស្ត្រគ្រប់គ្រងសំណល់រឹងប្រើដោយរដ្ឋាភិបាល / អាជ្ញាធរ**

**វាក្យខណ្ឌទី១៖ ការប្រមូល និង ដឹកជញ្ជូនសំណល់រឹង (ក្រុមហ៊ុនឯកជន)**

ការប្រមូល និងការដឹកជញ្ជូនសំណល់រឹងមានភាពស្មុគស្មាញ និងសំញ៉ាំដោយសារការបញ្ចេញសំណល់រឹងមាននៅគ្រប់ទីកន្លែងទាំងអស់ រួមទាំងលំនៅដ្ឋាន ទីផ្សារ រោងចក្រ សហគ្រាស ផ្លូវថ្នល់ និងទីសាធារណៈផ្សេងៗ ទៀត។ ការប្រមូលសំណល់រឹង គឺផ្សាភ្ជាប់ ទៅនឹងការដឹកជញ្ជូនផងដែរ ចំណែកឯមធ្យោបាយ និងវិធីសាស្ត្រក្នុងការប្រមូល គឺមានការប្រែប្រួលទៅតាមទីតាំង និងស្ថានភាពនៃកន្លែងបង្កើតសំណល់រឹងនោះ។ ការប្រមូលសំណល់រឹងមានដូចជា៖ ការប្រមូលនៅតាមលំនៅដ្ឋាន ការប្រមូលតាមសហគមន៍ និងការប្រមូលតាមចិញ្ចើមថ្នល់។

គេដឹងថានៅប្រទេសកម្ពុជា ការផ្តល់ថវិកាដល់វិស័យសាធារណៈមានតិចតួចធៀបនឹងតម្រូវការជាក់ស្តែង។ក្រុមហ៊ុនឯកជនផ្តល់សេវាប្រមូលសំណល់រឹងជាច្រើន បានធ្វើការចរចាដោយផ្ទាល់ជាមួយស្ថាប័នជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើការគណនាប្រាក់ចំណេញរបស់ខ្លួនពីសេវាប្រមូលសំណល់រឹង។ ក្នុងការគណនាតម្លៃនេះទៀតសោត ការកំណត់ប្រភពប្រមូលសំណល់រឹងគឺជាដំណាក់កាលសំខាន់មុននឹងធ្វើការព្រមព្រៀងកំណត់តម្លៃនានា។ មានន័យថា ថវិការសម្រាប់យកទៅធ្វើការគ្រប់គ្រងសំណល់រឹង គឺបានមកពីថ្លៃដើមរបស់អ្នកប្រើប្រាស់ដែលត្រូវបានកំណត់ ដោយផ្អែកលើប្រភេទនៃអគារ រួមបញ្ចូលទាំងប្រភេទលំនៅឋានដោយគិតជាជាន់ ក៏ដូចជាថាប្រភពសំណល់រឹងដែលបានមកពីប្រភពគ្រឹះស្ថាន អាជីវកម្ម ផ្សារទំនើប គ្លីនិក ឬសាលារៀន សាកលវិទ្យាល័យជាដើម។

ជាក់ស្តែង ការគ្រប់គ្រងសំណល់រឹងបានក្លាយជាកិច្ចការអទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយសារតែរដ្ឋបាលក្រុង ស្រុកភាគច្រើនត្រូវបានផ្ទេរតិចតួចនៅឡើយនូវមុខងារនៃការគ្រប់គ្រងការប្រមូល និងដឹកជញ្ជូនសំណល់រឹង, ការខ្វះខាតនូវបទដ្ឋានគតិយុត្ត, ស្តង់ដា, និងគោលការណ៍ណែនាំសមត្ថភាពនៅមានកម្រិត និងមានឧបសគ្គលើថវិការបស់វិស័យសាធារណៈ ដែលជាហេតុធ្វើឱ្យតួអង្គក្នុងវិស័យឯកជននៅកម្ពុជាកំពុងដើរតួនាទីក្នុងការដោះស្រាយលើបញ្ហាគ្រប់គ្រងសំណល់រឹងនេះ។ ក្រុមហ៊ុនឯកជនដែលបានចុះកិច្ចសន្យាផ្តល់សេវាកម្មគ្រប់គ្រងសំណល់រឹងត្រូវបានគេរំពឹងថានឹងផ្តល់ការប្រមូលសំណល់រឹងនៅតាមទីប្រជុំជនដោយមិនពឹងផ្អែកលើការឧបត្ថម្ភធន ឬការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលក្នុងតំបន់ ឬថ្នាក់ជាតិ។ ទោះជាយ៉ាងណាក៏

[19] https://khmer.voanews.com/a/public-littering-habit-still-a-concern/3598344.html

ដោយអ្នកម៉ៅការជាច្រើននៅតែបន្តជួបប្រទះបញ្ហាជាមួយនឹងការស្តារថ្លៃដើមពីការប្រមូលសំណល់រឹង ពីព្រោះអ្នកស្រុកខ្លះមិនមានឆន្ទៈក្នុងការបង់ថ្លៃសេវាកម្មបែបនេះទេ។

ក្រុមហ៊ុនឯកជនណាដែលចង់វិនិយោគក្នុងផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំណល់រឹង គឺត្រូវធ្វើកិច្ចកិច្ចសន្យាជាមួយអាជ្ញាធរដែនដីទាំងនោះ។ រីឯកិច្ចសន្យារវាងក្រុមហ៊ុន ជាមួយអាជ្ញាធរ គឺភាគច្រើននៃកិច្ចសន្យានោះ សុទ្ធតែធ្វើឡើងជាមួយនឹងរដ្ឋបាលថ្នាក់ខេត្ត និងជាកិច្ចសន្យាដែលមានរយៈពេលខុសគ្នា មានន័យថា រដ្ឋ-បាលក្រុង ស្រុកខ្លះបានធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនក្នុងការប្រមូលនិងដឹកជញ្ជូនសំណល់រឹងដែលមានរយៈពេល១ឆ្នាំ ឬ១ទៅ៣០ឆ្នាំ ឬលើសពី៣០ឆ្នាំ។ ជាក់ស្តែងសម្រាប់ក្រុងកំពង់ចាម កិច្ចសន្យាជាមួយក្រុមហ៊ុនស៊ិនទ្រីក្នុងការប្រមូលនិងដឹកជញ្ជូនសំណល់រឹង គឺត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ចំណែករដ្ឋបាលរាជធានីភ្នំពេញវិញ គឺបានធ្វើកិច្ចសន្យារយៈពេល៥០ឆ្នាំ ជាមួយក្រុមហ៊ុនស៊ិនទ្រីផងដែរ។ ភាពខុសគ្នានៃរយៈពេលកិច្ចសន្យាពីក្រុង ស្រុកមួយទៅមួយត្រូវបានគេដឹងថា អាស្រ័យទៅលើការចរចា និងការបញ្ចុះបញ្ចូលរបស់ក្រុមហ៊ុនឯកជនជាមួយអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត។ ករណីភាគច្រើនក្នុងការផ្តល់កិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹងពុំបានធ្វើឡើងដោយបើកជំហរទូលំទូលាយឡើយ ហើយក៏ពុំបានផ្តល់លទ្ធភាពដល់សាធារណៈជនក្នុងការដឹងលឺផងដែរ។

វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹងក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំណែកដ៏សំខាន់មួយនៃសេវាកម្មគ្រប់គ្រងសំណល់រឹងនៅទីក្រុងភ្នំពេញត្រូវបានផ្តល់ហិរញ្ញប្បទានដោយក្រុមហ៊ុនឯកជនឈ្មោះ **ស៊ិនទ្រី** ដែលផ្តល់ការប្រមូល និងដឹកជញ្ជូនសំណល់រឹង ។ ក្រុមហ៊ុន ស៊ិនទ្រី បានដើរតួនាទីជាអ្នកផ្គត់ផ្គង់សេវាប្រមូលសំណល់រឹងមុនដំបូងគេនៅក្នុងរាជធានីភ្នំពេញ ចាប់តាំងពីឆ្នាំ២០០២ មកម្ល៉េះ ក្រុមហ៊ុននេះបានចុះកិច្ចសន្យារយៈពេល ៥០ ឆ្នាំជាមួយរដ្ឋាភិបាលដើម្បីផ្តល់ សេវាប្រមូលសំណល់រឹងសម្រាប់ទីក្រុងភ្នំពេញទាំងមូល។

### ចំណុច (ក)៖ ប្រតិបត្តិការប្រមូល និងដឹកជញ្ជូនសំណល់រឹងរបស់ក្រុមហ៊ុន ស៊ិន ទ្រី

ក្រុមហ៊ុនស៊ិនទ្រី (ខេមបូឌា) គឺជាក្រុមហ៊ុនឯកជនមួយដែលត្រូវបានបង្កើតឡើងនៅក្នុងខែសីហាឆ្នាំ២០០២ ក្នុងនាមជាភ្នាក់ងារសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹងក្នុងរាជធានីភ្នំពេញ។ ក្រុមហ៊ុន ស៊ិនទ្រី ទទួលសិទ្ធិពីសាលារាជធានីភ្នំពេញក្នុងការផ្តល់សេវាកម្មបោកសម្អាត ប្រមូលនិងដឹកជញ្ជូនសំណល់រឹងលើដែនដីរដ្ឋបាលសាលារាជធានីភ្នំពេញទាំងមូលដោយគ្របដណ្តប់១២ខណ្ឌស្មើនឹង៩៦សង្កាត់នាពេលបច្ចុប្បន្ន[20] ដែលអត្រាប្រមូលសំណល់រឹងក្នុងក្រុងមានប្រមាណ៨៣.៣%ជាមួយនឹងសំណល់រឹងចំនួន ៨៣៩.៥០០តោនត្រូវបោះចោលនៅទីលានដង្កោ ក្នុងឆ្នាំ២០១៥។

[20] http://www.cintri.com.kh/view.aspx?LID=KH&mID=H03

ក្រុមហ៊ុនមានកម្មករចំនួនជាង ២.៣៥៩នាក់ ដែលក្នុងចំណោមនោះកម្មករចំនួន ១.៦៧៨នាក់ ធ្វើការផ្នែកប្រតិបត្តិ។ ក្រុមហ៊ុន ស៊ិន ទ្រី មានរថយន្តផ្នែកប្រមូលសម្រាមចំនួន ៤២៦គ្រឿង និងរទេះអូសសម្រាមចំនួន២៧៣ សម្រាប់ការប្រមូលសម្រាម[21]។ ការប្រមូលសំណល់រឹង គឺធ្វើឡើងនៅពេលថ្ងៃនិងពេលយប់ដោយអាស្រ័យលើទីតាំងនីមួយៗនៅក្នុងក្រុង។ កាលវិភាគប្រមូលសំណល់រឹងនៅតាមផ្លូវអាចធ្វើឡើង«រៀងរាល់ថ្ងៃ»ឬ«រៀងរាល់ពីរថ្ងៃម្តង»ឬ«បីដងក្នុងមួយសប្តាហ៍» ចំណែកឯផ្សារមួយចំនួន ឬកន្លែងសំខាន់ៗមួយចំនួនផ្សេងទៀតគឺ«មួយថ្ងៃពីរដង»។ រថយន្តដឹកសំណល់រឹង ត្រូវបានគេប្រើប្រាស់ដើម្បីដើរប្រមូលសំណល់រឹងតាមផ្លូវសំខាន់ៗនៅក្នុងទីក្រុង ចំណែករទេះតូចត្រូវបានគេប្រើប្រាស់សម្រាប់ប្រមូលសំណល់រឹងតាមផ្លូវលំ។

ដោយសារសហគមន៍ខ្លះដែលពិបាក់ក្នុងការចូលទៅដល់បាន ការកកស្ទះចរាចរណ៍ បញ្ហាការងារ និងការពង្រីកទីក្រុងភ្នំពេញ ធ្វើឱ្យគ្រួសារជាច្រើនមិនបានទទួលសេវាប្រមូលសំរាមទៀងទាត់(ហើយខ្លះទៀតមិនបានទទួលសេវាកម្មទាល់តែសោះ)។ ប៉ុន្តែប្រសិនបើអ្នកស្រុកបដិសេធមិនបង់ថ្លៃសេវាសម្រាប់ការប្រមូលសំណល់រឹងទេ ពួកគេនឹងប្រថុយនឹងការដាច់ចរន្តអគ្គិសនី[22] ដោយសារក្រុមហ៊ុន **ស៊ិនទ្រី** ទទួលបានការបង់ថ្លៃសេវាកម្មតាមរយៈថ្លៃសេវាដែលជាផ្នែកមួយនៃវិក្កយប័ត្រអគ្គិសនីសម្រាប់លំនៅដ្ឋាននីមួយៗ។

**ចំណុច (ខ)៖ ការទូទាត់តម្លៃសេវាប្រមូលសំណល់រឹងរបស់ក្រុមហ៊ុន ស៊ិន ទ្រី**

ដោយសារផ្នែកទន់ខ្សោយនៃហិរញ្ញវត្ថុ និងធនធានមនុស្ស អាជ្ញាធរមូលដ្ឋានបានចុះកិច្ចសន្យាប្រគល់ការងារប្រមូល និងដឹកជញ្ជូនសំណល់រឹងទៅឱ្យក្រុមហ៊ុនឯកជនដោយមិនមាន សំណងរូបិយប័ណ្ណ (Monetary Compensation)។ ដោយយោងតាមការចុះសន្យាបែបនេះយើងឃើញថា គុណភាព និងសេវាប្រមូល បានធ្វើឡើងតាមធនធានវិនិយោគរបស់ក្រុមហ៊ុន និងប្រាក់ដែលទទួលបានពីប្រជាពលរដ្ឋតាមរយៈតម្លៃសេវា។ ការគ្រប់គ្រងសំណល់រឹងនៅទីក្រុង គឺអនុវត្តន៍តាម«**ប្រព័ន្ធទូទាត់លុយដោយអ្នកប្រើប្រាស់**»ផ្ទាល់ខ្លួន។ កម្រៃសេវាប្រមូលសំណល់រឹងសរុប ជាទូទៅគឺ ៤០០០៛ ឬ ១ដុល្លាអាមេរិច ក្នុងមួយខ្នងផ្ទះនៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង រហូតដល់ ១០០ដុល្លាអាមេរិច តាមទីតាំងផ្សេងៗទៀត។ ប្រជាពលរដ្ឋមួយចំនួនមិនព្រមបង់ថ្លៃសេវាប្រមូលសំណល់រឹងជូនក្រុមហ៊ុន ជាហេតុនាំឱ្យក្រុមហ៊ុនជាច្រើនបរាជ័យក្នុងការវិនិយោគនេះ។ ក្រុមហ៊ុនប្រមូលសំណល់រឹងជាទូទៅតែងតែបន្ទោសប្រជាពលរដ្ឋដែលពុំបានបង់ថ្លៃសេវា ហើយតែងតែលើកឡើងថា នេះជាមូលហេតុសំខាន់ដែលធ្វើឱ្យក្រុមហ៊ុនខ្លួនពុំបានអនុវត្តការប្រមូល ឬដឹកជញ្ជូនសំណល់រឹងបានល្អ។ ចំពោះក្រុមហ៊ុន ស៊ិនទ្រី ដើម្បីឱ្យប្រជាពលរដ្ឋបំពេញកាតព្វកិច្ចបង់ថ្លៃសេវាប្រមូលសំណល់រឹង ក្រុមហ៊ុនបានដាក់កម្រៃសេវាប្រមូល បញ្ចូលទៅក្នុងវិក័យបត្រអគ្គិសនី។ គោលបំណងនៃការធ្វើបែបនេះ គឺដើម្បីកាត់ផ្តាច់ចរន្តអគ្គិសនី

[21] Cintri provided statistics for their own workplace injuries and deaths during interviews with STT. 2018.
[22] http://asiafoundation.org/wp-content/uploads/2016/06/Working-Politically-and-Flexibly-to-Reform-Solid-Waste-Management-in-Phnom-Penh.pdf

នៅពេលដែលប្រជាពលរដ្ឋណាពុំបានបង់ថ្លៃសេវាសម្រាម។ យ៉ាងណាក៏ដោយ យន្តការនៃការប្រមូលកម្រៃសម្រាមរបៀបនេះត្រូវគេយល់ថា មិនគួរប្រើក្នុងរយៈពេលយូរឡើយ។

យោងតាមរដ្ឋបាលរាជធានីភ្នំពេញ ការចំណាយសេវាបង់ថ្លៃប្រមូលសំណល់រឹងតាមរយៈវិក្កយប័ត្រអគ្គិសនីនឹងមិនមានទៀតទេចាប់ពីថ្ងៃទី ១ មករា ឆ្នាំ២០២០ តទៅ។ ការមិនឱ្យមានការដាក់ថ្លៃសេវាប្រមូលសំណល់រឹងទៅក្នុងវិក្កយបត្រអគ្គិសនីបន្តទៀតនេះ ដោយសារតែរាជរដ្ឋាភិបាលបានមើលឃើញពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ក៏ដូចជាការត្អូញត្អែរ និងការមិនស្មើរភាពគ្នា ខណៈដែលអ្នកខ្លះមិនមានសម្រាមឱ្យប្រមូលផងក៏ត្រូវបង់ថ្លៃសេវា ទៅក្នុងវិក្កយប័ត្រអគ្គិសនីដែរ។

រដ្ឋាករស្វ័យតគ្រប់គ្រងសម្រាម និងសំណល់រឹងរាជធានីភ្នំពេញ ដែលមានភារកិច្ចទទួលបន្ទុកក្នុងការគ្រប់គ្រងការផ្តល់សេវាប្រមូលសម្រាម និងសំណល់រឹងក្នុងអំឡុងពេលអន្តរកាលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ពេលបង្កើតបាន និងដាក់ឱ្យដំណើរការពេញលេញនូវប្រព័ន្ធគ្រប់គ្រងសម្រាម និងសំណល់រឹងថ្មីក្នុងពេលឆាប់ៗខាងមុខនេះ រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីនទ្រី មានសិទ្ធិបន្តប្រតិបត្តិការសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹងបណ្ដោះអាសន្នសិន ប៉ុន្តែមិនមានសិទ្ធិក្នុងការប្រមូលថ្លៃសាវាសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹងតទៅទៀតទេ។ ចំពោះតម្លៃវិញ រដ្ឋបាលរាជធានីភ្នំពេញ ឱ្យរក្សាតម្លៃសេវាបច្ចុប្បន្នជាបណ្តោះអាសន្នសិន ហើយសេវាបង់ថ្លៃសំរាមថ្មី នឹងត្រូវបង់តាមមធ្យោបាយទូទាត់តាមប្រព័ន្ធសេវាអេឡិចត្រូនិចដូចជាតាមទូរស័ព្ទដៃ, តាមសេវា E-Money, True Money, លីហ្សួរវលុយ, PiPay, ដារាផេ និងតាមប្រព័ន្ធធនា គារអេស៊ីលីដា[23]។

**វាក្យខណ្ឌទី២៖ ទីលានចាក់សម្រាម**

ទីលានចាក់សម្រាម គឺជាកន្លែងចំបងសម្រាប់ចោលសំណល់រឹងក្នុងប្រទេសនីមួយៗ ក៏ដូចជាប្រទេសកម្ពុជាផងដែរ។ ទោះបីជាមានការកើនឡើងនូវអត្រាបង្កើតសំណល់រឹងនៅកម្ពុជាក៏ដោយ ក៏មានការរីកចម្រើនតិចតួចនៃការអភិវឌ្ឍន៍សមត្ថភាពផ្នែកហិរញ្ញវត្ថុ និងស្ថាប័ននៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ឬវិស័យឯកជនដែលបានចុះកិច្ចសន្យា សម្រាប់ការពង្រឹងស្ថានភាពនៃទីលានចាក់សំរាម។

សំណល់រឹងជាច្រើន ដែលប្រមូលបានដោយក្រុមហ៊ុនឯកជនត្រូវបានយកទៅបោះចោលនៅទីលានចាក់សម្រាមដូចជា ទីលានចាក់សម្រាមដង្កោនៅក្រុងភ្នំពេញ , ទីលានចាក់សម្រាមនៅខេត្តបាត់ដំបង , ទីលានចាក់សម្រាមនៅខេត្តកំពត និងនៅទីលានចាក់សម្រាមនៅខេត្តផ្សេងៗទៀត។ សំណល់រឹង ដែលចាក់នៅទីលានចាក់សំរាមមានចំនួន ១,៩៥ លានតោន នៅរយៈពេល ១០ខែ នៃឆ្នាំ ២០១៩ ដោយមានការកើនឡើងប្រមាណ ១៣,៤% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៨ មានតែ ១,៦៨លានតោនប៉ុណ្ណោះនៅទូទាំង

[23] http://kleykley.sabay.com.kh/article/1179888

ប្រទេស។ នៅទីក្រុងមួយចំនួន ទីលានចាក់សម្រាម គឺជាកម្មសិទ្ធិរបស់អាជ្ញាធរដែនដី ប៉ុន្តែខ្លះទៀតជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជនដែលបានចុះកិច្ចសន្យា។ ក្នុងករណីដែលទីលានចាក់សម្រាមជាកម្មសិទ្ធិរបស់អាជ្ញាធរនោះក្រុមហ៊ុនឯកជនត្រូវធ្វើការបង់ថ្លៃសេវាចោលសម្រាម។ គេសង្កេតឃើញមានប្រមាណជា ៦០ទីលានចាក់សម្រាមដែលកំពុងដំណើរការនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែភាគច្រើននៅតំបន់ទាំងនោះត្រូវបានគេដឹងថា មានគុណភាពអន់ និងការរចនាបច្ចេកទេសនៅមានកម្រិត[24]។ ករណីលើកលែងមួយ នៅរាជធានីភ្នំពេញ គឺទីលានចាក់សម្រាមដង្កោ ដែលត្រូវបានសាងសង់ឡើងដោយប្រើបច្ចេកទេសទំនើបរួមបញ្ចូលគ្នា រួមទាំងប្រព័ន្ធបង្ហូរឬសង្កត់សម្រាម និងប្រព័ន្ធបង្ហូរទឹកស្អុយ។

នៅឆ្នាំ ២០០៩ ទីលានចាក់សំរាមថ្មី គឺទីលានចាក់សម្រាមដង្កោ ដែលមានចម្ងាយ១៥គីឡូម៉ែតពីចំណុចកណ្តាលនៃរាជធានីភ្នំពេញមួយត្រូវបានបង្កើតឡើងដែលត្រូវបានរចនាឡើងក្រោមជំនួយរបស់ JICA ឱ្យដំណើរការរយៈពេល ២៥ ឆ្នាំ ដែលមានទំហំដល់ទៅជាង៣០ហិកតា ដើម្បីជំនួសទីលានចាក់សម្រាមចាស់ដែលស្ថិតនៅតំបន់ស្ទឹងមានជ័យដែលបានបិទ។ ត្រឹម ៥ឆ្នាំប៉ុណ្ណោះបន្ទាប់ទីលានដង្កោនេះបើកដំណើរការទទួលសំណល់រឹង ទីលានចាក់សំរាមនេះផ្ទុកសំណល់រឹងជិតពាក់កណ្តាលទៅហើយ ដោយសារទីលាននេះទទួលយកសំណល់រឹងទាំងអស់ដោយគ្មានការញែក និងការកែឆ្នៃឡើងវិញ។ ទីលាននេះ គឺមាន២តំបន់ គឺតំបន់ A-B និងតំបន់ C-D។ តំបន់ A-B ដែលមានជម្រៅរណ្តៅ ១០ ម៉ែត្រត្រូវបានបើកពីខែសីហាឆ្នាំ ២០០៩ ហើយត្រូវបានបិទនៅខែកុម្ភៈឆ្នាំ ២០១៦ (ដោយសារតែបានទទួលសំណល់រឹងពេញ)។ តំបន់ C (៥.៥ ហិកតា) ត្រូវបានចាប់ផ្តើមភ្លាមៗបន្ទាប់ពីការបិទតំបន់ A-B។ ជម្រៅរណ្តៅនៃតំបន់ C គឺជ្រៅណាស់ប្រហែល ៣០ ម៉ែត្រក្រោមផ្ទៃដី។ កាលពីខែឧសភាឆ្នាំ២០១៦ អគ្គិភ័យមួយបានឆាបឆេះនៅក្នុងរណ្តៅដ៏ជ្រៅហើយសំរាមជាច្រើនរយតោនត្រូវបានដុតបំផ្លាញ។ ទន្ទឹមនឹងនេះតំបន់ D ក៏ត្រូវបានគេជីកជាមួយនឹងជម្រៅរណ្តៅប្រហាក់ប្រហែលទៅនឹងតំបន់ C ដែលមានផ្ទៃដីប្រហាក់ប្រហែល ៣.៨ ហិកតាដើម្បីពង្រីកសមត្ថភាពចាក់សំរាម[25] ។ យោងតាម សាលារាជធានីភ្នំពេញធ្លាប់បានឲ្យដឹងថា ទីលានចាក់សំរាមដែលមានទំហំជាង៣០ហិកតានៅបឹងជើងឯក ក្នុងខណ្ឌដង្កោនេះនឹងត្រូវពេញហៀរមិនអាចទទួលយកសំរាមបានទៀតឡើយនៅឆ្នាំ២០២១។

[24] Ibid; interview with Mr. Sam Phall, Vice Director and Composting Project Manager at COMPED on April 02, 2015.

[25] https://www.mdpi.com/2076-3298/5/6/65/htm

**ខ-កម្មវិធីទី៣៖ ការកែឆ្នៃ / ការធ្វើជីកំប៉ុស**

ក្រៅពីការប្រើប្រាស់សេវាប្រមូលនិងដឹកជញ្ជូន និងទីលានចាក់សម្រាម ដើម្បីគ្រប់គ្រងសំណល់រឹង រដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋានក៏បានធ្វើកិច្ចសហប្រតិបត្តិការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងវិស័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងក្នុងការអនុវត្តការធ្វើជីកំប៉ុស និងកម្មវិធីកែឆ្នៃជាច្រើន។

ការធ្វើជីកំប៉ុសពីសម្រាម និងការកែឆ្នៃសម្រាមត្រូវបានបង្កើតឡើងនៅក្នុងទីក្រុង និងបណ្តាលខេត្តមួយចំនួននៅទូទាំងប្រទេស។ ឧទាហរណ៍៖ នៅខេត្តបាត់ដំបង រោងចក្រធ្វើជីកំប៉ុសមួយត្រូវបានប្រតិបត្តិការនៅជិតទីលានចាក់សម្រាម។ រោងចក្រនេះត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយក្រសួងអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់សហព័ន្ធអាល្លឺម៉ង់ (German Federal Ministry of Economic Cooperation and Development) និងសមាគម Thuringian កម្ពុជា (TKG) (the Thuringian-Cambodian Association) និងត្រូវប្រតិបត្តិដោយអង្គការមិនមែនរដ្ឋាភិបាល COMPED ។ ចំនួនសំណល់រឹងសរីរាង្គដែលបានដឹកចូលទៅកាន់រោងចក្រធ្វើជីកំប៉ុសនេះបានកើនឡើងពី ១,២តោន/ថ្ងៃ នៅក្នុងឆ្នាំ២០១៤ ទៅ១,៥ ឬ ២តោន/ថ្ងៃ នៅក្នុងឆ្នាំ២០១៥ និងទៅ ៣,៥តោន/ថ្ងៃ នៅក្នុងឆ្នាំ២០១៧។ រោងចក្រនេះផលិតបានទិន្នផលជាមធ្យម ៦ទៅ៧ តោន/ប្រចាំខែ ដែលត្រូវបានលក់ឱ្យកសិករក្នុងស្រុកខេត្តបាត់ដំបងនិងខេត្តដទៃផ្សេងទៀតក្នុងតម្លៃ១២០ដុល្លា/តោន[26]
។

នៅទីក្រុងភ្នំពេញ គម្រោងធ្វើជីកំប៉ុសត្រូវបានអនុវត្តដោយអាជ្ញាធរគ្រប់គ្រងសំណល់រឹងភ្នំពេញ (Phnom Penh Waste Management "PPWM" Authority) ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការកែឆ្នៃសម្រាម និងសិក្សានៅកម្ពុជា (COMPED) និងអង្គការស្ការ៉ូ (SCARO) ។ អាជ្ញាធរគ្រប់គ្រងសម្រាមភ្នំពេញ គឺជាអ្នកទទួលខុសត្រូវប្រមូលសំណល់រឹងសរីរាង្គនៅតំបន់ដែលកំណត់មួយចំនួន (ឧទាហរណ៍៖ សង្កាត់បឹងកេងកង១ និង២ សង្កាត់ផ្សារដើមគរ និងកន្លែងសត្តឃាត) និងផ្គត់ផ្គង់សំណល់រឹងទាំងនេះទៅឱ្យអង្គការកែឆ្នៃសម្រាម និងសិក្សានៅកម្ពុជា និងអង្គការស្ការ៉ូសម្រាប់ធ្វើជីកំប៉ុស។ ជាងនេះទៅទៀត អាជ្ញាធរគ្រប់គ្រងសំណល់រឹងភ្នំពេញក៏បានផ្តល់ទីតាំងនៅឯទីលានចាក់សម្រាមទៅអង្គការកែឆ្នៃសម្រាម និងសិក្សានៅកម្ពុជាផងដែរ ដើម្បីអនុវត្តគម្រោងធ្វើជីកំប៉ុស។

ទាក់ទងនឹងការកែឆ្នៃសម្រាម ក្រុមហ៊ុន ស៊ិនទ្រី មានគម្រោងបង្កើតរោងចក្រកែឆ្នៃសំណល់រឹងជាមួយសាលារាជធានីភ្នំពេញដើម្បីកាត់បន្ថយសំណល់រឹងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលបច្ចុប្បន្ននេះ

[26] https://wedocs.unep.org/bitstream/handle/20.500.11822/30991/PWMkh.pdf?sequence=2&isAllowed=y

មិនមានព័ត៌មានថា តើផែនការនេះកំពុងត្រូវបានអនុវត្តឬទេ និងអាចត្រូវសម្រេចបាននៅរយៈពេលប៉ុន្មានឆ្នាំនោះទេ។

## កថាខណ្ឌទី៣៖ ក្របខ័ណ្ឌគតិយុត្តនៃការគ្រប់គ្រងសំណល់រឹង

### វាក្យខណ្ឌទី១៖ ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង

រដ្ឋាភិបាលកម្ពុជា បានបង្កើតឡើងនូវបទបញ្ញត្តិ គោលនយោបាយ និងគោលការណ៍ណែនាំនានា ដើម្បីគ្រប់គ្រងសំណល់រឹងនៅកម្ពុជា ។ បទបញ្ញត្តិទាំងនោះរួមមាន ៖

- ច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹង (១៩៩៩)
- អនុក្រឹត្យស្តីពី ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (១៩៩៩)
- ប្រកាសស្តីពី ការប្រតិភូកម្មទទួលខុសត្រូវ ទៅដល់មន្ទីខេត្ត ក្រុងនានា តាមតយៈការអនុវត្តន៍អនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យតាមដាន ទឹកបំពុល និងការគ្រប់គ្រងសម្រាម (ថ្ងៃទី២ ខែមិថុនា ឆ្នាំ ១៩៩៩)
- ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរបរិស្ថានខេត្ត ក្រុង (ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩)
- គោលការណ៍ណែនាំស្តីពី ការរៀបចំក្រសួងបរិស្ថាន និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់អនុសាសន៍សម្រាប់ការអនុវត្តន៍អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំណល់រឹង (ឆ្នាំ១៩៩៩)
- ប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣)
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន (ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥)
- សារាចរអន្តរក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពី ការអនុវត្តន៍អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន (ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥)

បន្ថែមលើបទបញ្ញត្តិបានលើកឡើងខាងលើ មានគោលការណ៍ណែនាំ និងសេចក្តីសម្រេចនានាដែលរៀបចំដោយអាជ្ញាធរខេត្ត ក្រុងនីមួយៗដើម្បីគ្រប់គ្រងសម្រាមទៅតាមតំបន់របស់ពួកគេ។ លើសពីនេះទៅទៀត សេចក្តីព្រាងច្បាប់យុទ្ធសាស្ត្រជាតិ ៣R (ការកាត់បន្ថយ "Reduce" , ការប្រើប្រាស់ឡើងវិញ "Reuse" , និងការកែឆ្នៃ "Recycle") ស្តីពី ការគ្រប់គ្រងសម្រាមនៅកម្ពុជាត្រូវបានរៀបចំឡើង។

### វាក្យខណ្ឌទី២៖ ការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ

យោងតាមអនុក្រឹត្យឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងសម្រាម និងកាកសំណល់រឹងនៅទីប្រជុំជន ដែលបានចាត់តាំងឱ្យមានការទទួលខុសត្រូវទៅដល់ក្រុម និងអ្នកពាក់ព័ន្ធជាច្រើនរួមមាន៖

**ចំណុច (ក)៖ ក្រសួងបរិស្ថាន**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកម្ពស់ក្នុងការអប់រំក្នុង និងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែឆ្នៃ (3R': Reduce , Reuse , Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកែឆ្នៃសម្រាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

**ចំណុច (ខ)៖ ក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រ និងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍន៍សមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

**ចំណុច (គ)៖ រដ្ឋបាលខេត្ត**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងសម្របសម្រួល ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនដែលអនុវត្តន៍ដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានា សម្រាប់ណែនាំ និងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និងថវិកាប្រចាំសម្រាប់គ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សម្រាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណៈជនអំពីសារប្រយោជន៍នៃការញែកសម្រាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែឆ្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែឆ្នៃសម្រាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំ និងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់រដ្ឋបាល់ក្រុង ស្រុកក្នុងការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

**ចំណុច (ឃ)៖ មន្ទីរបរិស្ថានរាជធានី ខេត្ត**

មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាមយបរិស្ថានតាមរយៈការអប់រំ និងការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែឆ្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើរ ឬគម្រោងសេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

- តាមដាន ត្រួតពិនិត្យ វាយតម្លៃលើការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែឆ្នៃសម្រាម សំណល់រឹងទីប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសម្រាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។

**ចំណុច (ខ)៖ រដ្ឋបាលរាជធានី ក្រុង និងស្រុក**

រដ្ឋបាលរាជធានី ក្រុង ស្រុក មានតួនាទីក្នុងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និងថវិការប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសម្រាម សំណល់រឹងនៅទីប្រជុំជនក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋានគតិយុត្តនានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូនសម្រាម និងសេវាទីលានដាក់សម្រាម សំណល់រឹងទីប្រជុំជនក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាត អនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានដាក់សម្រាម សំណល់រឹងទីប្រជុំជន ដែលបានរៀបចំក្នុងមូលដ្ឋាន និង
- អប់រំ ផ្សព្វផ្សាយអំពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផល ដែលបានមកពិការកែច្នៃពីសម្រាម សំណល់រឹងទីប្រជុំជន។

**ចំណុច (ច)៖ រដ្ឋបាលខណ្ឌ**

រដ្ឋបាលខណ្ឌ ត្រូវទទួលខុសត្រូវអនុវត្តលើមុខងាដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សម្រាម សំណល់រឹងទីប្រជុំជនក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលទទួលបានក្នុងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនៃការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន និង

- ចូលរួមតាមដានការអនុវត្ត សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានដាក់សម្រាម សំណល់រឹងទីប្រជុំជន ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។

**ចំណុច (ឆ)៖ រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តលើមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សម្រាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវា ទីលានដាក់សម្រាម សំណល់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមផ្តល់យោបល់ដល់ការរៀបចំកម្មវិធី សម្អាត ប្រមូល ដឹកជញ្ជូនសម្រាម សំណល់រឹងទីប្រជុំជននៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយនានាដែលពាក់ព័ន្ធនឹងការងារសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានដាក់សម្រាម សំណល់រឹងទីប្រជុំជនក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសម្រាម សំណល់រឹងទីប្រជុំជន។

**ចំណុច (ជ)៖ ម្ចាស់សំណល់រឹង**

- ម្ចាស់សម្រាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងវេចខ្ចប់សម្រាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសម្រាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។
- ម្ចាស់សម្រាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសម្រាមផ្ទាល់ខ្លួននូវសម្រាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យជ្រាបទឹកស្អុយ ឬមិនឱ្យភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រងចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។
- ម្ចាស់សម្រាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសម្រាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

- ម្ចាស់សម្រាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានចាក់សម្រាម សំណល់រឹងទីប្រជុំជន ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

## ផ្នែកទី២៖ របបនៃការគ្រប់គ្រងសំណល់រឹងនៅជប៉ុន

### កថាខណ្ឌទី១៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយប្រជាពលរដ្ឋ

#### វាក្យខណ្ឌទី១៖ ការបែងចែកសំណល់រឹងនៅប្រភពដើម

ប្រព័ន្ធបែងចែកសំណល់រឹងនៅជប៉ុន មានភាពលម្អិត និងស្មុគស្មាញច្រើនជាងប្រទេសដទៃ ព្រោះវាមានភាពចាំបាច់ខ្លាំងសម្រាប់ប្រទេសនេះ។ ប្រទេសជប៉ុន ជាប្រទេសដែលមានប្រជាជនច្រើន ប៉ុន្តែមានកន្លែងទំនេរតិចតួចដែលជាហេតុធ្វើឱ្យមានការកើនឡើងនៃសំណល់រឹងជាច្រើនតែមិនសូវមានទីលានទុកដាក់សំណល់រឹងទាំងនោះដូចបណ្តាលប្រទេសដទៃទៀតឡើយ។ ដូច្នេះហើយ មធ្យោបាយដើម្បីកាត់បន្ថយសំណល់រឹងនៅទីលានចាក់សម្រាមឱ្យមានអត្រាអប្បរមា នោះសំណល់រឹងនៅក្នុងប្រទេសជប៉ុនត្រូវបានគេយកទៅដុតចោល។ ហេតុផលនៃការដុតសំណល់រឹងនេះហើយ ដែលធ្វើឱ្យប្រព័ន្ធនៃការបែងចែកសំណល់រឹងនៅប្រទេសជប៉ុនគឺមានភាពសំខាន់និងចាំបាច់បំផុតព្រោះសំណល់រឹងប្រភេទផ្សេងៗគ្នាត្រូវការវិធីនៃការដុតក៏ផ្សេងៗគ្នាដែរ។ ប្រសិនបើមិនមានការបែងចែក ឬលាយបញ្ចូនគ្នានៃសំណល់រឹងទាំងអស់ នោះវាធ្វើឱ្យមានភាពលំបាកខ្លាំងសម្រាប់បុគ្គលិករបស់ក្រុមហ៊ុនបោះចោលសំណល់រឹងដែលពួកគេត្រូវធ្វើការបែងចែកឡើងវិញម្តងទៀត។

នៅជប៉ុន ប្រភេទសំណល់រឹងសម្រាប់ធ្វើការញែកមាន **៤ ប្រភេទ**សំខាន់ៗ ហើយប្រភេទនីមួយៗសុទ្ធតែមានកាលបរិច្ឆេទប្រមូលរៀងៗគ្នា។ ទោះយ៉ាងណាក៏ដោយ វាអាចខុសគ្នាអាស្រ័យលើតំបន់ ឬក្រុងដែលពួកគេរស់នៅដូចជា ទីក្រុង Kakimatsu ក្នុងតំបន់ Shikoku ជាកន្លែងមានប្រភេទសំរាមខុសៗគ្នារហូតដល់ចំនួន ៤៤ប្រភេទ។ ប្រភេទសំណល់រឹងសំខាន់ៗទាំង ៤ នោះរួមមាន[27]៖

**(១) សំណល់រឹងងាយឆេះ** Combustible Trash ៖ គឺជាសំណល់រឹងមូលដ្ឋានមួយដែលអាចធ្វើការដុតបាន។ របស់របរដូចជា សំណល់ក្រដាស(កន្សែងក្រដាស),ថង់ប្លាស្ទិក,ផលិតផលខ្ចប់អាហារ,ក្រណាត់,ស្បៀងអាហារ,បំណែកតូចៗនៃឈើ ឬក្រណាត់,ជ័រនិងកៅស៊ូ និងស្បែកជាដើម និងរបស់របរប្រហាក់ប្រហែលនេះត្រូវបានគេចាត់ចូលក្នុងប្រភេទសំណល់រឹងងាយឆេះនេះ។ នៅតំបន់ខ្លះ ប្លាស្ទិកមិនត្រូវបានសម្គាល់ដោយម៉ាក ឬផ្លាកសញ្ញាប្លាស្ទិកនោះទេ។ ឧទាហរណ៍ដូចជា សម្លៀកបំពាក់ចាស់ៗប្រសិនបើមិនមានការទុកដាក់ និងប្រមូលដោយឡែកនោះទេ នោះសម្លៀកបំពាក់ចាស់ៗទាំងនេះនឹងត្រូវបានចាត់ចូលជាប្រភេទសំណល់រឹងប្លាស្ទិកផងដែរ។ សំណល់រឹងប្រភេទនេះភាគច្រើនជារបស់ដែលមនុស្សបោះចោល ហើយជាធម្មតាត្រូវបានគេប្រមូល ២ដងក្នុងមួយសប្តាហ៍។

---

27 https://www.tsunagujapan.com/everything-you-need-to-know-about-garbage-in-japan/

**(២) សំណល់រឹងមិនងាយឆេះ Incombustible Trash៖** គឺជាសំណល់រឹងដែលមិនអាចដុតបាន។ វត្ថុធ្វើពីដែក, កញ្ចក់ខូច, ពែង, ចាន, ceramics ត្រូវបានគេចាត់ទុកថាជាសំណល់រឹងមិនងាយឆេះ។ អាស្រ័យលើសាលាក្រុងផងដែរ សំណល់រឹងមិនអាចដុតបានអាចរាប់បញ្ចូនផងដែរនូវប្រភេទឧបករណ៍អេឡិចត្រូនិច, អំពូលភ្លើង, ថ្មពិល និងកំប៉ុងបាញ់ថ្នាំ ប៉ុន្តែវត្ថុទាំងនេះអាចស្ថិតនៅក្រោមសំណល់រឹងមានគ្រោះថ្នាក់ ដែលជាប្រភេទសំណល់រឹងដោយឡែកមួយផ្សេងទៀត។ ផលិតផលប្លាស្ទិកដែលមិនមានម៉ាក ឬផ្លាកសញ្ញាសម្គាល់ប្លាស្ទិក អាចស្ថិតនៅក្នុងប្រភេទសំណល់រឹងនេះផងដែរនៅតាមតំបន់ខ្លះ។ សំណល់រឹងប្រភេទទាំងនេះ ជាធម្មតាត្រូវបានគេប្រមូលម្តងក្នុងមួយខែ។

**(៣) សំណល់រឹងអាចយកទៅកែឆ្នៃឡើងវិញ Recyclables Trash៖** មានដូចជាដប,អាលុយមីញ៉ូម, ដែកថែប,ដបប្លាស្ទិក PET,ទស្សនាវដ្តី,កាសែត,ក្រដាសកាតុង,ក្រដាសអេតចាយ,ប្រអប់ទឹកដោះគោ សុទ្ធតែជាប្រភេទនៃសំណល់រឹងអាចប្រើប្រាស់ឡើងវិញបាន។ ប្រភេទក្រដាសកាតុង និងក្រដាស ជាទូទៅត្រូវបានចងជាបាច់ និងភ្ជាប់ជាមួយអក្សរថា«ធ្វើមកពីក្រដាស»។ នៅក្នុងប្រភេទសំណល់រឹងនេះចែកជាប្រភេទរងចំនួន ៣ ដោយឡែកពីគ្នាទៀតគឺ កំប៉ុង,ដបកែវ,និងដបប្លាស្ទិក PET។ របស់របរទាំងនេះចាំបាច់ត្រូវញែកដាច់ពីគ្នាហើយជាធម្មតាគេប្រមូលបានម្តងក្នុងមួយសប្តាហ៍ ឬពីរសប្តាហ៍ដោយសម្ភារៈនីមួយៗត្រូវបានរើសនៅថ្ងៃដាច់ដោយឡែកពីគ្នា។

**(៤) សំណល់រឹងហួសកម្រិត Oversized trash៖** គឺជាសំណល់រឹងដែលធំជាងសំណល់រឹងធម្មតាប្រចាំថ្ងៃមានដូចជា ប្រដាប់ប្រដាប្រើប្រាស់ក្នុងផ្ទះ, គ្រឿងសង្ហារិម, គ្រែដេក និងរបស់របរដែលមានទំហំលើសពីទំហំជាក់លាក់មួយ(ជាទូទៅ ៣០សង់ទីម៉ែត្រនៅម្ខាង)។ នៅតាមតំបន់នីមួយៗមានការកំណត់ពីនិយមន័យខុសៗគ្នាចំពោះប្រភេទសំណល់រឹងនេះ តែតាមច្បាប់ជាទូទៅ គឺអ្វីៗដែលមានប្រវែងលើសពី ៣០ស.ម នៅម្ខាង។ សូមកត់សម្គាល់ថា នេះមិនរាប់បញ្ចូលរបស់របរដែលមានចែងនៅក្នុងច្បាប់ស្តីពីការកែឆ្នៃឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ដូចជា ម៉ាស៊ីនត្រជាក់ទូរទស្សន៍, ទូទឹកកក, ម៉ាស៊ីនបោកគក់/ម៉ាស៊ីនសម្ងួត និងកុំព្យូទ័រ។

** វាក្យខណ្ឌទី២៖ ការរៀបចំ និងវេចខ្ចប់សំណល់រឹង**

នៅពេលប្រជាជនជប៉ុនរៀបចំសំណល់រឹងសម្រាប់ការប្រមូល ពួកគេបានធ្វើការពិនិត្យមើលប្រភេទថង់សំណល់រឹងរបស់ពួកគេ ថាតើពួកគេត្រូវប្រើប្រាស់ថង់ប្រភេទមួយណាសម្រាប់ដាក់សំណល់រឹងរបស់ពួកគេ។ ពួកគេមានច្បាប់ជាក់លាក់សម្រាប់ធ្វើការកំណត់អំពីរបៀបនៃការវេចខ្ចប់សំណល់រឹងរបស់ពួកគេ ហើយវាក៏អាស្រ័យទៅតាមតំបន់ ឬក្រុងនីមួយៗផងដែរ។

ក្រុងជាច្រើនតម្រូវឱ្យដាក់សំណល់រឹងក្នុងថង់សំណល់រឹង ដែលបានកំណត់សម្រាប់ក្នុងការប្រមូល។ ថង់ដាក់សំណល់រឹងទាំងនេះអាចទិញនៅផ្សារទំនើប ហាង ឬកន្លែងលក់ជាច្រើនទៀត និងមានទំហំខុសៗគ្នា និងមានពណ៌ដាច់ដោយឡែកដែលបង្ហាញពីប្រភេទសំណល់រឹងដែលដាក់ក្នុងថង់នីមួយៗ និងមានសមត្ថភាព

ដាក់របស់វាចាប់ពី ៥ទៅ៤០លីត្រ ហើយមានពណ៌ខុសៗគ្នាអាស្រ័យលើប្រភេទសំណល់ដុតបាន និងមិនអាចដុតបាន។ ខាងក្រោមនេះគឺជាវិធីខ្លីៗ សម្រាប់វេចខ្ចប់សំណល់រឹងរបស់ប្រជាជននៅជប៉ុនតាមប្រភេទសំណល់រឹងនីមួយៗ៖

- **ការវេចខ្ចប់សំណល់អាចដុតបាន៖** សំណល់រឹងផ្ទះបាយគួរតែត្រូវបានបង្ហូរសំណើមក្នុងសំណល់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានមុនពេលដាក់សំណល់រឹងទាំងនោះចូលក្នុងថង់ ហើយថង់គួរតែត្រូវបានចងមាត់យ៉ាងតឹង ហើយដាក់សម្រាប់ការប្រមូលនៅពេលវេលាសមស្របដើម្បីការពារសត្វពីការកកាយនាំឱ្យខ្ចាត់ខ្ចាយសំណល់រឹងទាំងនោះ។
- **ការវេចខ្ចប់ខ្ចប់សំណល់មិនអាចដុតបាន៖** សំណល់រឹង គួរតែត្រូវបានដាក់ក្នុងធុងសម្រាមឱ្យបានត្រឹមត្រូវ ហើយទុកចោលខាងក្រៅសម្រាប់ធ្វើការប្រមូលនៅថ្ងៃសមរម្យ។ វត្ថុមុតស្រួចដូចជា កាំបិតចាស់,កញ្ចក់បែក ,និងម្ជុល គួរតែត្រូវបានខ្ចប់ក្នុងថង់ដែលមានអក្សរ キケン (kiken) ស្មើនឹងពាក្យ "hazardous," (គ្រោះថ្នាក់) ដូច្នេះហើយកម្មករប្រមូលសំណល់រឹងអាចចៀសវាងពីការរបួសនៅពេលដែលពួកគេធ្វើការប្រមូល។ អំពូលដែលដាច់ ឬងាប់គួរតែត្រូវបានដាក់ក្នុងប្រអប់ដើមដើម្បីចៀសវាងការបែក(ប្រសិនបើអ្នកទិញអំពូលថ្មីមកជំនួសអំពូលដែលដាច់នោះ សុំយកប្រអប់អំពូលថ្មីមកដាក់អំពូលដាច់នោះ)។
- **ការវេចខ្ចប់ផលិតផលសម្រាប់ប្រើប្រាស់ឡើងវិញ៖** កំប៉ុង, ដបប្លាស្ទិច និងដបកែវ ត្រូវបានលាងសម្អាតឱ្យបានស្អាត ហើយដកស្លាកខាងក្រៅចេញនៅពេលដាក់ចូលធុងសម្រាមប្រសិនជាអាច។ រីឯក្រដាស/ ក្រដាសកាតុង ត្រូវបានរៀបចំតាមប្រភេទ និងចងជាមួយខ្សែយ៉ាងបានត្រឹមត្រូវ។ បន្ទាប់មកដាក់វាចូលក្នុងថង់ ឬធុងសម្រាមសម្រាប់ការប្រមូល។
- **ការរៀបចំបោះចោលផលិតដែលលើសកម្រិត៖** ដើម្បីបោះចោលសំណល់រឹងប្រភេទនេះ ត្រូវតែទូរស័ព្ទទាក់ទងជាមួយអ្នកផ្តល់សេវាប្រមូល និងបញ្ជាទិញស្លាកដែលសម្គាល់ថាជា **សំណល់រឹងហួសកម្រិត**។ ស្លាកនេះ គឺជាភស្តុតាងនៃការទូទាត់របស់អ្នកសម្រាប់សេវាកម្មបោះចោល ហើយបន្ទាប់មក ត្រូវដាក់ចេញថ្ងៃជាក់លាក់មួយក្នុងការប្រមូល ព្រមទាំងធ្វើការបង់ថ្លៃសេវាកម្មផងដែរ។ នៅពេលដល់ថ្ងៃដែលបានកំណត់ អ្នកអាចទុកសំណល់រឹងប្រភេទនេះនៅកន្លែងប្រមូលបាន។

### វាក្យខណ្ឌទី៣៖ ការបោះចោលសំណល់រឹង

ការចោលសំណល់រឹងក្នុងប្រទេសជប៉ុន មានភាពស្មុគស្មាញជាងប្រទេសដទៃទៀត។ នៅតាមទីសាធារណៈប្រទេសនេះមានលក្ខខណ្ឌកំណត់នៃប្រភេទសំណល់រឹងនៅតាមដងផ្លូវ ហើយភាគច្រើនគឺសម្រាប់ការកែឆ្នៃឡើងវិញ។ ចំណែកនៅតាមផ្ទះវិញ គឺមិនមានលក្ខខណ្ឌលម្អិតនោះឡើយ ព្រោះសង្កាត់ ឬតំបន់នីមួយៗមានការគ្រប់គ្រងវិធានការគ្រប់គ្រងសំណល់រឹងផ្ទាល់ខ្លួនរបស់ពួកគេ។ ការចោលសំណល់រឹងតាមផ្ទះនៅជប៉ុនអាចជាបទពិសោធន៍គួរឱ្យស្ញប់ស្ញែងដោយមានប្រភេទដាច់ដោយឡែកសម្រាប់របស់របរដែលអាចឆេះ

បាន, មិនងាយឆេះ, អាចយកទៅកែច្នៃឡើងវិញបាន, ទំនិញហួសកម្រិត, និងកាលវិភាគដ៏តឹងរឹងសម្រាប់កំណត់ប្រភេទនីមួយៗសម្រាប់ប្រមូល និងមានថង់ប្រភេទផ្សេងៗសម្រាប់ទិញដើម្បីទុកដាក់សម្រាម។

ចំពោះការបោះចោលសំណល់រឹងធំៗ ភាគច្រើនគ្រឿងសង្ហារិមមានប្រវែងលើសពី ៣០ស.ម ត្រូវការរក្សាទុក និងបង់ថ្លៃសេវាកម្ម។ ឧទាហរណ៍៖ សាឡុងតែមួយមានតំលៃ ៨០០យ៉េន(៧,៣៧ ដុល្លារអាមេរិក) និងសាឡុង២ មានតម្លៃ ២,០០០យ៉េន(១៨,៤២ ដុល្លារអាមេរិក)។ យោងតាមគេហទំព័ររបស់រដ្ឋាភិបាល Shibuya ត្រូវចំណាយប្រាក់ ២,៤៨៤យ៉េន(២២,៨៨ ដុល្លារអាមេរិក) ដើម្បីបោះចោលម៉ាស៊ីនបោកគក់មួយ។ ការទុកដាក់សំណល់រឹងមិនត្រឹមត្រូវអាចធ្វើឱ្យមានការផាកពិន័យខ្ពស់ និងអាចជាប់គុកជាមួយនឹងវិធាននៃការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងររបស់ប្រទេសជប៉ុន។

នៅជប៉ុន ការចោលសំណល់រឹងតាមទីសាធារណៈត្រូវបានគេចាត់ទុកថា ជាការចោលសំណល់រឹងខុសច្បាប់ និងត្រូវប្រឈមនឹងការពិន័យចាប់ពី ៥ឆ្នាំឡើងទៅព្រមទាំងពិន័យជាប្រាក់រហូតដល់ ១០លានយ៉េន (៩២,១០០ដុល្លារអាមេរិក)។ រីឯចំពោះក្រុមហ៊ុនអាចត្រូវបានផាកពិន័យរហូតដល់ ១០០លានយ៉េន (៩២១,០០០ ដុល្លារអាមេរិក) ចំពោះការចោលសំណល់រឹងឧស្សាហកម្មខុសច្បាប់។

ប្រជាជនជប៉ុនបោះចោលសំណល់រឹងរបស់ពួកគេនៅទីតាំងគំនរសំណល់រឹងខាងក្រៅផ្ទះ ដើម្បីឱ្យរថយន្តដឹកសំណល់រឹងមកប្រមូល ដូច្នេះភាគច្រើនមិនមានដាក់ធុងសំរាមនៅមុខផ្ទះរបស់ពួកគេទេ។ ប្រសិនបើអ្នកប្រមូល សំណល់រឹងរកឃើញថា ប្រជាពលរដ្ឋមិនបានធ្វើការបែងចែកសំណល់រឹងឱ្យបានត្រឹមត្រូវ និងបោះចោលសំណល់រឹងក្នុងពេលវេលាខុសពីការកំណត់ ពួកគេអាចបដិសេធមិនព្រមប្រមូលសំណល់រឹងទាំងនោះ ហើយសរសេកំណត់ចំណាំ ដើម្បីរំលឹកម្ចាស់សំណល់រឹងនោះធ្វើការបែងចែកសំណល់រឹងរបស់ពួកគេឱ្យបានត្រឹមត្រូវវិញ។ ប្រជាជនជប៉ុនចាត់ទុកថាការបដិសេធមិនព្រមទទួលការប្រមូលសំណល់រឹងដោយសារការមិនបានបែងចែកសម្រាមឱ្យបានត្រឹមត្រូវ គឺជារឿងដ៏អាម៉ាស់បំផុតសម្រាប់ពួកគេ។

## កថាខណ្ឌទី២៖ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹងប្រើដោយរដ្ឋាភិបាល/អាជ្ញាធរ

### វាក្យខណ្ឌទី១៖ ការប្រមូល និងដឹកជញ្ជូន (ស្ថានីយផ្ទេរសំណល់រឹង)

កាលណាគេពង្រីកទីក្រុង គេក៏ត្រូវតែធ្វើការពង្រីកនូវទីតាំងប្រមូលសំណល់រឹងផងដែរ។ ការដែលពង្រីកនូវទីតាំងប្រមូលសំណល់រឹង វាអាចធ្វើឱ្យមានភាពប្រសើឡើងក្នុងការប្រមូលសំណល់រឹងទាំងនោះ និងការដឹកជញ្ជូននៅក្នុងទីក្រុងដោយត្រូវបង្កើតឡើងនូវស្ថានីយផ្ទេរសំណល់រឹង ដែលអាចធ្វើឱ្យសំណល់រឹងអាចផ្ទេរបានពីឡានដឹកសំណល់រឹងខ្នាតតូច ឬមធ្យមទៅកាន់ឡានដឹកទំនិញធំៗបាន។ បើទោះបីតម្លៃនៃការប្រមូល និងដឹកជញ្ជូនសំណល់រឹងតាមរបៀបនេះ វាមានតម្លៃថ្លៃជាងកាលដែលយកទៅបោះចោលសំណល់រឹងតែម្តងក៏ដោយ ប៉ុន្តែការកែលម្អបែបនេះ វាធ្វើឱ្យការប្រមូល និងដឹកជញ្ជូនសំណល់រឹងប្រកបដោយរបៀបរាបរយ និងឆាប់រហ័ស ម្យ៉ាងទៀតអាចកាត់បន្ថយការចំណាយលើការរក្សាទុកប្រចាំថ្ងៃរបស់ប្រជាជន និងជាពិសេសដើម្បីកែ

លម្អរសេវាកម្មដល់ប្រជាជនឱ្យពួកគេមានភាពងាយស្រួលក្នុងការរស់នៅ ព្រមទាំងជួយកាត់បន្ថយការបំភាយឧស្ម័នកាបូនិចដែលរួមចំណែកដល់ការការពារការឡើងកំដៅផែនដី។

ការរៀបចំស្ថានីយផ្ទេរសំណល់រឹង ដែលសំណល់រឹងអាចផ្ទេរពីរថយន្តធុនតូច ទៅរថយន្តធុនធំ ដែលវាជាយុទ្ធសាស្ត្រល្អក្នុងការកែលម្អប្រសិទ្ធិភាពក្នុងការដំណើរការប្រមូល និងដឹកជញ្ជូនសំនល់រឹងទីក្រុងដែលមានទីតាំងប្រមូលធំទូលាយ។ វិធីសាស្ត្រស្ថានីយផ្ទេរសំណល់រឹងនេះ ត្រូវបានគេអនុម័តជាទូទៅក្នុងប្រទេសជប៉ុនដោយសំណល់រឹងដែលប្រមូលដោយរថយន្តដឹកសំណល់រឹងខ្នាតតូចៗ ត្រូវបានទម្លាក់សំណល់ចូលទៅក្នុងម៉ាស៊ីនបង្រួម រួចបញ្ចូលបញ្ចូលក្នុងកុងតឺន័រ ហើយដាក់ទៅក្នុងឡានដឹកទំនិញធំៗវិញ។ នៅក្នុងស្ថានីយ៍ផ្ទេរសំណល់រឹងនេះ សំណល់រឹងដែលប្រមូលបានដោយឡានដឹកសំណល់រឹង ២ ទៅ ៣ តោន អាចបង្រួមបានក្នុងកុងតឺន័រតែមួយ។ បន្ទាប់មកកុងតឺន័រត្រូវបានដឹកទៅកាន់កន្លែងចោល ឬរោងចក្រដុតដោយឡានដឹកទំនិញធំមួយ។

ការផ្ទេរទៅឡានដឹកទំនិញធំៗ នៅស្ថានីយ៍ដឹកជញ្ជូនធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពនៃការដឹកជញ្ជូន និងជួយកាត់បន្ថយការចំណាយការប្រើប្រាស់ឥន្ធនៈ ព្រមទាំងកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចផងដែរ។ វានឹងមានប្រសិទ្ធិភាពជាងនៅតាមបណ្តាប្រទេសអាស៊ីជាច្រើនក្នុងការប្រើប្រាស់ឡានដឹកទំនិញតូចពីព្រោះផ្លូវតូច។ ផ្លូវជាច្រើននៅក្នុងប្រទេសជប៉ុនក៏តូចចង្អៀតដែរហើយរថយន្តដឹកសំណល់រឹងធុនតូចពី ១ ទៅ ២ តោនត្រូវបានបង្កើតឡើង។ ឡានដឹកសំណល់រឹងមាន ២ប្រភេទ គឺឡានដឹកសំណល់រឹង មេកានិច (ដែលមានអ្នកប្រមូលចល័ត) និងឡានដឹកសំណល់រឹងដែលមាន ម៉ាស៊ីនបង្ហាប់ ប៉ុន្តែប្រភេទឡានដឹកសំណល់រឹងមេ-កានិច ត្រូវបានគេនិយមប្រើប្រាស់ជាទូទៅជាង។ រីឯឡានដឹកទំនិញប្រភេទម៉ាស៊ីនបង្ហាប់ វាមានប្រសិទ្ធភាពក្នុងការប្រមូលសំណល់រឹងធំៗ ដោយសារតែវាអាចបង្ហាប់សំណល់រឹងដែលសំពីងសំពោងឱ្យមានលក្ខណៈតូច ដូចជាសំណល់រឹងប្លាស្ទិក ឬដបជាដើម។ សហគ្រាសជប៉ុនមួយចំនួនបានបង្កើតការបណ្តាក់ទុនរួមគ្នានៅក្នុងប្រទេសចិនជាមួយនឹងសមិទ្ធិផលខ្ពស់ក្នុងការផលិត និងលក់ស្ថានីយ៍ផ្ទេរសំណល់រឹង។ អ្នកខ្លះក៏លក់វាទៅប្រទេសអាស៊ីផ្សេងទៀតដូចជា ម៉ាឡេស៊ីជាដើម។

**វាក្យខណ្ឌទី២៖ ទីលានចាក់សម្រាម**

ក្នុងឆ្នាំ ១៩៧៧ ដើម្បីធានាបាននូវការបោះចោលសំរាមដោយសុវត្ថិភាព រដ្ឋាភិបាលជប៉ុនបានបង្កើតស្តង់ដារស្ថាបត្យកម្ម និងការថែទាំសម្រាប់ទីលានចាក់សម្រាម ក្នុងបទប្បញ្ញត្តិនៃច្បាប់គ្រប់គ្រងសំណល់រឹង។ រដ្ឋាភិបាលក៏បានកំណត់ទីលានចាក់សម្រាមជា ៣ប្រភេទ សម្រាប់ការចោលសំណល់រឹងផងដែរ គឺ controlled landfill, inert landfill, and isolated landfill ។

សំណល់រឹងដែលបង្កឱ្យមានគ្រោះថ្នាក់ ហើយមានឥទ្ធិពលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងបរិស្ថានត្រូវតែបោះចោលនៅឯប្រភេទទីលានចាក់សម្រាម isolated landfill។ រីឯសំណល់រឹងមិនបង្កគ្រោះ

ថ្នាក់ ហើយមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធទឹកសាធារណៈ និងទឹកក្រោមដី ឬអាចប៉ះពាល់ដល់បរិស្ថាន ដោយសារឧស្ម័ន ក្លិន ឬសត្វល្អិត ត្រូវតែបោះចោលនៅឯប្រភេទទីលានចាក់សម្រាម controlled landfill និង ចំពោះសំណល់ងប្លាស្ទិក, កម្ទេចជ័រកៅស៊ូ, កំទេចកំទីដែក, កញ្ចក់សេរ៉ាមិច និងឥដ្ឋដែលមានឥទ្ធិពលតិចតួច ក្នុងការបង្កឱ្យមានការបំពុល បរិស្ថានអាចត្រូវបានគេបោះចោលនៅឯប្រភេទទីលានចាក់សម្រាម inert landfill ។

នៅទូទាំងប្រទេសជប៉ុនមានទីលានចាក់សម្រាមចំនួនប្រមាណ ២,៣៣៥កន្លែង នៅឆ្នាំ២០០៦។ ប្រសិនបើប្រទេសជប៉ុនបន្តផលិតសំណល់រឹងនៅទីលានចាក់សម្រាមទូទាំងប្រទេសជាង ៤០លានតោនក្នុង មួយឆ្នាំ នោះទីលានចាក់សម្រាមអាចនឹងត្រូវចាក់បំពេញក្នុងរយៈពេលប្រហែល ២០,៥ ឆ្នាំទៀត[28]។ ក្រសួង បរិស្ថានជប៉ុន បានស្នើឱ្យបញ្ឈប់ការចោលសំណល់រឹងដោយផ្ទាល់ទៅក្នុងទីលានចាក់សម្រាម ដើម្បីកាត់បន្ថយ បរិមាណសំណល់រឹងនៅឯទីលានចាក់សម្រាម ជាពិសេសដើម្បីទប់ស្កាត់ការបំភាពឧស្ម័នផ្ទះកញ្ចក់។ ៧០% នៃ កន្លែងចាក់សម្រាមទីក្រុងបានប្រើប្រាស់វិធីសាស្ត្រមួយហៅថា **semi-aerobic system** ។ ប្រភេទទីលានចាក់ សម្រាមដែលប្រើប្រព័ន្ធ semi-aerobic system នេះ មានបំពង់បង្ហូរទឹកសំអុយ ឬទឹកមានសារធាតុគីមីដែល ស្ថិតនៅខាងក្រោមទីលានចាក់សម្រាម។ ខ្យល់ធម្មជាតិ ត្រូវបាននាំចូលតាមរយៈបំពង់បង្ហូរទឹកសំអុយទៅកាន់ ស្រទាប់នៃទីលានចាក់សម្រាមដើម្បីធ្វើឱ្យមានការបំបែកធាតុនៃសំណល់រឹងទាំងនោះ។ ការធ្វើបែបនេះ ជួយឱ្យ មានស្ថេរភាពនៃសំណល់រឹងក្នុងការទប់ស្កាត់ការបង្កើតឧស្ម័នមេតាន និងឧស្ម័នផ្ទះកញ្ចក់ដែលធ្វើឱ្យវាមានការ ឡើងកំដៅផែនដី។ ជាទូទៅ ខ្យល់ធម្មជាតិក្នុងបរិយាសកាសអាចបម្លែងកាបូននៅក្នុងសំណល់សរីរាង្គទៅជា កាបូនឌីអុកស៊ីត និងអាចបម្លែងអ៊ីយ៉ុងផ្សេងៗទៀត ដែលកាត់បន្ថយការបង្កើតក្លិនមិនល្អ និងឧស្ម័នដែលងាយ ឆេះ។ លើសពីនេះទៀតខ្យល់ធម្មជាតិ អាចជួយបង្កើនល្បឿនសកម្មភាពរបស់មីក្រូសរីរាង្គដែលបំផ្លាញសំណល់ រឹងបានឆាប់រហ័សផងដែរ។

**ខ.ឃ្លាខណ្ឌទី៣៖ រោងចក្រដុតសម្រាម**

ដោយសារតែមិនមានដីធំទូលាយច្រើននៅប្រទេសជប៉ុន ដូច្នេះហើយការកាត់បន្ថយបរិមាណ សំណល់រឹង និងការបោះចោលសំណល់រឹងឱ្យបានឆាប់រហ័សបានក្លាយជាកត្តាចាំបាច់បំផុត។ ទោះជាយ៉ាង ណាក៏ដោយ បញ្ហានគរូបនីយកម្ម និងការរស់នៅរបស់ប្រជាជនបានបង្កការលំបាក់ដើម្បីសម្រេចនូវគម្រោង មួយនេះ។ ប្រទេសជប៉ុនមិនមានដីគ្រប់គ្រាន់សម្រាប់សាងសង់ទីលានចាក់សម្រាមនោះទេ វិធីសាស្ត្រដែលល្អ បំផុតសម្រាប់ប្រទេសជប៉ុនក្នុងការបោះចោល ឬបំផ្លាញសំណល់រឹង គឺឡដុតសម្រាម។

[28] ប្រទេសជប៉ុនបានបង្កើតកាកសំណល់ណៅទីលានចាក់សម្រាមចំនួន ៤៣,១៧ លានតោនក្នុងឆ្នាំ២០១៦ នេះ។

ចាប់ពីឆ្នាំ ១៩៦០ ប្រទេសជប៉ុនបានចាប់ផ្តើមបំផ្លាញសំណល់រឹងដោយឡដុតសម្រាម ហើយសព្វថ្ងៃនេះ ប្រទេសជប៉ុនជាកន្លែងដែលមានឡដុតសម្រាមឈានមុខគេក្នុងពិភពលោក។ មានឡដុតប្រមាណជាង ១.៣៧៤ កន្លែងកំពុងប្រតិបត្តិការក្នុងប្រទេសជប៉ុនក្នុងឆ្នាំ ២០០៦ ។ ជាមួយនឹងរោងចក្រដែលមានបច្ចេកទេសខ្ពស់របស់ជប៉ុន ការដុតសម្រាមបានទទួលការជឿទុកចិត្តថាមានសុវត្ថិភាព និងមានបច្ចេកទេសត្រឹមត្រូវ ហើយនៅពេលគ្រោងសាងសងកន្លែងបែបនេះ ការប្រាស្រ័យទាក់ទងជាមួយអ្នកស្រុកនៅក្នុងតំបន់នោះគឺមានភាពរលូន ដែលធ្វើឱ្យមានភាពរីកចម្រើនយ៉ាងឆាប់រហ័សក្នុងផែនការសាងសង់កន្លែងរោងចក្រឡដុតសម្រាមនៅក្នុងទីក្រុង និងក្នុងតំបន់លំនៅឋាន។

នៅប្រទេសជប៉ុនមានឡដុតសម្រាមដោយប្រើវិធីផ្សេងៗដែលគេឱ្យឈ្មោះដូចជា stoker furnaces, fluidized bed furnaces, និង gasification fusion resource furnaces ។ មានរោងចក្រដុតសម្រាមក្នុងទីក្រុងមួយចំនួន ទាំងតូចទាំងធំ បាននឹងកំពុងដំណើរដោយអនុលោមតាមគោលនយោបាយដែលបានអនុវត្តនៅក្នុងប្រទេសជប៉ុន។ ខណៈដែលបច្ចេកវិទ្យាជាច្រើនត្រូវបានបង្កើតឡើងរួមទាំងបច្ចេកវិទ្យាដើម្បីកាត់បន្ថយការបំភាយឌីអុកស៊ីត ការដកឧស្ម័នអាស៊ីត និងកែច្នៃផេះដែលបានដុតឡើងវិញ ដោយប្រភេទឡដុត stoker furnaces ត្រូវបានគេមើលឃើញថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ បច្ចេកទេសដ៏មានប្រសិទ្ធិភាពរបស់ឡដុត stoker furnaces គឺវាបានធ្វើឱ្យមានថាមពលអគ្គិសនី ដែលបានមកពីការដុតសំណល់រឹង ហើយវាបានក្លាយជាវិធានការដល់មានប្រសិទ្ធិភាពដើម្បីប្រឆាំងនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់។ ឡដុតប្រភេទ stoker furnaces មានប្រវត្តិយូរបំផុតនៅក្នុងប្រទេសជប៉ុន និងការប្រើប្រាស់វិធីសាស្ត្រនៃការបំផ្លាញសំណល់រឹងដែលរីកចម្រើនខ្លាំងបំផុត។ សព្វថ្ងៃនេះឡដុតភាគច្រើនប្រើប្រព័ន្ធនេះ ហើយក្រុមហ៊ុន Takuma (តាក់គឹម៉ា) បានផលិតវាច្រើនជាងក្រុមហ៊ុនផលិតដទៃទៀតនៅក្នុងប្រទេសជប៉ុន។

**វាក្យខណ្ឌទី៤៖ ការកែច្នៃឡើងវិញ**

ដើម្បីគាំទ្រគំនិតក្នុងការផ្តួចផ្តើមយុទ្ធសាស្ត្រ (៣R) ជប៉ុនមានច្បាប់ និងកម្មវិធីវិស័យឯកជនមួយចំនួនត្រូវបានណែនាំដើម្បីលើកកម្ពស់ការកែឆ្នៃផលិតផលជាច្រើន ។ ចំពោះក្នុងការគ្រប់គ្រងសំណល់រឹងវិញ មានច្បាប់ចម្បងចំនួន ៣ ដែលជះឥទ្ធិពលដល់តម្រូវការសម្រាប់បច្ចេកវិទ្យាកែឆ្នៃឡើងវិញនេះ។

• **ច្បាប់ស្តីពីការកែឆ្នៃសំណល់រឹងគ្រឿងប្រើប្រាស់ក្នុងផ្ទះ៖** ច្បាប់នេះបានជំរុញការអភិវឌ្ឍបច្ចេកវិទ្យាកែឆ្នៃសម្រាប់សំណល់រឹងអេឡិចត្រូនិច និងបានចូលជាធរមានក្នុងឆ្នាំ២០០១។ ច្បាប់នេះតម្រូវឱ្យអ្នកប្រើប្រាស់ធ្វើការបង់ថ្លៃសេវាសម្រាប់ការប្រមូល និងកែឆ្នាំឡើងវិញនូវផលិតផលដូចជា ទូរទឹកកក,ម៉ាស៊ីនត្រជាក់,ទូរទស្សន៍ និងម៉ាស៊ីនបោកគក់ជាដើម។ រដ្ឋាភិបាលបានកំណត់អត្រាកែច្នៃឡើងវិញសម្រាប់មនុស្សម្នាក់ៗ ក្នុងចន្លោះពី ៥០% ទៅ៦០%។ ក្រុមហ៊ុនផលិតទាំងអស់រួមទាំងក្រុមហ៊ុនអេឡិចត្រូនិកធំៗដូចជា Fujitsu, Hitachi, Panasonic,

Sanyo, Sharp, Sony និង Toshiba បានសហការក្នុងប្រតិបត្តិការរោងចក្រកែច្នៃចំនួន ២៧រោងចក្រនៅទូទាំងប្រទេសដែលក្នុងនោះជិត ១២ លានគ្រឿងត្រូវបានប្រមូលនៅឆ្នាំ ២០០៦។

• **ច្បាប់ស្តីពីការកែឆ្នៃសំណល់អាហារ៖** សំណល់រឹងអាហារមានប្រមាណ ៣០% នៃបរិមាណសំណល់រឹងសរុបនៅក្នុងប្រទេសជប៉ុន។ បន្ទាប់ពីច្បាប់កែឆ្នៃសំណល់រឹងអាហារត្រូវបានអនុម័តនៅឆ្នាំ ២០០០ គម្រោងកែច្នៃជាច្រើនត្រូវបានដាក់ឱ្យដំណើរការ។ មជ្ឈមណ្ឌលកែច្នៃសំណល់រឹងផ្ទះបាយ Sapporo បានកែឆ្នៃសំណល់រឹងអាហារចំនួន ៥០ តោន ដែលប្រមូលបានជារៀងរាល់ថ្ងៃពីសាលារៀនក្នុងស្រុកចំនួន ១៨៨ និងមន្ទីរពេទ្យផងដែរ។ រីឯក្រុមហ៊ុន Mitsui Zosen ដែលជាក្រុមហ៊ុនផលិតចំណីគោបានកែឆ្នាំកាកសំណល់អារហារ ១០តោនក្នុងមួយថ្ងៃសម្រាប់ដំណើរក្រុមហ៊ុនរបស់ខ្លួន។ មិនតែប៉ុណ្ណោះ គេបានសាងសង់រោងចក្រសាកល្បងមួយនៅក្រុង Kitakyushu Eco-Town ដែលមានសមត្ថភាពផលិតអេតាណុល ៤០០លីត្រក្នុងមួយថ្ងៃពីសំណល់រឹងអាហារ ១០ តោន។

• **ច្បាប់ស្តីពីការកែឆ្នៃសំណល់រឹងជាសម្ភារៈស្តុកទុក និងវេចខ្ចប់៖** ដោយមូលហេតុសំណល់រឹងដែលជាប្រភេទសម្រាប់ទុកដាក់ និងវេចខ្ចប់មានប្រមាណ ៦០%នៃបរិមាណសំណល់រឹងសរុបនៅប្រទេសជប៉ុន។ ដូច្នេះហើយ ទើបប្រទេសជប៉ុនបានអនុម័ត ច្បាប់កែឆ្នៃសំណល់រឹងដែលជាប្រភេទសម្រាប់ទុកដាក់ និងវេចខ្ចប់នៅឆ្នាំ ១៩៩៥ ដើម្បីកាត់បន្ថយសំណល់រឹងទាំងនេះដូចជា ក្រដាសកាតុង, ប្លាស្ទិក និងដបជាដើម ដោយយកសំណល់រឹងទាំងនេះទៅធ្វើការកែឆ្នៃទៅជាធនធានមានប្រយោជន៍ផ្សេងៗវិញ។ ក្រុមហ៊ុនផលិតឧបករណ៍កែឆ្នៃក្នុងស្រុករួមមាន ក្រុមហ៊ុនឧស្សាហកម្ម Fuji Heavy, Hitachi Zosen, IHI, JFE Environmental Solutions and Rasa និងក្រុមហ៊ុនតូចៗផ្សេងទៀត ក៏បានកំណត់គោលដៅក្នុងការកែឆ្នៃសំណល់រឹងទាំងនេះផងដែរ។ អត្រានៃការកែឆ្នៃ ប្លាស្ទិកនៅប្រទេសជប៉ុនមានរហូតដល់ ៨៤% ដែលវាជាអត្រាដែលគួរជាទីមោទនភាពសម្រាប់ពួកគេ ហើយកំប៉ុងប្លាស្ទិកត្រូវបានគេកែឆ្នៃស្ទើរតែទាំងអស់ទូទាំងប្រទេស។

## កថាខណ្ឌទី៣៖ ក្របខ័ណ្ឌគតិយុត្តនៃការគ្រប់គ្រងសំណល់រឹងនៅជប៉ុន

ដើម្បីដោះស្រាយបញ្ហាសំណល់រឹងដែលបានវិវត្តន៍ជារៀងរាល់ឆ្នាំ និងក្លាយជាបញ្ហាប្រឈមខ្លាំងកន្លងមករដ្ឋាភិបាលជប៉ុនបានអនុម័តច្បាប់ និងធ្វើវិសោធនកម្មច្បាប់សំខាន់ៗជាច្រើនដោយបានសហការជាមួយអាជ្ញាធរក្នុងតំបន់, ប្រតិបត្តិករឯកជន, និងប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវក្នុងការប្រើប្រាស់ធនធានក៏ដូចជាការអភិវឌ្ឍការកែឆ្នៃ និងប្រើប្រាស់ឡើងវិញនូវធនធានសម្ភារៈផ្សេងៗដែរ.។ ខាងក្រោមនេះ យើងនឹងបង្ហាញពីបទបញ្ញត្តិ ក៏ដូចជាច្បាប់សំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងការបោះចោលសំណល់រឹង,ការកែឆ្នៃ និងប្រើប្រាស់ឡើងវិញ ព្រមទាំងតួនាទី ឬទំនួលខុសត្រូវរបស់តួអង្គដែលពាក់ព័ន្ធទាំងឡាយ ដើម្បីធ្វើឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវក្នុងប្រទេសជប៉ុន។

## វាក្យខណ្ឌទី១៖ ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង

ដើម្បីដោះស្រាយបញ្ហាការគ្រប់គ្រងសំណល់រឹង ដែលបានវិវត្តន៍ក្នុងរយៈពេលច្រើនឆ្នាំកន្លងមក រដ្ឋាភិបាលជប៉ុនបានអនុម័ត និងធ្វើវិសោធនកម្មច្បាប់ ព្រមទាំងធ្វើការដោយសហការជាមួយរដ្ឋាភិបាលក្នុងតំបន់ ប្រតិបត្តិករឯកជន និងប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ និងការប្រើប្រាស់ធនធានឱ្យល្អប្រសើរ ក៏ដូចជាការអភិវឌ្ឍថេរនៃការកែច្នៃសម្ភារៈឱ្យមានសុវត្ថិភាពផងដែរ។ ខាងក្រោមនេះគឺជាច្បាប់ ឬបទបញ្ញត្តិសំខាន់ៗក្នុងការគ្រប់គ្រងសំណល់រឹងក្នុងប្រទេសជប៉ុន៖

- Waste Sanitation Law (1900) ច្បាប់ស្តីពីអនាម័យចំពោះសំណល់រឹង (ឆ្នាំ១៩០០)
- Public Cleansing Act (1954) ច្បាប់ស្តីពីការសំអាតសាធារណៈ (ឆ្នាំ១៩៥៤)
- Waste Management and Public Cleansing Law (1970) ច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹង និងការសំអាតសាធារណៈ (ឆ្នាំ១៩៧០) វិសោធនកម្ម (ឆ្នាំ១៩៧៦ , ១៩៩១ , ១៩៩៧)
- Basic Environment Law (1993) ច្បាប់ស្តីពីមូលដ្ឋាននៃបរិស្ថាន (ឆ្នាំ១៩៩៣)
- Containers and Packaging Recycling Law (1995) ច្បាប់ស្តីពីការកែច្នៃសំណល់រឹងដែលជារបស់របរសម្រាប់ស្តុកទុក និងវេចខ្ចប់ (ឆ្នាំ១៩៩៥)
- Home Electric Appliances Recycling Law (1998) ច្បាប់ស្តីពីការកែច្នៃសំណល់រឹងជាគ្រឿងប្រើប្រាស់ក្នុងផ្ទះ (ឆ្នាំ១៩៩៨)
- Dioxins Control Law (1999) ច្បាប់ស្តីពីការត្រួតពិនិត្យឧស្ម័នឌីអុកស៊ីត (ឆ្នាំ១៩៩៩)
- Basic Law for Establishing a Sound Material-Cycle Society (2000) មូលដ្ឋានច្បាប់សម្រាប់ការបង្កើតវដ្តនៃការប្រើប្រាស់ធនធានសម្ភារៈឱ្យត្រឹមត្រូវ (ឆ្នាំ២០០០)
- Construction Material Recycling Law (2000) ច្បាប់ស្តីពីការកែច្នៃសំណល់រឹងសំភារៈសំណង់ (ឆ្នាំ២០០០)
- Food Waste Recycling Law (2000) ច្បាប់ស្តីពីការកែច្នៃសំណល់រឹងអាហារ (ឆ្នាំ២០០០)
- End-of-Life Vehicles Recycling Law (2002) ច្បាប់ស្តីពីការកែច្នៃរថយន្តដែលហួសកំណត់ (ឆ្នាំ២០០២)
- Amendment to Waste Management and Public Cleansing Law (2003-06, 10, 15, 17) វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹង និងការសំអាតសាធារណៈ (ឆ្នាំ២០០៣ , ០៦ , ១០, ១៥ , ១៧ )
- Small Home Electric Appliances Recycling Law (2013) ច្បាប់ស្តីពីការកែច្នៃសំណល់រឹងជាគ្រឿងប្រើប្រាស់ក្នុងផ្ទះខ្នាតតូច (២០១៣)។

## ឃាត្យខណ្ឌទី២៖ តួនាទីនិងទំនួលខុសត្រូវរបស់អង្គភាព និងអ្នកពាក់ព័ន្ធនានា

ដើម្បីបង្កើតកម្មវិធីគោលនយោបាយស្តីពី sound material-cycle society ឱ្យបានល្អប្រសើរ វាចាំបាច់ណាស់ត្រូវតែមានអង្គភាពផ្សេងៗចូលរួមដូចជា រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(មូលដ្ឋាន), ប្រតិបត្តិករអាជីវកម្ម,អ្នកប្រើប្រាស់ ក្នុងការចូលរួមទទួលស្គាល់ពីតួនាទីរបស់ពួកគេរៀងៗខ្លួនដោយអនុលោមតាមច្បាប់ស្តីពីមូលដ្ឋាននៃការកែឆ្នៃ ក្នុងបញ្ញត្តិស្តីពីការលើកកម្ពស់យុទ្ធសាស្ត្រ (៣R)។ វាមានសារៈសំខាន់ណាស់ដែលអង្គភាពនីមួយៗអនុវត្តន៍ទំនួលខុសត្រូវរបស់ខ្លួនសម្រាប់ការគ្រប់គ្រងសំណល់រឹង និងសហការគ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធិភាពដើម្បីបង្កើត និងថែរក្សាប្រព័ន្ធនៃការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ។ ដើម្បីឱ្យបានសម្រេចគោលនយោបាយនេះ ច្បាប់ស្តីពីការគ្រប់គ្រងកាកសំណល់រឹង បានកំណត់យ៉ាងច្បាស់ពីតួនាទី និងទំនួលខុសត្រូវរបស់ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ប្រតិបត្តិករអាជីវកម្ម និងអ្នកប្រើប្រាស់ផ្សេងៗក្នុងការគ្រប់គ្រងសំណល់រឹងរបស់ពួកគេ។ ខាងក្រោមនេះគឺជា ទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់ជាតិ, ថ្នាក់មូលដ្ឋាន,ប្រតិបត្តិករអាជីវកម្ម អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដែលបង្កើតសំណល់រឹង។

### ចំណុច (ក)៖ ច្បាប់គ្រប់គ្រងសំណល់រឹង និង ការសម្អាតសាធារណៈ

ច្បាប់នេះត្រូវបានអនុម័តក្នុងឆ្នាំ ១៩៧០ និងធ្វើវិសោធនកម្មជាបន្តបន្ទាប់។ ច្បាប់នេះមានគោលបំណងការពារបរិស្ថានរស់នៅ និងលើកកម្ពស់សុខភាពសាធារណៈតាមរយៈការរឹតបន្តឹងការបញ្ចេញសំណល់រឹង,ការបែងចែក និងរៀបចំទុកដាក់សំណល់រឹង,ការប្រមូល និងដឹកជញ្ជូន,ការកែច្នៃ,ការបោះចោលសំណល់រឹង និងការថែរក្សាបរិស្ថានក្នុងការរស់នៅស្អាត។

- **រដ្ឋាភិបាលថ្នាក់ជាតិ៖** ដើម្បីជួយអង្គភាពដទៃទៀតក្នុងការអនុវត្តការទទួលខុសត្រូវរបស់ពួកគេឱ្យបានត្រឹមត្រូវ រដ្ឋាភិបាលជាតិត្រូវរៀបចំ និងអនុវត្តយុទ្ធសាស្ត្រមូលដ្ឋានឱ្យបានទូលំទូលាយរួមមាន ការប្រមូល,វិភាគព័ត៌មានស្តីពីសំណល់រឹង,អនុម័តច្បាប់និងបទប្បញ្ញត្តិ, ជំរុញការអភិវឌ្ឍបច្ចេកវិទ្យា, ផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យា និងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលខេត្ត ក្រុង។ តួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិរួមមាន៖ ការបង្កើតគោលនយោបាយមូលដ្ឋាន, ការបង្កើតស្តង់ដារក្នុងការគ្រប់គ្រងសំណល់រឹង, ការបង្កើតស្តង់ដារទីតាំងអគារ, ការបង្កើតស្តង់ដារការងារនៅខាងក្រៅ, ការអភិវឌ្ឍបច្ចេកវិទ្យាក្នុងការប្រមូលព័ត៌មាន។ ល។
- **រដ្ឋបាលខេត្ត៖** រដ្ឋបាលខេត្តនានាត្រូវផ្តល់នូវការគាំទ្រផ្នែកបច្ចេកវិទ្យាចាំបាច់សម្រាប់រដ្ឋបាលក្រុង (ទទួលខុសត្រូវលើការគ្រប់គ្រងសំណល់រឹងទីក្រុង) ដើម្បីជួយពួកគេក្នុងការបំពេញភារកិច្ចរបស់ពួកគេឱ្យបានគ្រប់គ្រាន់។ ទន្ទឹមនឹងនេះដែររដ្ឋបាលខេត្តនានាត្រូវប្រមូលព័ត៌មានអំពីវិធីគ្រប់គ្រងសំណល់រឹងឧស្សាហកម្មនៅក្នុងតំបន់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ពួកគេ,បង្កើតផែនការគ្រប់គ្រងសំណល់រឹង, ផ្តល់ការណែនាំនិងការត្រួតពិនិត្យដើម្បីធានាបាននូវការគ្រប់គ្រងសមស្របនៃសំណល់រឹងឧស្សាហកម្ម។ លើសពីនេះទៀតរដ្ឋបាលខេត្តក៏ត្រូវផ្តល់សិទ្ធិ និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មរបស់ប្រតិបត្តិករសម្រាប់កែច្នៃសំណល់រឹងឧស្សាហកម្ម

ផងដែរ។ តួនាទីរបស់រដ្ឋបាលខេត្តរួមមាន៖ ការបង្កើតផែនការគ្រប់គ្រងសំណល់រឹង,ផ្តល់ការអនុញ្ញាតសម្រាប់ការសាងសង់កន្លែងគ្រប់គ្រងសំណល់រឹង(ការទទួលយករបាយការណ៍ ស្តីពីការសាងសង់), ផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និង បង្កើតបទបញ្ជាផ្ទៃក្នុងផ្នែករដ្ឋបាល។ ល។

- **រដ្ឋបាលក្រុង៖** រដ្ឋបាលក្រុងទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង ឬតំបន់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំផែនការព្រមទាំងអនុវត្តផែនការគ្រប់គ្រងសំណល់រឹងផងដែរ។ សាលាក្រុងក៏លើកកម្ពស់សកម្មភាពនៃការគ្រប់គ្រងសំណល់រឹងផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយបរិមាណសំណល់រឹងទីក្រុង ឬក្នុងតំបន់របស់ពួកគេក៏ដូចជាអនុវត្តវិធានការដែលត្រូវការសម្រាប់ការគ្រប់គ្រងឱ្យបានត្រឹមត្រូវនៃសំណល់រឹងទីក្រុង។ តួនាទីរដ្ឋបាលក្រុងរួមមាន៖ រៀបចំផែនការក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង, ប្រតិបត្តិការក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង។ល។

- **ប្រតិបត្តិករអាជីវកម្ម និងអ្នកស្រុក៖** អ្នកស្រុកដែលបង្កើតសំណល់រឹងត្រូវទទួលខុសត្រូវក្នុងការលើកកម្ពស់ការកែច្នៃសំណល់រឹងដោយប្រើប្រាស់ផលិតផលកែច្នៃ និងកាត់បន្ថយការចោល ឬរៀបចំសំណល់រឹងដែលត្រូវបោះចោល។ ពួកគេត្រូវធ្វើការសហការជាមួយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងការខិតខំកាត់បន្ថយ និងគ្រប់គ្រងសំរាមឱ្យបានត្រឹមត្រូវ។ រីឯប្រតិបត្តិករអាជីវកម្មវិញត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងសំណល់រឹងឧស្សាហកម្មដែលបានមកពីសកម្មភាពក្រុមហ៊ុនរបស់ពួកគេ។ ពួកគេត្រូវធ្វើសកម្មភាពដើម្បីកាត់បន្ថយសំណល់រឹងតាមរយៈការកែច្នៃ និងអនុវត្តវិធានការដូចជា ប្រតិបត្តិការគ្រប់គ្រងសំណល់រឹងតាមរយៈការងារដើម្បីធានាការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ។ ប្រតិបត្តិករអាជីវកម្មក៏ត្រូវរៀបចំផលិតផល និងធុងសម្រាមរបស់ពួកគេ ដែលជាការគ្រប់គ្រងយ៉ាងងាយស្រួលនៅពេលដែលត្រូវបានយកទៅកែច្នៃ និងផ្តល់ព័ត៌មានអំពីវិធីគ្រប់គ្រងរបស់ពួកគេផងដែរ។ តួនាទីរបស់ប្រតិបត្តិករអាជីវកម្មនិងអ្នកស្រុករួមមាន៖ ការគ្រប់គ្រងសំណល់រឹងផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ,សហប្រតិបត្តិការជាមួយរដ្ឋបាលក្រុង, ការគ្រប់គ្រងសំណល់រឹងស្របតាមតំបន់នីមួយៗ,ការកាត់បន្ថយ,ការកែច្នៃ និងប្រើប្រាស់ឡើងវិញនៃសំណល់រឹង, អនុលោមតាមបទដ្ឋាននៃបញ្ញត្តិស្តីពី ការបង្កើតស្តង់ដារការងារនៅខាងក្រៅរបស់រដ្ឋាភិបាលថ្នាក់ជាតិ, បង់ថ្លៃសេវាក្នុងការបញ្ចេញសំណល់រឹង, រៀបចំផែនការកាត់បន្ថយសំណល់រឹងដោយប្រតិបត្តិករអាជីវកម្ម។ល។

### ចំណុច (ខ)៖ ច្បាប់ស្តីពីការកែច្នៃរបស់របរជាប្រភេទស្តុកទុក និងវេចខ្ចប់

ច្បាប់នេះអនុម័តនៅឆ្នាំ ១៩៩៥ និងសម្រាប់គ្រប់គ្រងប្រភេទសំណល់រឹងដូចជា៖ កំប៉ុងដែក, កំប៉ុងអាលុយមីញ៉ូម, កញ្ចក់, ដប, ក្រដាសកាតុង, ប្រអប់ក្រដាស,ដបជ័រ,របស់របរសម្រាប់វេចខ្ចប់ផលិតពីក្រដាស ឬប្លាស្ទិក។ ខាងក្រោមនេះគឺជាទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹង៖

- **អ្នកប្រើប្រាស់៖** អ្នកប្រើប្រាស់ត្រូវធ្វើការបែងចែក និងបោះចោលសំណល់រឹងរបស់ពួកគេដោយប្រយ័ត្នឱ្យស្របតាមស្តង់ដារនៃការប្រមូល និងធុងសម្រាមដែលបានរៀបចំឡើងដោយរដ្ឋបាលក្រុង។ ពួកគេក៏ត្រូវកាត់

បន្ថយការបង្កើតសំណល់រឹងដោយត្រូវប្រើថង់ដើរទិញឥវ៉ាន់ផ្ទាល់ខ្លួនរបស់ពួកគេជំនួសថង់ប្លាស្ទិក ឬរបស់របរសម្រាប់វេចខ្ចប់ដែលទទួលបានពីហាង។

- **រដ្ឋបាលក្រុង៖** រដ្ឋបាលក្រុងត្រូវរៀបចំ និងប្រមូលសំណល់រឹងប្រភេទវេចខ្ចប់ដែលបោះចោលដោយគ្រួសារក្នុងសហគមន៍ហើយប្រគល់ទៅឱ្យប្រតិបត្តិករកែឆ្នៃសំណល់រឹងទាំងនោះ។ មិនតែប៉ុណ្ណោះ រដ្ឋបាលក្រុងនានាក៏ត្រូវសហការជាមួយប្រតិបត្តិករអាជីវកម្ម និងអ្នកស្រុកដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីឱ្យពួកគេធ្វើការកាត់បន្ថយការចោលសំណល់រឹងប្រភេទវេចខ្ចប់ទាំងនោះផងដែរ។
- **ប្រតិបត្តិករអាជីវកម្ម៖** ប្រតិបត្តិករអាជីវកម្មត្រូវមានកាតព្វកិច្ចក្នុងការកែច្នៃសំណល់រឹងប្រភេទវេចខ្ចប់ដែលខ្លួនបានផលិត ឬនាំចូល ឬដែលត្រូវបានប្រើក្នុងប្រតិបត្តិការអាជីវកម្មរបស់ពួកខ្លួន។ តាមពិតប្រតិបត្តិករអាជីវកម្ម ត្រូវរកប្រភពក្នុងការកែឆ្នៃសំណល់រឹងប្រភេទវេខ្ចប់របស់ពួកគេដែលបានកំណត់ដោយច្បាប់ Containers and Packaging Recycling Act និងត្រូវចំណាយលើការកែច្នៃឡើងវិញដើម្បីបំពេញកាតព្វកិច្ចរបស់ពួកគេ។ ក្រៅពីកែឆ្នៃសំណល់រឹង ប្រតិបត្តិករអាជីវកម្មក៏ត្រូវកាត់បន្ថយការផលិតសំណល់រឹងប្រភេទវេចខ្ចប់ផងដែរ តាមរយៈការគិតថ្លៃលើសេវាសម្រាប់ថង់ប្លាស្ទិកដាក់ឥវ៉ាន់ ឬរបស់របរវេចខ្ចប់ផ្សេងទៀតទាំងនៅពេលដែលផ្ដល់ឱ្យអតិថិជន និងនៅពេលដែលទទួលបានពីការកែឆ្នៃឡើងវិញ។

**ចំណុច (គ)៖ ច្បាប់កែឆ្នៃគ្រឿងប្រើប្រាស់ក្នុងផ្ទះ**

ច្បាប់នេះអនុម័តក្នុងឆ្នាំ១៩៩៨ និងសម្រាប់គ្រប់គ្រងប្រភេទសំណល់រឹងដូចជា៖ ទូរទស្សន៍, ម៉ាស៊ីនត្រជាក់, ទូរទឹកកក ឬទូរក្លាសេផ្សេងៗទៀត, ម៉ាស៊ីនបោកគក់ និងម៉ាស៊ីនសម្ងួត។ល។ ខាងក្រោមនេះគឺជាទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹង៖

- **អ្នកប្រើប្រាស់៖** អ្នកប្រើប្រាស់ (អ្នកបង្កើតសំណល់រឹង) ដែលចង់បោះចោលឧបករណ៍ប្រើប្រាស់ក្នុងផ្ទះរបស់ខ្លួន ត្រូវតែប្រគល់សម្ភារៈទាំងនោះទៅឱ្យអ្នកលក់រាយ ហើយត្រូវចំណាយលើថ្លៃដឹកជញ្ជូន និងការកែឆ្នៃសំណល់រឹងទាំងនោះផងដែរ។
- **អ្នកលក់រាយគ្រឿងប្រើប្រាស់ក្នុងផ្ទះ៖** អ្នកលក់រាយដែលបានទទួលសំណល់រឹងប្រើប្រាស់ក្នុងផ្ទះដែលបានមកពីអ្នកប្រើប្រាស់បោះចោលនោះ ត្រូវតែយកសំណល់រឹងទាំងនោះទៅប្រគល់ទៅឱ្យក្រុមហ៊ុនដែលផលិតសំណល់រឹងទាំងនោះតាមប្រភេទនីមួយៗ។
- **ក្រុមហ៊ុនផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ៖** ក្រុមហ៊ុនផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះត្រូវធ្វើការទទួលសំណល់រឹងជាសម្ភារៈប្រើប្រាស់ក្នុងផ្ទះដែលបានមកពីអ្នកលក់រាយ ហើយយកសំណល់រឹងទាំងនោះទៅធ្វើការកែឆ្នៃ ឬផលិតឡើងវិញ ព្រមទាំងធ្វើការបំផ្លាញសារធាតុពុលផងដែរដូចករណី ម៉ាស៊ីនត្រជាក់ ឬទូរទឹកកកជាដើម។

**ចំណុច (ឃ)៖ ច្បាប់ស្តីពីការកែឆ្នៃសំណល់អាហារ**

ច្បាប់នេះអនុម័តក្នុងឆ្នាំ២០០០ និងសម្រាប់គ្រប់គ្រងប្រភេទសំណល់រឹងដែលសំដៅទៅលើ៖ ប្រភេទកាកសំណល់អារហារទាំងឡាយណាដែលមិនអាចធ្វើការបរិភោគបាន ឬ ប្រភេទអាហារហួសថ្ងៃកំណត់ ឬ ប្រភេទអាហារដែលនៅសល់បន្ទាប់ពីបរិភោគរួច។ ខាងក្រោមនេះគឺជាទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹង៖

- **ប្រតិបត្តិករអាជីវកម្មដែលទាក់ទងនឹងអាហារ៖** ពួកគេទាំងនេះរួមមាន អ្នកផលិតអាហារ និងអ្នកកែច្នៃអាហារ,អ្នកលក់ដុំ និងអ្នកលក់រាយអាហារ,ភោជនីយដ្ឋាននិងអ្នកធ្វើម្ហូបអាហារ។ ពួកគេទាំងនេះត្រូវតែ៖ កាត់បន្ថយការផលិតសំណល់រឹងអាហារ, ធ្វើការកែឆ្នៃសំណល់រឹងអាហារដើម្បីឱ្យក្លាយទៅជាប្រភេទធនធានអាហារដែលអាចយកទៅបរិភោគឡើងវិញបាន, ធ្វើការប្រើប្រាស់នូវប្រភេទសំណល់រឹងអាហារណាដែលមិនអាចកែឆ្នៃឡើងវិញបាន និងចាត់វិធានការឱ្យបានតឹងរឹងក្នុងការកាត់បន្ថយសំណល់រឹងអាហារ។
- **អ្នកប្រើប្រាស់៖** អ្នកប្រើប្រាស់ត្រូវព្យាយាមក្នុងការកាត់បន្ថយសំណល់រឹងអាហារតាមរយៈការធ្វើឱ្យប្រសើរចំពោះការបញ្ជាទិញអាហារ ឬការចម្អិនអាហារ(កុំឱ្យមានការខ្ជះខ្ជាយអាហារ) និងជំរុញឱ្យមានការប្រើប្រាស់នូវសំណល់រឹងអាហារដែលបានកែឆ្នៃឡើងវិញ។

**ចំណុច (ខ)៖ ច្បាប់ស្តីពីការកែឆ្នៃសំណល់សំណង់**

ច្បាប់នេះអនុម័តក្នុងឆ្នាំ ២០០០ និងសម្រាប់គ្រប់គ្រងប្រភេទសម្រាមដូចជា៖ បេតុង, សំភារៈសំណង់ផ្សំពីបេតុងនិងដែក, ឈើ, កៅស៊ូ។ល។ ខាងក្រោមនេះគឺជានីតិវិធីនៃការរុះរើសំណង់,ការកែឆ្នៃឡើងវិញ និងប្រតិបត្តិការផ្សេងៗ៖

- **(១)ការពន្យល់៖** អ្នកម៉ៅការត្រូវប្រាប់ជូនភាគីម្ចាស់សំណង់ឱ្យរៀបចំនូវឯកសារជាលាយលក្ខណ៍អក្សរ ដើម្បីពន្យល់អំពីផែនការសម្រាប់ការវាយកម្ទេចសំណង់ចោល និងប្រតិបត្តិការផ្សេងៗ។
- **(២)កិច្ចសន្យា៖** វាចាំបាច់ត្រូវបញ្ជាក់អំពីវិធីសាស្ត្រដែលត្រូវបានប្រើសម្រាប់ការវាយកម្ទេចសំណង់ចោលនៅក្នុងកិច្ចសន្យាដែលបានបញ្ចប់រវាងភាគីម្ចាស់សំណង់ និងអ្នកម៉ៅការ។
- **(៣)ការរាយការណ៍បឋម៖** ភាគីម្ចាស់សំណង់ត្រូវរៀបចំផែនការ ឬឯកសារសម្រាប់ប្រើប្រាស់ក្នុងការរុះរើសំណង់ និងប្រតិបត្តិការផ្សេងទៀត ដើម្បីបញ្ជូនរបាយការណ៍ទាំងនោះទៅកាន់រដ្ឋបាលខេត្តដែលពាក់ព័ន្ធជាមុន។
- **(៤)ការបញ្ជាក់សារជាថ្មី៖** នៅពេលដែលការងារត្រូវបានប្រគល់ដល់អ្នកម៉ៅបន្ត នោះអ្នកម៉ៅការដំបូងត្រូវធ្វើការបញ្ជាក់ដល់អ្នកម៉ៅការបន្តអំពីអ្វីដែលជាការចាំបាច់ដែលត្រូវរាយការណ៍ជូនទៅរដ្ឋបាលខេត្ត។
- **(5)កិច្ចសន្យា៖** វាចាំបាច់ត្រូវបញ្ជាក់អំពីវិធីសាស្ត្រដែលត្រូវបានប្រើសម្រាប់ការរុះរើសំណង់ក្នុងកិច្ចសន្យាដែលបានបញ្ចប់រវាងអ្នកម៉ៅការដំបូង និងអ្នកម៉ៅការបន្ត។

- **(៦)ប្រតិបត្តិការរុះរើ៖** ការវាយកម្ទេចចោល, ការរៀបចំកែច្នៃឡើងវិញ និងប្រតិបត្តិការផ្សេងៗទៀត ដោយធ្វើការបិទស្លាកសញ្ញានៅការដ្ឋានសំណង់ និងធ្វើការគ្រប់គ្រងសំណង់ដោយក្រុមអ្នកវិស្វករ។
- **(៧)ការរាយការណ៍៖** នៅពេលបានបញ្ចប់ការរុះរើសំណង់, ការកែច្នៃឡើងវិញ និងប្រតិបត្តិការផ្សេងទៀត អ្នកម៉ៅការដំបូងត្រូវប្រាប់ឱ្យភាគីម្ចាស់សំណង់រៀបចំនូវឯកសារជាលាយលក្ខណ៍អក្សរអំពីការបញ្ចប់ប្រតិបត្តិការរបស់ខ្លួន ហើយត្រូវរក្សាទុកនូវកំណត់ត្រាដែលទាក់ទងនឹងរបៀបនៃការរុះរើ, ការកែច្នៃឡើងវិញ និងប្រតិបត្តិការផ្សេងៗទាំងនេះ។

**ចំណុច (ច)៖ ច្បាប់ស្តីពីការកែឆ្នៃរថយន្តដែលហួសកំណត់**

ច្បាប់នេះអនុម័តក្នុងឆ្នាំ២០០២ និងសម្រាប់គ្រប់គ្រងលើរងយន្តដែលត្រូវបានគេបោះចោល។ ខាងក្រោមនេះគឺជានីតិវិធីនៃការចំណាយលើការកែឆ្នៃរថយន្ត និង ដំណាក់កាលនៃការបោះចោលរថយន្ត៖

- **ម្ចាស់រថយន្ត៖** ម្ចាស់រថយន្តត្រូវបង់ថ្លៃកែឆ្នៃនៅពេលទិញរថយន្ត (ដោយដាក់ប្រាក់ចូលក្នុងគណនេយ្យនៃបេឡាគ្រប់គ្រងមូលនិធិរបស់ក្រុមហ៊ុនសាជីវកម្ម[29]) និងប្រគល់រថយន្តទៅឱ្យប្រតិបត្តិករអាជីវកម្ម ឬអ្នកកែឆ្នៃ (អ្នកលក់ឡាន) នៅពេលរថយន្តនោះបោះចោលឈប់ប្រើប្រាស់។
- **ប្រតិបត្តិករអាជីវកម្ម(អ្នកលក់រថយន្ត)៖** អ្នកលក់រថយន្តត្រូវទទួលយករថយន្តដែលម្ចាស់រថយន្តបានបោះចោលឈប់ប្រើប្រាស់ ហើយត្រូវផ្តល់វិញ្ញាបនប័ត្រដើម្បីបញ្ជាក់ពីការទទួលយករថយន្តជូនទៅម្ចាស់រថយន្តផងដែរ។
- **ប្រតិបត្តិករស្តារថយន្តឡើងវិញ៖** ប្រតិបត្តិករស្តារថយន្តឡើងវិញត្រូវធ្វើការជួសជុល ឬរៀបចំរថយន្តដែលគេបោះចោលនោះឱ្យមានសភាពដូចដើមឡើងវិញ បន្ទាប់មកត្រូវប្រគល់ទៅឱ្យក្រុមហ៊ុនផលិតរថយន្ត ឬក្រុមហ៊ុននាំចូលរថយន្ត ដើម្បីឱ្យពួកគេយករថយន្តនោះទៅឱ្យប្រតិបត្តិកររុះរើរថយន្តបន្តទៀត។
- **ប្រតិបត្តិកររុះរើរថយន្ត៖** ប្រតិបត្តិកររុះរើរថយន្តត្រូវដកហូតពោងខ្យល់ និងគ្រឿងបន្លាស់ផ្សេងៗទៀតចេញពីរថយន្ត ហើយប្រគល់គ្រឿងបន្លាស់ដែលបានស្តាឡើងវិញជូនទៅក្រុមហ៊ុនផលិតរថយន្ត ឬក្រុមហ៊ុននាំចូលរថយន្ត បន្ទាប់មកយកគ្រឿងបន្លាស់ដែលបានប្រើប្រាស់រួចហើយចេញពីរថយន្ត ហើយប្រគល់រថយន្តដែលត្រូវបានរុះរើនោះទៅឱ្យប្រតិបត្តិករខាងរុះរើម៉ាស៊ីនរថយន្ត។
- **ប្រតិបត្តិកររុះរើម៉ាស៊ីនរថយន្ត៖** ប្រតិបត្តិកររុះរើម៉ាស៊ីនរថយន្ត ត្រូវធ្វើការរុះរើម៉ាស៊ីនរថយន្តដោយប្រើប្រតិបត្តិការដោយម៉ាស៊ីនរុះរើ បន្ទាប់មកត្រូវរៀបចំ និងបែងចែកនូវសំណល់លោហៈធាតុ និងសំណង់រឹងផ្សេងទៀត រួចធ្វើការដឹកជញ្ជូនទៅឱ្យក្រុមហ៊ុនផលិតរថយន្ត ឬក្រុមហ៊ុននាំចូលរថយន្ត។

[29] ជាកន្លែងគ្រប់គ្រងថ្លៃសេវារបស់ម្ចាស់រថយន្តសម្រាប់ធ្វើការកែឆ្នៃរថយន្តដែលបោះចោលគ្រប់ដំណាក់កាលរហូតដល់រថយន្តនោះបានធ្វើការប្រើប្រាស់ឡើងវិញបាន។ ដើម្បីគ្រប់គ្រងរាល់ដំណើរការកែឆ្នៃឡើងវិញឱ្យបានត្រឹមត្រូវ គេមានមជ្ឈមណ្ឌលត្រួតពិនិត្យព័ត៌មានដែលប្រមូលព័ត៌មានអំពីរបៀបដែលរថយន្តដែលត្រូវគេបោះចោលរហូតត្រូវបានកែច្នៃឡើងវិញដោយប្រតិបត្តិករឌីជីថល។

- **ក្រុមហ៊ុនផលិតរថយន្ត/ អ្នកនាំចូល/ ស្ថាប័នកែឆ្នៃកែច្នៃដែលបានកំណត់៖** ក្រុមហ៊ុនផលិតរថយន្ត ឬក្រុមហ៊ុននាំចូលរថយន្ត ត្រូវធ្វើការរៀបចំទុកដាក់នូវគ្រឿងបន្លាស់រថយន្តទាំង ៣ប្រភេទខាងលើយ៉ាងត្រឹមត្រូវ បន្ទាប់មកក្រុមហ៊ុនផលិតរថយន្ត ឬក្រុមហ៊ុននាំចូលរថយន្តធ្វើការទាញយកគ្រឿងបន្លាស់រថយន្តទាំងនោះទៅធ្វើការកែឆ្នៃប្រើប្រាស់ឡើងវិញដើម្បីផលិតជារថយន្តថ្មីមួយផ្សេងទៀត។

**ចំណុច (ឆ)៖ ច្បាប់កែឆ្នៃគ្រឿងប្រើប្រាស់ក្នុងផ្ទះខ្នាតតូច**

ច្បាប់នេះអនុម័តក្នុងឆ្នាំ ២០១២ និងសម្រាប់គ្រប់គ្រងប្រភេទសំណល់រឹងដែលសំដៅទៅលើ៖ ឧបករណ៍អេឡិចត្រូនិច និងឧបករណ៍អគ្គិសនីផ្សេងទៀតដែលត្រូវបានប្រើប្រាស់ដោយអ្នកប្រើប្រាស់ទូទៅក្នុងជីវិតប្រចាំថ្ងៃដូចជាកុំព្យូទ័រ, ទូរស័ព្ទចល័ត, ម៉ាស៊ីនថតឌីជីថល, នាឡិកា និងម៉ាស៊ីនសម្ងួតសក់ជាដើម ដែលអាចប្រមូលនិងដឹកជញ្ជូនបានយ៉ាងមានប្រសិទ្ធិភាព និងជាពិសេសត្រូវការកែច្នៃឡើងវិញ។ ខាងក្រោមនេះគឺជាទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹង៖

- **អ្នកប្រើប្រាស់៖** អ្នកប្រើប្រាស់ត្រូវរៀបចំ និងបែងចែកសំណល់រឹងតាមប្រភេទនីមួយៗសម្រាប់បោះចោល និងប្រគល់សំណល់រឹងទាំងនោះទៅឱ្យរដ្ឋបាលក្រុង ឬអ្នកលក់រាយដើម្បីយកទៅឱ្យប្រតិបត្តិករកែឆ្នៃ។
- **រដ្ឋបាលក្រុង៖** រដ្ឋបាលក្រុង ត្រូវធ្វើការប្រមូលសំណល់រឹងតាមប្រភេទនីមួយៗ និងប្រគល់សំណល់រឹងទាំងនោះទៅឱ្យប្រតិបត្តិករកែឆ្នៃ។
- **ប្រតិបត្តិករកែឆ្នៃ៖** ប្រតិបត្តិករកែឆ្នៃ ត្រូវទទួលយកសំណល់រឹងប្រើប្រាស់ក្នុងផ្ទះខ្នាតតូចទាំងនោះ ព្រមទាំងធ្វើការកែឆ្នៃឡើងវិញ។
- **ប្រតិបត្តិករអាជីវកម្ម៖** ប្រតិបត្តិករអាជីវកម្ម ត្រូវរៀបចំ និងបែងចែកសំណល់រឹងតាមប្រភេទនីមួយៗសម្រាប់បោះចោល និងបង្កើតប្រព័ន្ធប្រតិបត្តិការក្នុងការចោលសំណល់រឹងទាំងនោះដើម្បីជួយដល់ប្រតិបត្តិករកែឆ្នៃ និងអង្គភាពផ្សេងទៀតដែលមានសមត្ថភាពកែឆ្នៃសំណល់រឹងទាំងនោះ។
- **អ្នកលក់រាយ៖** អ្នកលក់រាយត្រូវសហការក្នុងការប្រមូលសំណល់រឹងទាំងនេះដែលបានពីអ្នកប្រើប្រាស់ដោយយកចិត្តទុកដាក់តាមរយៈការចេញវិធានការដូចជា ការតម្លើងធុងសម្រាប់ប្រមូលនៅក្នុងក្រុង។
- **ក្រុមហ៊ុនផលិត៖** ក្រុមហ៊ុនផលិត ត្រូវបង្កើតការរចនាគ្រឿងបន្លាស់ និងសំភារៈថ្មីៗដើម្បីកាត់បន្ថយការចំណាយលើការកែច្នៃឡើងវិញ និងធ្វើការប្រើប្រាស់សំភារៈដែលទទួលបានពីការកែច្នៃឡើងវិញ។

## ផ្នែកទី៣៖ ប្រៀបធៀបរបបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន

យោងតាមការសិក្សាពីស្ថានភាពក្នុងការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និង ជប៉ុន ខាងលើរួចមកយើងអាចពិនិត្យមើលឃើញថាការគ្រប់គ្រងសំណល់រឹងក្នុងប្រទេសកម្ពុជា មិនទាន់មានលក្ខណៈល្អប្រសើរអ្វីនៅឡើយនោះទេ បើធៀបជាមួយនឹងប្រទេសជប៉ុន។ បើធៀបជាមួយស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងនៅជប៉ុនវិញ ចំពោះកម្ពុជាគឺមានកត្តាខ្វះខាតមួយចំនួនដែលបានជះឥទ្ធិពលដល់ការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

ហើយវាក៏ជាកត្តាអវិជ្ជមានផងដែរដែលបង្ករឱ្យមានភាពមិនល្អដល់ជីវិតរស់នៅសព្វថ្ងៃ ក៏ដូចជាបរិស្ថានសង្គមទាំងមូល។ កត្តាទាំងនោះរួមមាន៖

➢ **កត្តាចំណេះដឹងរបស់ប្រជាពលរដ្ឋ៖** ជាក់ស្តែង ពាក់ព័ន្ធនឹងការយល់ដឹងពីការគ្រប់គ្រងសំណល់រឹងរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិតទាបឡើយ ដែលជាហេតុធ្វើឱ្យពួកគេមិនមានការបែងចែកសំណល់រឹងរបស់ពួកគេនៅប្រភព ឬ ឬធ្វើការដុតសំណល់រឹងគ្រប់ប្រភេទរួមបញ្ចូលគ្នា។ ផ្ទុយពីប្រជាជននៅជប៉ុន បញ្ហាសំណល់រឹង គឺជាបញ្ហាចម្បង និងចាំបាច់បំផុតក្នុងជីវភាពរស់នៅរបស់ពួកគេ។ ដូច្នេះហើយរាល់ពេលដែលគេចង់បោះចោលសំណល់រឹង ពួកគេតែងតែងធ្វើការបែងចែកប្រភេទសំណល់រឹងរបស់ពួកគេតាមប្រភេទនីមួយៗជាមុនសិន ជាមួយនឹងការរៀបចំវេចខ្ចប់យ៉ាងត្រឹមត្រូវ និងបោះចោលតាមពេលវេលាច្បាស់លាស់ និងមិនមានការដុតសំណល់រឹងរបស់ពួកគេដោយគ្មានការអនុញ្ញាត ឬមិនមានកន្លែងសម្រាប់ដុតត្រឹមត្រូវនោះឡើយ។

➢ **កត្តាទម្លាប់ និង ឥរិយាបថ៖** ទម្លាប់ និងឥរិយាថរបស់ប្រជាជនកម្ពុជាភាគច្រើន ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កឱ្យមានសំណល់រឹងកើនឡើង និងមិនមានការរៀបចំទុកដាំឱ្យបានត្រឹមផងដែរដូចជា ការចោលសម្រាមតាមទីសាធារណៈ, ការបោះចោលសម្រាមតាមដងផ្លូវ, ការចូលចិត្តប្រើប្រាស់សម្ភារៈនិយម (បានថ្មីចោលចាស់), ការពេញនិយមប្រើប្រាស់របស់របរវេចខ្ចប់ផ្សេងៗដោយមិនចាំបាច់ជាដើម។ល។ ខុសពីប្រជាជនជប៉ុន ពួកគេប្រកាន់ឥរិយាបថយ៉ាងត្រឹមត្រូវក្នុងការគ្រប់គ្រងសំណល់រឹងរបស់ពួកគេ។ ពួកគេចូលចិត្តយករបស់ដែលប្រើប្រាស់ហើយមកប្រើប្រាស់ឡើងវិញ និងតែងតែជំរុញឱ្យមានការកែច្នៃឡើងវិញនូវរបស់របរដែលបានបោះចោល។ មិនតែប៉ុណ្ណោះ ពួកគេមិនធ្វើការបោះចោលសំណល់រឹងរបស់ពួកគេតាមទីសាធារណៈ ឬខុសពីកន្លែងដែលអាជ្ញាធរបានរៀបចំឱ្យនោះទេ ព្រោះពួកគេបានប្រកាន់ភ្ជាប់ឥរិយាបថដ៏សំខាន់មួយថា"ការបោះចោលសំណល់រឹងតាមទីសាធារណៈដោយគ្មានសណ្តាប់ធ្នាប់ គឺជាទង្វើដែលគួរឱ្យអាម៉ាស់បំផុត" ។

➢ **ការប្រមូល និង ដឹកជញ្ជូន៖** បើយើងក្រឡេកមើលទៅលើសេវាប្រមូល និងដឹកជញ្ជូនសំណល់រឹងនៅកម្ពុជា យើងឃើញថា នៅតែជាបញ្ហាមួយដែលមិនទាន់មានការដោះស្រាយអ្វីមួយឱ្យមានលក្ខណៈល្អប្រសើរនៅឡើយ។ ចំពោះពេលវេលាក្នុងការប្រមូល និងដឹកជញ្ជូន បើទោះបីក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់រឹងបានចេញការកាលវិភាគក្នុងការប្រមូលសំណល់រឹងយ៉ាងណាក្តី តែក្នុងការប្រតិបត្តិការជាក់ស្តែងនៅមិនទាន់ធ្វើការប្រមូលតាមកាលវិភាគ និងវេលាត្រឹមត្រូវនោះឡើយ បូករួមទាំងរថយន្តប្រតិបត្តិការប្រមូលសំណល់រឹងនៅមិនទាន់ស្របតាមបច្ចេកទេសខ្ពស់ និងមានភាពចាស់ភាគច្រើន ដែលជាហេតុធ្វើឱ្យសំណល់រឹងជាច្រើនបានទុកចោល និងរ៉ាយប៉ាយពេញដងផ្លូវ និងតាមកន្លែងនានា។ ទន្ទឹមនឹងនោះផងដែរ ចំពោះការប្រមូល និងដឹកជញ្ជូនសំណល់រឹងនេះ នៅមិនទាន់បានប្រតិបត្តិការឱ្យបានពេញលេញគ្រប់តំបន់នានានៅតាមបណ្តាលនៅឡើយ ដែលចំណុចនេះហើយធ្វើឱ្យមានបន្សល់ទុកនូវសំណល់រឹងយ៉ាងច្រើន ជាពិសេសធ្វើឱ្យប្រជាពលរដ្ឋនៅតាម

តំបន់ដែលគ្មានសេវាកម្មប្រមូលសំណល់រឹងធ្វើការដុតសំណល់រឹងទាំងនោះ និងបោះចោលតាមទីសា-ធារណៈនានា។ល។ យ៉ាងណាមិញ បើយើងប្រៀបធៀបជាមួយប្រទេសជប៉ុនចំពោះបញ្ហាប្រមូល និងដឹកជញ្ជូនសំណល់រឹងនេះ គឺប្រទេសជប៉ុនបានប្រតិបត្តិការពេញលេញនិងល្អប្រសើររួចទៅហើយ ទាំងពេលវេលាក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រឹង ទាំងការរៀបចំទីតាំងស្តុកសំណល់រឹងរបស់ប្រជាពលរដ្ឋសម្រាប់ធ្វើការប្រមូល ទាំងយានយន្តប្រមូលផងដែរ មិនតែប៉ុណ្ណោះនៅជប៉ុន គេថែមទាំងបង្កើតឱ្យមានស្ថានីយផ្ទេរសំណល់រឹងថែមទៀត ដើម្បីជាភាពងាយស្រួល និងសម្រួលដល់ការប្រមូលនិងដឹកជញ្ជូនសំណល់រឹងឱ្យកាន់តែរហ័ស និងអនាម័យខ្ពស់។

➢ **លិខិតបទដ្ឋានគតិយុត្តៈ** ចំពោះបញ្ហាលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់រឹងនោះ គឺប្រទេសកម្ពុជានៅមានភាពខ្វះខាតច្រើនបើធៀបជាមួយនឹងប្រទេសជប៉ុន។ ជាក់ស្តែងយើងឃើញថាមានបទដ្ឋានគតិយុត្តតិចតួចណាស់សម្រាប់ការគ្រប់គ្រងសំណល់រឹង ដែលសង្គមកម្ពុជាកំពុងតែយកមកអនុវត្តសព្វថ្ងៃ ម្យ៉ាងវិញទៀតភាគច្រើននៃខ្លឹមសារក្នុងលិខិតបទដ្ឋានទាំងនោះគឺមិនមានការចែងឱ្យមានភាពទូលំទូលាយនោះទេ ពោលគឺក្នុងលិខិតបទដ្ឋានគតិតយុត្តមួយ គឺចែងគ្រប់ប្រភេទសំណល់រឹងទាំងអស់ ដោយមិនមានការញែកប្រភេទកាកសំណល់រឹងតាមប្រភេទនីមួយៗ ឱ្យទៅជាលិខិតបទដ្ឋានគតិយុត្តមួយផ្សេងទៀតនោះទេ។ បញ្ហានេះគឺខុសគ្នាឆ្ងាយពីលិខិតបទដ្ឋានគតិយុត្តនៅជប៉ុន។ ដោយយោងតាមសិក្សារខាងលើ យើងអាចឃើញថា លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងនៅជប៉ុន គឺមានភាពលម្អិតខ្លាំង ដោយមានការបែងចែងនូវប្រភេទសំណល់រឹងផ្សេងៗឱ្យស្ថិតក្នុងច្បាប់ដោយឡែកៗពីគ្នា មិនតែប៉ុណ្ណោះ គ្រប់លិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ប្រទេសសុទ្ធតែមានការចែងពីតួនាទី និងកាតព្វកិច្ចយ៉ាងលម្អិតចំពោះអ្នកពាក់ព័ន្ធទាំងអស់រាប់តាំងពីអ្នកបង្កើតសំណល់រឹង អ្នកប្រើប្រាស់ អ្នកចែកចាយ អ្នកបោះចោល ឬក្រុមហ៊ុនឯកជននានា និងអាជ្ញាធរនានាផងដែរ។ល។

# ជំពូកទី៣

# ឱកាស និង បញ្ហាប្រឈមក្នុងគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

## ផ្នែកទី១៖ ឱកាសក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

ការយល់ដឹងពីកំណើននៃនគររូបនីយកម្ម កំណើនប្រជាជន បរិមាណនៃសំណល់រឹងដែលកើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសគឺការយល់ដឹងពីប្រភេទនៃសំណល់រឹងដែលយើងបានបង្កើត និងវិធីសាស្ត្រក្នុងការគ្រប់គ្រងសំណល់រឹងរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលក្នុងប្រទេសយើង អាចអនុញ្ញាតឱ្យយើងជ្រើសរើសឱកាសដែលសមស្រប ឬផែនការសម្រាប់តម្រូវការក្នុងការគ្រប់គ្រងសំណល់រឹងឱ្យមានភាពល្អប្រសើរនាពេលអនាគត។ ដូចដែលបានសិក្សាខាងលើ គោលបំណងសំខាន់ក្នុងការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ គឺរៀបចំបែងចែកប្រភេទសំណល់រឹង,ការប្រមូលសំណល់រឹងប្រកបដោយអនាម័យ និងការបោះបង់ចោលសំណល់រឹងចុងក្រោយឱ្យបានត្រឹមត្រូវដើម្បីសុខភាពរបស់មនុស្ស សត្វ និងបរិស្ថានទាំងមូល ជាពិសេសគឺការបម្លែងសំណល់រឹងទៅជាថាមពល ឬប្រយោជន៍ផ្សេងៗទៀត។ ដូច្នេះខាងក្រោមនេះ ខ្ញុំនឹងលើកយកឱកាសមួយចំនួនដែលអាចឱ្យប្រទេសកម្ពុជាធ្វើការសិក្សាដើម្បីអនុវត្តឬបង្កើតកម្មវិធីគោលនយោបាយ និងសកម្មភាពនានា ព្រមទាំងពិចារណាលើគម្រោងផ្សេងៗនាពេលអនាគត់ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់រឹងឱ្យបានល្អប្រសើរ។

### កថាខណ្ឌទី១៖ ការញែក ឬបែងចែកសំណល់រឹងនៅប្រភពដើម

ដំណោះស្រាយក្នុងការគ្រប់គ្រងសំណល់រឹងកាន់តែងាយស្រួល នៅពេលណាសំណល់រឹងត្រូវបានញែកឬបែងចែកតាមប្រភេទ និងរក្សាទុកក្នុងថង់ ឬប្រអប់ឱ្យបានត្រឹមត្រូវ។ ក្នុងសហគមន៍ខុសៗគ្នា អាចជ្រើសរើសការញែកសំណល់រឹងរបស់ពួកគេតាមវិធីខុសៗគ្នាបានអាស្រ័យលើដំណោះស្រាយរបស់ពួកគេបង្កើត។ វិធីសា-ស្ត្រមួយចំនួនដែលអាចយកទៅអនុវត្ត ឬគួរគិតពិចារណាមានដូចតទៅ ៖

**១.ការញែកសំណល់រឹងដែលបង្កគ្រោះថ្នាក់ចេញពីសំណល់រឹងដែលមិនបង្កគ្រោះថ្នាក់៖** ទោះបីជានៅតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋមិនមែនជាប្រភពចម្បងដែលបង្កើតឡើងនូវសំណល់រឹងគ្រោះថ្នាក់ក៏ដោយ ក៏ប៉ុន្តែវាក៏មានប្រភេទសំណល់រឹងមួយចំនួន ដូចជា ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យដែលសេសសល់ពីការប្រើប្រាស់ឬផុតកាលកំណត់នៃការប្រើប្រាស់ សំណល់រឹងថ្នាំសម្លាប់សត្វ និងកំប៉ុង ដែលមានដាក់សារធាតុគីមីមួយចំនួនទៀតដែលមានផ្ទុកនូវសារធាតុពុល។ ដូច្នេះសំណល់រឹងទាំងនោះគួរតែញែកចេញឱ្យដាច់ពីគ្នារវាង សំណល់រឹងធម្មតា។ លើសពីនេះទៅទៀតសំណល់រឹងធម្មតាដែលអាចយកទៅប្រើក្នុងគោលបំណងផ្សេងទៀតបាន គួរតែញែកចេញពីសំណល់រឹងដែលត្រូវបោះចោល។ ឧទាហរណ៍៖ ដូចជាថង់ប្លាស្ទិក និងកញ្ចប់មួយចំនួន យើងអាចយកទៅលាងសម្អាតដើម្បីទុកប្រើប្រាស់ ឡើងវិញ ចៀសវាងការទិញស្បោង ឬប្រអប់មកទុកប្រើប្រាស់។

**២.ការញែកសំណល់រឹងសម្រាប់កែច្នៃ៖** គឺជាការញែកសំណល់រឹង ដូចជាក្រដាស កំប៉ុងអាលុយមីញ៉ូម អំបែងដប ឬកែវ និង សារធាតុប្លាស្ទិកចេញពីគ្នា។ រីឯប្រភពបង្កើតសំណល់រឹងដើម្បីយកទៅកែច្នៃ គឺជាមធ្យោបាយល្អ ប្រសើរមួយដើម្បីសន្សំសំចៃវត្ថុធាតុដើម មានន័យថាយើងអាចកាត់បន្ថយការទាញយកធនធានធម្មជាតិយកមកប្រើប្រាស់។ ទន្ទឹមនឹងការញែកសំណល់រឹងទាំងនេះ បញ្ហាដែលយើងត្រូវគិតគូរគឺថា តើយើងត្រូវទុកដាក់វាបែបណា មុនពេលដែលសេវាកម្មនៃការប្រមូលបានមកដល់។ នៅបណ្តាប្រទេសមួយចំនួនដែលមានប្រព័ន្ធកែច្នៃល្អប្រសើររួមផ្សំនឹងមានគោលការណ៍ណែនាំ និងការអប់រំស្តីពីការទុកដាក់ឬបោះចោលសំណល់រឹង(ដូចករណីប្រទេសជប៉ុនដែលយើងបានសិក្សាខាងលើ) ប្រជាពលរដ្ឋបានយកសំណល់រឹងរបស់ពួកគេដែលបានញែករួច ទៅទុកដាក់តាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល ឬអាជ្ញាធរក្នុងតំបន់នីមួយរបស់ពួកគេ។

**៣.ការញែកសំណល់ដែលនៅតាមទីសាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម៖** ការញែកសំណល់រឹងនៅតាម សាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម មានភាពលំបាក និងស្មុគ-ស្មាញជាងតាមលំនៅដ្ឋាន ដោយទីនោះជាកន្លែងដែលមមាញឹក និងមានទំនាក់ទំនងទៅនឹងប្រជាជនទូទៅ។ ដូច្នេះការញែកសំណល់រឹងនេះវាទាក់ទងទៅនឹងឥរិយាបថ ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងស្មារតីចូលរួមក្នុងសកម្មភាពនៃការញែកសំណល់រឹងទាំងនេះ។ ជាក់ស្តែងដូចករណីរបស់ប្រទេសជប៉ុន អាជ្ញាធរមូលដ្ឋានរបស់គេបានប្រើប្រាស់ធុងមួយណាសម្រាប់ដាក់សំណល់រឹងតាមប្រភេទផ្សេងៗគ្នាដូចជា សំណល់រឹងលោហៈធាតុ សំណល់រឹងប្លាស្ទិក សំណល់រឹងក្រដាស សំណល់រឹងអាហារ(ឬសំណល់ដែលអាចបំបែកបានដោយពពួកមីក្រូសារពាង្គកាយ) ។ល។

## កថាខណ្ឌទី២៖ ការអនុវត្តយុទ្ធសាស្ត្រ (៣R) នៅក្នុងសហគមន៍

បើទោះបីជាដំណោះស្រាយនៃការគ្រប់គ្រងសំណល់រឹងជាច្រើនត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលក៏ដោយ តែមានកត្តាជាច្រើនដែលយើងអាចធ្វើបាននៅក្នុងសហគមន៍ដើម្បីគ្រប់គ្រងសំណល់រឹងបានដែរ។ យុទ្ធសាស្ត្រនេះភាគច្រើនត្រូវបានគេស្គាល់ថា យុទ្ធសាស្ត្រ«៣R» (ការកាត់បន្ថយ, ការប្រើប្រាស់ឡើងវិញ និងការកែឆ្នៃឡើងវិញ)។

### ចាក្យខណ្ឌទី១៖ ការកាត់បន្ថយ

ការកាត់បន្ថយ គឺជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសំណល់រឹង។ ប្រសិនបើយើងកាត់បន្ថយបរិមាណសំណល់រឹងនៅក្នុងសហគមន៍ ពេលនោះសំណល់រឹងនឹងមានតិចតួចហើយងាយស្រួលគ្រប់គ្រង។

ឧទាហរណ៍៖ នៅពេលដែលយើងដើរផ្សារ ជាធម្មតាយើងឃើញថាមានការប្រើប្រាស់ថង់ប្លាស្ទិកលើសពី ៥ថង់ ហើយជារឿយៗយើងបានបោះចោលថង់ប្លាស្ទិកទាំងនោះភ្លាមៗនៅពេលដែលយើងទៅដល់ផ្ទះ។ ប្រសិនបើមនុស្សម្នាក់ៗយកថង់ផ្ទាល់ខ្លួនទៅផ្សារ យើងអាចកាត់បន្ថយបរិមាណសំណល់រឹងដែលពិបាក

គ្រប់គ្រងទាំងនេះបាន។ ម្យ៉ាងវិញទៀត ប្រអប់ដាក់ម្ហូបអាហារប្រភេទ ស្ទីរ៉ូហ្វម (Styrofoam) និងកែវ កំប៉ុង ដែលខ្ទប់កាហ្វេក្តៅត្រជាក់ ឬដាក់ភេសជ្ជៈផ្សេងៗគឺមិនអាចយកទៅកែច្នៃឡើងវិញបានទេនៅកម្ពុជា។ ដូច្នេះហើយ សូមយកប្រអប់និងដបទឹកដែលអាចប្រើឡើងវិញដាក់តាមខ្លួនដើម្បីចូលរួមកាត់បន្ថយបរិមាណវត្ថុធាតុដែលពិបាកក្នុងការកែច្នៃឡើងវិញ។

**ឃ្លាខណ្ឌទី២៖ ការប្រើប្រាស់ឡើងវិញ**

សម្ភារៈជាច្រើនដែលយើងប្រើប្រាស់ត្រូវបានបោះចោលក្រោយពីការប្រើប្រាស់បានតែម្តង។ ការប្រើប្រាស់ផលិតផលឡើងវិញមានសារៈសំខាន់ណាស់ បើទោះបីមិនអាចប្រើប្រាស់ផលិតផលក្នុងគោលបំណងដូចដើមបានក៏ដោយ ក៏នៅតែមានវិធីជាច្រើនដែលយើងអាចបង្កើតគុណតម្លៃពីផលិតផលចាស់ៗ។

ឧទាហរណ៍៖ ការធ្វើជីកំប៉ុស ដែលជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការបង្វែរសំណល់រឹងផ្ទះបាយ ឬសំណល់រឹងសរីរាង្គផ្សេងៗឱ្យទៅជាជីដែលអាចប្រើប្រាស់បាន អាចលក់ ឬប្រើសម្រាប់កសិកម្ម និងសួនច្បារដែលធ្វើបានទាំងតាមគ្រួសារ និងក្នុងសហគមន៍។ រីឯសំណល់រឹងផ្សេងទៀតដូចជា សំបកកង់ឡាន សំបកកំប៉ុង សំបកដប អាចធ្វើជាស្បែកជើងសម្រែក ធុង ជើងដាំរុក្ខជាតិ ឧបករណ៍ស្រោចដំណាំ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត។ល។

**ឃ្លាខណ្ឌទី៣៖ ការកែច្នៃឡើងវិញ**

ការកែច្នៃ គឺជាវិធីដ៏សំខាន់មួយក្នុងការកាត់បន្ថយបរិមាណសំណល់រឹង។ ប៉ុន្តែការកែច្នៃត្រូវការការគាំទ្រពីរដ្ឋាភិបាល និងក្រុមហ៊ុនឧស្សាហកម្ម ក៏ដូចជាការប្តេជ្ញាចិត្តពីសំណាក់សហគមន៍ និងប្រជាជន។ ប្រសិនបើគ្មានទីផ្សារសម្រាប់ផលិតផលកែច្នៃ ឬបើផលិតផលនោះត្រូវបានកែច្នៃដោយគ្មានសុវត្ថិភាព នោះការកែច្នៃមិនមែនជាដំណោះស្រាយឡើយ។ ក្នុងការកែច្នៃ គេយកផលិតផលដែលគ្មានប្រយោជន៍រួចប្រែទៅជាវត្ថុធាតុដើមដើម្បីបង្កើតផលិតផលមានប្រយោជន៍ថ្មីៗ

ឧទាហរណ៍៖ កញ្ចក់ ត្រូវបានផលិតចេញពីខ្សាច់ ម៉ែ្សូដា និងក្រួចធ្នា ។ នៅពេលបោះចោល វាអាចសឹកដាច់ ប៉ុន្តែមិនបំបែកទៅជាវត្ថុធាតុដើមវិញទេ។ ដើម្បីកែច្នៃកញ្ចក់ គេបែងចែកវាតាមពណ៌ រួចដុតរំលាយទៅជាទឹក ហើយចាក់ចូលទៅក្នុងពុម្ពផ្សេងៗ។ កញ្ចក់ខ្លះត្រូវបានកែច្នៃទៅជាសម្ភារៈដែលប្រើប្រាស់ក្នុងផ្លូវថ្នល់ ឬសំណង់អាគារ។ ម្យ៉ាងវិញទៀត ផលិតផលអាលុយមីញ៉ូម ក៏ត្រូវបានគេយកទៅកែច្នៃដោយដុតរំលាយ រួចចាក់ក្នុងកំប៉ុង និងវត្ថុថ្មីៗផ្សេងទៀត។

**កថាខណ្ឌទី៣៖ ការបង្កើតស្ថានីយផ្ទេរសំណល់រឹងក្នុងក្រុង**

ស្ថានីយ៍ផ្ទេរសំណល់រឹង គឺជាស្ថានីយ៍មួយដែលមានចម្ងាយមធ្យមរវាងទីតាំងប្រមូល និងទីតាំងចោលសំណល់រឹងចុងក្រោយ។ វាជាចំណុចកណ្តាលដែលរថយន្តដឹកសំណល់រឹងតូចៗធ្វើការផ្ទេរសំណល់រឹងទៅកាន់រថយន្តដឹកទំនិញធំៗតាមរយៈការគៀបសំណល់រឹងចូលក្នុងធុងកុងតឺន័រ សម្រាប់ដឹកទៅកន្លែងបោះចោល

សំណល់រឹងចុងក្រោយ។ ស្ថានីយ៍ផ្ទេរសំណល់រឹងត្រូវបានប្រើសម្រាប់សហគមន៍ដែលមានប្រជាជនច្រើន ហើយដែលសហគមន៍នោះមានផ្លូវតូចចង្អៀត ឬនៅដាច់ស្រយាលពីទីលានចាក់សម្រាម ឬកន្លែងកែច្នៃ។ ស្ថានីយ៍ផ្ទេរអាចជាទីតាំងយុទ្ធសាស្ត្រមួយក្នុងការទទួលយកសំណល់រឹងពីឡានដឹកសម្រាមតូចៗ ហើយអាចជាដំណោះស្រាយសេដ្ឋកិច្ចដែលសមស្រប និងល្អប្រសើរផងដែរ។

នៅក្នុងស្ថានីយផ្ទេរ យើងអាចមានកន្លែងការងារផ្សេងៗទៀតជាច្រើនដូចជា៖ កន្លែងធ្វើការញែកសំណល់រឹងដោយដៃនៅលើឧបករណ៍, ម៉ាស៊ីនផលិតកញ្ចក់ ដែលកញ្ចក់ត្រូវបានកំទេចទៅជាបំណែកតូចៗសម្រាប់ការកែច្នៃឡើងវិញ, ម៉ាស៊ីនបន្សុត់ទឹក ដើម្បីទាញយកសារធាតុរាវចេញពីសំណល់រឹងដូចជា ប្លាស្ទិក លោហៈក្រដាស វាយនភ័ណ្ឌជាដើម។ ម៉ាស៊ីនបន្សុត់ទឹកនេះ នឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការរក្សាទុក និងដឹកជញ្ជូនទៅកន្លែងផ្សេងទៀត ឬក្រុមហ៊ុនកែច្នៃ។ ក្នុងការពិចារណាផ្សេងៗសម្រាប់ការសាងសង់ស្ថានីយផ្ទេរសំណល់រឹង គឺត្រូវគិតពីវិធីសាស្ត្រមួយចំនួនជាមុនសិនដូចជា ការប្រើប្រាស់ថាមពល និងការវិនិយោគដើមទុនដើម្បីរៀបចំការញែកសំណល់រឹងដោយស្វ័យប្រវត្តិ, ការញែកសំណល់រឹងដោយដៃ និងឧបករណ៍បំបែកសមាសធាតុផ្សេងៗ។

ខាងក្រោមនេះគឺជាលក្ខណៈពិសេសនៃស្ថានីយផ្ទេរសំណល់រឹងដែលអាចផ្តល់ឧកាសដល់កម្ពុជាក្នុងការធ្វើការសិក្សាដើម្បីបង្កើត៖

- ជួយឱ្យមានចម្ងាយផ្លូវជិតរវាងទីតាំងប្រមូល និង ទីតាំងចោលសំណល់រឹងចុងក្រោយ
- ជួយឱ្យការប្រមូលមានតម្លៃទាប
- កាត់បន្ថយការប្រើប្រាស់ឥន្ធនៈ និងអាចថែទាំយានយន្តដឹកសំណល់រឹងបានល្អ
- ជាកន្លែងអភិវឌ្ឍ និងស្តារឡើងវិញនូវការកែច្នៃដ៏មានប្រសិទ្ធភាព
- កាត់បន្ថយការបំពុលបរិស្ថានដូចជា ក្លិនអាក្រក់ ទឹកសំអុយ ការភាយឧស្ម័នមេតាន។ល។
- បង្កើនប្រសិទ្ធភាពក្នុងការប្រមូល និង ដឹកជញ្ជូនបានឆាប់រហ័ស និងស្របតាមតម្រូវការ
- ជំរុញដល់ការប្រមូល និងដឹកជញ្ជូនសំណល់រឹងបានគ្រប់ទីកន្លែង ។

### កថាខណ្ឌទី៤៖ ការសាងសង់ទីលានចាក់សម្រាមអនាម័យបន្ថែម

ក្រោយពីបានសិក្សាពីទីលានចាក់សម្រាមនៅកម្ពុជារួចមក យើងឃើញថានៅមានភាពខ្វះខាតខ្លាំងណាស់ចំពោះទីលានចាក់សម្រាមបើធៀបជាមួយនឹងបរិមាណសំណល់រឹង ដែលបានបញ្ចេញចោលជារៀងរាល់ថ្ងៃ។ បើយើងធៀបជាមួយប្រទេសជប៉ុនដែលមានផ្ទៃដីធំជាងកម្ពុជាប្រមាណជា ២ដងប៉ុណ្ណោះ ប៉ុន្តែជប៉ុនមានទីលានចាក់សម្រាមរាប់ពាន់កន្លែងទៅហើយ។ ម្យ៉ាងវិញទៀតស្ទើតែទាំងអស់នៃទីលានចាក់សម្រាមនៅកម្ពុជាជាសុទ្ធតែជាប្រភេទទីលានចាក់សម្រាមមិនសូវមានអនាម័យ ឬគ្មានបច្ចេកទេសត្រឹមត្រូវតាមស្តង់ដាបរិស្ថាន

និងមិនមានការគ្រប់គ្រងទីលានឱ្យបានត្រឹមត្រូវនោះឡើយ។ ភាគច្រើននៃទីលានចាក់សម្រាមនៅកម្ពុជា គឺស្ថិតនៅកន្លែងដែលងាយលិចទឹក ដែលបានធ្វើឱ្យជ្រាបទឹកសំអុយ ចេញពីការពុករលួយនៃសំណល់រឹងហូរចេញពីគំនរសម្រាម និងសំណល់ផ្សេងទៀតជ្រាបចូលទៅក្នុងទឹកក្រោមដី និងហូរចូលស្រែចំការដែលស្ថិតនៅក្បែរនោះ ជាពិសេសគឺប្រជាពលរដ្ឋងាយទទួលរងប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរដោយផ្ទាល់ និងប្រយោលពីសារធាតុពុល និងមេរោគចម្លងនៅរដូវវស្សា។

ដូច្នេះហើយ កម្ពុជាគួរតែធ្វើការសាងសង់ទីលានចាក់សម្រាមអនាម័យបន្ថែមសម្រាប់បណ្ដាលក្រុងស្រុកទូទាំងប្រទេសកម្ពុជា ជាពិសេសគួរតែធ្វើការសាងសង់ទីលានចាក់សម្រាមដែលមានបច្ចេកទេសត្រឹមត្រូវដូចករណីទីលានចាក់សម្រាមនៅជប៉ុនដែលប្រើប្រាស់បច្ចេកទេស semi-aerobic system ជាដើម។

ខាងក្រោមនេះគឺជា លក្ខណៈពិសេសនៃប្រភេទទីលានចាក់សម្រាមដែលប្រើប្រព័ន្ធ semi-aerobic system ធៀបនឹងទីលានចាក់សម្រាមធម្មតា៖

- គុណភាពនៃការបង្ហូរទឹកសំអុយ ឬទឹកមានសារធាតុគីមីល្អប្រសើរជាងទីលានចាក់សំរាមធម្មតា
- ការបំភាយឧស្ម័នផ្ទះកញ្ចក់មានតិចតួចជាងទីលានចាក់សំរាមធម្មតា
- កន្លែងចាក់សំរាមមានស្ថេរភាព និងបម្លែងសម្រាមលឿនជាងទីលានចាក់សំរាមធម្មតា
- ការបំពុលទឹកក្រោមដីមានតិចជាងទីលានចាក់សំរាមធម្មតា
- មានតម្លៃថោកដើម្បីប្រតិបត្តិការនិងគ្រប់គ្រងជាងទីលានចាក់សម្រាមធម្មតា។ល។

ទន្ទឹមនឹងការសាងសង់ទីលានដែលមានបច្ចេកទេសត្រឹមត្រូវហើយ កម្ពុជាគួរតែមានការរៀបចំ និងគ្រប់គ្រងទីលានចាក់សម្រាមនីមួយៗឱ្យបានល្អផងដែរដូចជា៖

- ត្រូវបាំងដោយរបង ជៀសវាងការរសាត់សំណល់រឹងចេញទៅក្រៅ និងការចូលក្នុងទីលានដោយគ្មានការអនុញ្ញាត ហើយនៅផ្នែកខាងក្នុងរបងត្រូវដាំដើមឈើបន្ថែម។
- ត្រូវមានប្រព័ន្ធផ្លូវសម្រាប់ដឹកជញ្ជូនសំណល់រឹងចូលទៅកាន់ទីលានរហូតដល់កន្លែងចាក់សំណល់រឹង ដោយធានានូវគុណភាពសម្រាប់រថយន្តដឹកជញ្ជូនសំណល់គ្រប់ប្រភេទ និងប្រើប្រាស់បានគ្រប់រដូវ។
- ត្រូវសាងសង់ការិយាល័យគ្រប់គ្រងនៅក្បែរផ្លូវចូលទីលាន ហើយត្រូវមានឃ្លាំង មានមធ្យោបាយការពារសុវត្ថិភាព ឧបករណ៍ពន្លត់អគ្គិភ័យ និងមធ្យោបាយត្រួតពិនិតយអង្កេត។
- ត្រូវមានការកត់ត្រានូវទិន្នន័យបរិមាណសំណល់រឹង។
- មិនត្រូវអនុញ្ញាតឱ្យអ្នករើសអេតចាយចូលក្នុងទីលានដោយគ្មានការអនុញ្ញាតជាមុន។
- ត្រូវជៀសវាងក្នុងការដុតសំណល់រឹងមិនត្រឹមត្រូវ។ល។

**កថាខណ្ឌទី៥៖ ការសិក្សាពីគម្រោងក្នុងការបង្កើតរោងចក្រដុតសម្រាម**

រោងចក្រដុតសម្រាម គឺជាវិធីសាស្ត្រមួយក្នុងការកំចាត់ ឬបំផ្លាញសម្រាមដែលពាក់ព័ន្ធដល់ការដុតសារធាតុដើមនៅក្នុងសំណល់រឹង ជាពិសេសវាពាក់ព័ន្ធនឹងការបម្លែងកាកសំណល់រឹងទៅជា ផេះ, ឧស្ម័ន និង កម្តៅ ។ ផេះភាគច្រើនជាសំណល់រឹងអសកម្ម ហើយអាចមានរាងជាដុំតូចៗ ឬជាភាគល្អិតនៅក្នុងឧស្ម័ន។ ចំពោះឧស្ម័ន ត្រូវបានគេសន្មត់ថា ត្រូវបានសម្អាត ឬដកចេញនូវសារធាតុពុលរួចរាលហើយមុនពេលឧស្ម័ននេះបានសាយភាយចេញទៅបរិយាកាស។ រីឯកម្តៅវិញ ត្រូវបានគេបង្កើតទឱ្យក្លាយទៅជាមធ្យបាយមានប្រយោជន៍ផងដែរដូចជា ការផលិតឱ្យក្លាយជាចរន្តអគ្គិសនីជាដើម។

រោងចក្រដុតសម្រាមនេះ អាចកាកបន្ថយបរិមាណកាកសំណល់ដែលបានបោះចោលរហូតដល់៩៥% ទៅ៩៦%។ ការកាត់បន្ថយនេះ ដោយសារតែឡដុតសម្រាមប្រើបច្ចេកទេសមួយដែលគេហៅថា waste-to-energy(មានន័យថា ការបម្លែងកាកសំណល់ទៅជាថាមពល)ដោយគេបានយកកាកសំណល់ដែលបោះចោលនោះទៅបំបែកធាតុ និងផលិតទៅជាប្រយោជន៍ផ្សេងៗវិញ។ បើទោះបី ឡដុតសម្រាមនេះ មិនអាចធ្វើការបំផ្លាញសម្រាមទាំងអស់ដែលគេបានចោលក៏ដោយ ប៉ុន្តែវាក៏បានចូលរួមកាត់បន្ថយកាកសំណល់យ៉ាងច្រើនក្នុងទីលានចាក់សម្រាមដែរ។

ឡដុតសម្រាមនេះ មានប្រយោជន៍ច្រើនណាស់ទាក់ទងនឹងការបំផ្លាញកាកសំណល់វេជ្ជសាស្ត្រ និង សំណល់រឹងប្រកបដោយគ្រោះថ្នាក់។ ខាងក្រោមនេះគឺជាផលប្រយោជន៍មួយចំនួនដែលកើតចេញពី ឡដុតសម្រាម៖

- បន្ថយបរិមាណនៃកាកសំណល់
- ផលិតបានកម្តៅ និងថាមពល
- ការបន្ថយការបំពុលបរិស្ថាន
- ឡដុតមានតម្រងសម្រាប់ដក់យកសារធាតុបំពុល
- សន្សំលើការដឹកជញ្ជូនកាកសំណល់
- ផ្តល់នូវការគ្រប់គ្រងបានប្រសើរជាង ដោយមិនមានក្លិននិងសំលេងរំខាន
- កំចាត់មេរោគ និងសារធាតុគីមីដែលមានគ្រោះថ្នាក់
- ឡដុតសម្រាមអាចធ្វើប្រតិបត្តិការនៅក្នុងអាកាសធាតុបែបណាក៏បាន
- មានប្រសិទ្ធិភាពក្នុងការកែច្នៃសារធាតុដែក
- ប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រសម្រាប់ត្រួតពិនិត្យ
- អាចយកផេះទៅប្រើប្រាស់បាន។

## កថាខណ្ឌទី៦៖ ការពង្រឹងប្រព័ន្ធច្បាប់ និងគោលនយោបាយនានារបស់ស្ថាប័នពាក់ព័ន្ធ

ប្រព័ន្ធច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាល គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការរៀបចំបង្កើតឱ្យមានប្រព័ន្ធនៃការគ្រប់គ្រងសំណល់រឹងដ៏មានប្រសិទ្ធភាពមួយ។ ជាក់ស្តែង ប្រព័ន្ធច្បាប់ និងគោលនយោបាយក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជាហាក់មានភាពទន់ខ្សោយនិងមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ។ ដូច្នេះហើយ ដើម្បីរៀបចំឱ្យមានប្រព័ន្ធនៃការគ្រប់គ្រងសំណល់រឹងមួយនៅកម្ពុជា រដ្ឋាភិបាល ឬក្រសួងពាក់ព័ន្ធនានាគួរតែមានផែនការសកម្មភាព ឬបង្កើតឱ្យមានច្បាប់គ្រប់គ្រងសំណល់រឹងឱ្យកាន់តែច្រើន និងរឹងបន្តឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាំងនោះឱ្យមានប្រសិទ្ធភាពទូទាំងប្រទេស។ ខាងក្រោមនេះ គឺជាអន្តរាគមន៍មួយចំនួនដែលអាចកែលម្អគុណភាពនៃការគ្រប់គ្រងសំណល់រឹង៖

- ធ្វើយុទ្ធនាការបង្កើនការយល់ដឹងដល់សហគមន៍ ឧទាហរណ៍ដូចជា៖ កម្មវិធីផ្សព្វផ្សាយ អប់រំនានាសម្រាប់យុវជន និងប្រជាពលរដ្ឋទូទៅពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង ដែលវាអាចជាជំហានដំបូងក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងសំណល់រឹងឱ្យបានល្អប្រសើរនៅកម្ពុជា។
- ការពង្រឹងការអនុវត្តច្បាប់ឱ្យបានល្អប្រសើរជាងមុន
- ការត្រួតពិនិត្យលើការនាំចូលផលិតផលចាស់ៗ និងលើកស្ទួយការប្រើប្រាស់ផលិតផលដែលមានគុណភាពល្អ និងផលិតផលដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃឡើងវិញ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ចោលនូវការប្រើប្រាស់សំណល់រឹងពុល ឬគ្រោះថ្នាក់ដែលកើតចេញពីឧស្សាហកម្មទាំងឡាយ។
- ការធ្វើអត្តសញ្ញាណ និងការត្រួតពិនិត្យទីលានចាក់សម្រាម
- ជម្រុញការធ្វើអភិបាលកិច្ចល្អ និងការដឹកនាំនៅថ្នាក់មូលដ្ឋានដើម្បីកែលម្អសម្របសម្រួលវិមជ្ឈការនៅថ្នាក់មូលដ្ឋាន
- រដ្ឋាភិបាលគួរដាក់ឱ្យអនុវត្ត និងលើកទឹកចិត្តឱ្យប្រើប្រាស់ធុងសម្រាមសម្រាប់បែងចែកសំណល់រឹងនូវប្រភេទខុសៗគ្នាដើម្បីធានាឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព
- រដ្ឋាភិបាលគួរតែពិនិត្យមើលជម្រើសនៃការបម្លែងសំណល់ឱ្យទៅជាថាមពល និងជម្រើសនៃការដុតសំណល់រឹង
- ផ្តល់នូវគ្រឿងលើកទឹកចិត្តមួយចំនួនដើម្បីទាក់ទាញក្រុមហ៊ុនវិនិយោគទន់ផ្សេងៗដែលធ្វើការវិនិយោគទន់រោងចក្រកែច្នៃឧបករណ៍ឡើងវិញ។
- បង្កើតច្បាប់ ឬបទបញ្ញត្តិឱ្យកាន់តែច្រើន និងមានភាពលម្អិតក្នុងការគ្រប់គ្រងសំណល់រឹងតាមប្រភេទសំណល់រឹងនីមួយៗ

- បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិ ៣R សម្រាប់ការគ្រប់គ្រងសំរាមនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ដោយផ្អែកលើច្បាប់បរិស្ថានដែលមានស្រាប់ និងលក្ខន្តិកៈពាក់ព័ន្ធ
- រៀបចំកម្មវិធីពង្រឹងសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាល និង ផ្សព្វផ្សាយចំណេះដឹង និងអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិ ៣R ទាំងផ្នែកសាធារណៈ និងឯកជន

ដើម្បីសម្រេចនូវការគ្រប់គ្រងសំណល់រឹងខាងលើដោយនិរន្តរភាព ក្រសួងបរិស្ថានគួរបន្តធ្វើការយ៉ាងជិតស្និតជាមួយ៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងផែនការ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងកិច្ចការនារី
- ក្រសួងទេសចរណ៍
- និងរដ្ឋបាលមូលដ្ឋាននានាទូទាំងប្រទេស។ល។

## ផ្នែកទី២៖ បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

បញ្ហាសម្រាម សំណល់រឹងទីប្រជុំជន បានក្លាយជាបញ្ហាចម្បងក្នុងចំណោមបញ្ហានានាដទៃទៀត(ក្នុងនោះរួមមាន៖ គ្រោះថ្នាក់ចរាចរណ៍,សន្តិសុខសង្គម និងការគ្រប់គ្រងសំណង់ជាដើម) ហើយជាប្រធានបទក្នុងការជជែកពិភាក្សាប្រចាំថ្ងៃក្នុងចំណោមសាធារណៈជនលើសារព័ត៌មាន,បណ្តាញសង្គមនិងកិច្ចពិភាក្សាគោលនយោបាយនានាហើយបញ្ហាគ្រប់គ្រងសំណល់រឹងនេះទៀតសោតបានបង្កជាបញ្ហាប្រឈមមួយទៅដល់សង្គមកម្ពុជា ព្រោះថាសំណល់រឹងបានធ្វើឱ្យប៉ះពាល់ទៅដល់បរិស្ថានក្រុង និងសុខាមាលភាពប្រជាពលរដ្ឋផងដែរ ។

### កថាខណ្ឌទី១ ៖ កត្តាប្រជាជន

របូតមកដល់ពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជានៅមានចំណេះដឹងតិចតួចនៅឡើយអំពីបញ្ហាក្នុងការគ្រប់គ្រងសំណល់រឹងរបស់ពួកគេ ។

តាមការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា បញ្ហាប្រឈមមួយចំនួនដែលប្រជាពលរដ្ឋមិនទាន់មានការយល់ដឹងក្នុងការគ្រប់គ្រងសំណល់រឹងរបស់ពួកគេមានដូចជា៖

- ប្រជាពលរដ្ឋតាមគ្រួសារនីមួយៗទូទាំងប្រទេស នៅមិនទាន់ឃើញមានការអនុវត្តឱ្យបានត្រឹមត្រូវនៅឡើយចំពោះការញែក ឬបែងចែកប្រភេទសំណល់រឹងរបស់ពួកគេ ពោលសំណល់រឹងគ្រប់ប្រភេទត្រូវបានវេចខ្ចប់ក្នុងថង់ប្លាស្ទិកមួយដើម្បីយកទៅបោះចោល

- ប្រជាពលរដ្ឋដែលមិនមានសេវាប្រមូលសម្រាម គឺពួកគេមានការនិយមក្នុងការដុតសំណល់រឹងរបស់ពួកគេជាលក្ខណៈតាមគ្រួសារ ឬសហគមន៍ ដែលការដុតសំណល់រឹងទាំងនោះពុំមានបច្ចេកទេសត្រឹមត្រូវ និងដុតគ្រប់ប្រភេទសំណល់រឹងទាំងអស់បញ្ចូលគ្នា ដែលនាំឱ្យមានការបំពុលបរិស្ថាន និងសុខភាពរបស់មនុស្ស

- ប្រជាពលរដ្ឋដែលស្ថិតក្នុងតំបន់ដែលមានសេវាប្រមូលសម្រាម យើងឃើញថាការទុកដាក់សំណល់រឹងរបស់ពួកគេ ភាគច្រើនគឺគ្មានសណ្តាប់ធ្នាប់ និងគ្មានអនាម័យឡើយ។ មានន័យថាសំណល់រឹងដែលពួកគេវេចខ្ចប់ក្នុងថង់ត្រូវបានយកទៅទុកនៅខាងមុខផ្ទះ (មាន ឬគ្មានធុងសម្រាម) និងបញ្ចេញសំណល់របស់ពួកគ្រប់ពេលវេលាទាំងអស់ ដែលចំណុចនេះធ្វើឱ្យសំណល់របស់ពួកគេអាចត្រូវបានសត្វកកាយ ឬ រប៉ាចរប៉ាយ ជាពិសេសបង្កឱ្យមានក្លិនមិនល្អដល់បរិស្ថានជុំវិញ

- ការចោលសំណល់រឹងតាមទីសាធារណៈ វានៅតែជាទម្លាប់មិនល្អរបស់ប្រជាពលរដ្ឋមួយចំនួន បើទោះបីមានធុងសម្រាមនៅទីតាំងរបស់ពួកគេបោះចោលក៏ដោយ ពិសេសនៅទីតាំងដែលមានការប្រមូលផ្តុំមនុស្ស តាមសួនច្បារ ទីផ្សារ រម្មណីយដ្ឋាន តាមភោជនីយដ្ឋាន និងតាមទីតាំងអាជីវកម្មផ្សេងៗ។ល។

- ប្រជាពលរដ្ឋកម្ពុជាភាគច្រើនមានអាកប្បកិរិយា ទិញបោះចោលៗ បានថ្មីចោលចាស់ សំបូរបែបជ្រុលពេក ឧទាហរណ៍ដូចជា ការនិយមប្រើប្រាស់នូវផលិតផលវេចខ្ចប់ជា ថង់ប្លាស្ទិក ប្រអប់ កែវជ័រ(កែវដាក់កាហ្វេ ឬភេសជ្ជៈ) ក៏ដូចជាផលិតផលអេឡិចត្រូនិចផងដែរ ដែលក្រោយពីប្រើប្រាស់ផលិតផលទាំងនោះបានម្តង ពួកគេក៏បោះចោល ណាមួយបូកបន្ថែមជាមួយនឹងគោលនយោបាយរបស់ក្រុមហ៊ុនផលិតសម្ភារៈអេឡិចត្រូនិច ដែលធ្វើយ៉ាងណាឲ្យផលិតផលរបស់ពួកគេមានអាយុប្រើប្រាស់កាន់តែខ្លី ដើម្បីជម្រុញឱ្យមនុស្សទិញផលិតផលថ្មីប្រើរហូត។ ដូចនេះកត្តានេះបានធ្វើបរិមាណនៃសំណល់រឹងដែលពិបាកកែច្នៃមានការកើនឡើងខ្លាំងស្របពេលដែលប្រទេសកម្ពុជាមិនទាន់មានប្រព័ន្ធកែច្នៃប្រភេទសំណល់រឹងទាំង

- ប្រជាពលរដ្ឋ និងក្រុមអាជីវករមានកិច្ចសហការ និងការចូលរួមទាប និងតិចតួច ក្នុងការអនុវត្តទៅលើបទបញ្ញា និងសេចក្តីណែនាំនានា ព្រមទាំងការវិភាគប្រមូលសំណល់រឹងផងដែរ ។

**កថាខណ្ឌទី២៖ ការប្រមូល និងដឹកជញ្ជូនសំណល់រឹង**

បើនិយាយដល់សេវាប្រមូល និងដឹកជញ្ជូនសំណល់រឹងនៅកម្ពុជា គឺគេមើលឃើញភ្លាមថា មិនមានភាពទំលំទូលាយឡើយនៅមូលដ្ឋានទូទាំងប្រទេស ពោលគឺមានតែទីតាំង ឬតំបន់ទីប្រជុំជន ឬក្រុងតែប៉ុណ្ណោះ។ ហេតុដូចនេះហើយ ប្រជាពលរដ្ឋភាគច្រើនពុំបានទទួលបាននូវសេវាប្រមូល និងដឹកជញ្ជូនសំណល់រឹងនោះឡើយ ដែលជាហេតុធ្វើឱ្យពួកគេបោះចោលសំណល់រឹងតាមទីសាធារណៈនៅក្បែតំបន់រស់នៅរបស់ខ្លួន ចោលសំណល់រឹងតាមដងផ្លូវ តាមសួនច្បារសាធារណៈ ជិតទីផ្សារ តាមដងទន្លេ ឬក្នុងទន្លេ តាមគំនរសំណល់រឹងនានាដោយពុំបានដាក់ក្នុងធុងសម្រាមត្រឹមត្រូវ ជាពិសេសពួកគេធ្វើការដុតសំណល់រឹងទាំងនោះដោយខុសច្បាប់ជាដើម។

ងាកមកតំបន់ ឬក្រុងដែលមានសេវាប្រមូល និងដឹកជញ្ជូនសំណល់រឹងវិញ បញ្ហាប្រឈមសំខាន់ៗមួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹងរួមមាន៖

- សេវាប្រមូល និងដឹកជញ្ជូនសំណល់រឹងមិនបានគ្របដណ្តប់គ្រប់សង្កាត់ និងគ្រប់ដងផ្លូវក្នុងក្រុងឡើយ
- ពុំបានប្រមូលគ្រប់ប្រភេទសំណល់រឹងទាំងអស់ ហើយប្រមូលក៏ពុំបានស្អាត
- ពុំមានការកំណត់ពេលវេលាប្រមូលឱ្យបានច្បាស់លាស់ និងប្រមូលមានភាពយឺតយ៉ាវ
- មធ្យោបាយដឹកជញ្ជូនសំណល់រឹងពុំមានសភាពល្អ (រថយន្តចាស់ , ខូច . លេចធ្លាយទឹកសំអុយ និងសម្រាមតាមដងផ្លូវ)
- ពុំមានការរៀបចំទីតាំងស្តុកទុកសំណល់រឹងក្នុងសហគមន៍ឱ្យបានត្រឹមត្រូវ និងអនាម័យ ពោលគឺ ពុំមានរបង ឬសំណាញ់ព័ទ្ធ ហើយទីតាំងទាំងនោះភាគច្រើនមាននៅតាមទីតាំងសាធារណៈតាមដងផ្លូវ ដែលធ្វើឱ្យមានក្លិនមិនល្អ និងទឹកសំអុយជុំវិញតំបន់នោះ
- ភាគច្រើនប្រមូលតែពេលថ្ងៃ រីឯពេលយប់ពុំសូវមានការប្រមូលឡើយ (ស្របពេលដែលប្រជាពលរដ្ឋបញ្ចេញសំណល់របស់ពួកគេគ្រប់ពេលទាំងពេលថ្ងៃ និង យប់)
- អត្រាឈប់ពីការងាររបស់កម្មករប្រមូល និងដឹកជញ្ជូនសំណល់រឹងមានកម្រិតខ្ពស់ ដោយសារតែពុំមានសេវាធានារ៉ាប់រងសុខភាព និងមិនសូវមានការលើកទឹកចិត្ត និងផ្តល់តម្លៃដល់ពួកគេ។

**កថាខណ្ឌទី៣៖ ការគ្រប់គ្រងសំណល់រឹងតាមបែបមជ្ឈការ**

ទោះបីជាមានការអនុវត្តកំណែទម្រង់វិមជ្ឈការ ត្រូវបានលើកកម្ពស់អស់រយៈពេលជាច្រើនឆ្នាំក្តី ក៏កម្ពុជានៅតែមានបញ្ហាប្រឈមមួយចំនួនក្នុងការលើកកម្ពស់គំនិតផ្តួចផ្តើមពីមូលដ្ឋាន ព្រមទាំងលើកកម្ពស់វិធានការការងារក្នុងការដោះស្រាយបញ្ហានានានៅមូលដ្ឋាន។ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងរដ្ឋបាលក្រុង ស្រុកនៅតែយល់ថា រដ្ឋបាលខេត្តគឺជាអ្នកទទួលខុសត្រូវលើបញ្ហានេះ ហើយបានលើកឡើងថា មន្ទីរសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុខេត្ត ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាអ្នកទទួលខុសត្រូវក្នុងការកំណត់កម្រៃអតិបរមា ហើយក្រសួងបរិស្ថានជាអ្នកដាក់ចេញនូវលិខិតបទដ្ឋានមួយចំនួន នៅមិនទាន់ច្បាស់លាស់ទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង។ រីឯក្រុមហ៊ុនប្រមូលសំណល់រឹង ពុំបានឬមានកិច្ចសហការតិចតួចជាមួយអាជ្ញាធរមូលដ្ឋាន (ដោយសាររបៀបគ្រប់គ្រងចាត់ចែងបែបមជ្ឈការ គឺអ្វីៗទាំងអស់ជាការសម្រេចរបស់ថ្នាក់លើនៅការិយាល័យកណ្ដាលនៅឯភ្នំពេញ)។ ក្រៅពីនេះ មានការចូលរួមតិចតួចពីសំណាក់ប្រជាពលរដ្ឋ ដោយសារតែពួកគេយល់ថាអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានជាអ្នកយល់ដឹង និងចាត់ចែងការងារនេះ។

ដោយសារតែផ្នត់គំនិតថ្នាក់លើជាធំ និងការស្ដាប់បង្គាប់នេះហើយ ទើបរដ្ឋបាលក្រុង ស្រុកស្ទាក់ស្ទើរក្នុងការផ្ដួចផ្ដើម និងបង្ហាញពីភាពសកម្ម ឬទទួលយកការទទួលខុសត្រូវនានារបស់ខ្លួន និងធ្វើតាមអ្វីដែលថ្នាក់លើប្រាប់ប៉ុណ្ណោះមុននឹងអនុវត្តភារកិច្ចអ្វីមួយ។ បញ្ហាទាំងនេះ ស្ដែងចេញពីភាពមិនច្បាស់លាស់នៃតួនាទី និងការទទួលខុសត្រូវនៃអង្គភាពផ្សេងៗរបស់រដ្ឋាភិបាល ដែលនាំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ចាំតែទទួលយកគោលការណ៍ណែនាំ និងនីតិវិធីទាំងឡាយមុននឹងបំពេញភារកិច្ចរបស់ខ្លួន។ ម្យ៉ាងវិញទៀត នីតិវិធីនានារបស់ថ្នាក់ជាតិ អាចរារាំងដល់គំនិតផ្ដួចផ្ដើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសយកសិទ្ធិអភិវឌ្ឍន៍មូលដ្ឋានដ៏សមស្របតាមតម្រូវការនៅមូលដ្ឋានទាំងបញ្ហាមធ្យោបាយ សេដ្ឋកិច្ច និង ឱកាសនានាផងដែរ។

## កថាខណ្ឌទី៤៖ លិខិតបទដ្ឋានគតិយុត្តមិនគ្រប់គ្រាន់ និងការអនុវត្តនៅមានកម្រិតទាប

យើងបានសិក្សារួចមកហើយ អំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា យើងឃើញថា នៅមានភាពខ្វះច្រើនបើធៀបទៅនឹងតម្រូវកាក្នុងពេលបច្ចុប្បន្ននេះ។ ជាក់ស្ដែងមានលិខិតបទដ្ឋានគតិយុត្ត៣ ទៅ៤ ប៉ុណ្ណោះដែលកម្ពុជាកំពុងយកមកអនុវត្តសម្រាប់គ្រប់គ្រងសំណល់រឹងទូទាំងប្រទេស។ មិនតែប៉ុណ្ណោះលិខិតបទដ្ឋានគតិយុត្តទាំងនោះ គឺមានភាពទូលំទូលាយ និងមិនមានចែងលម្អិតអំពីនីតិវិធី ឬគោលការណ៍ណែនាំនានាក្នុងការគ្រប់គ្រងសំណល់រឹងតាមមធ្យោបាយផ្សេងៗនោះឡើយ ឧទាហរណ៍ដូចជា៖ មិនមានគោលការណ៍ណែនាំក្នុងការវេចខ្ចប់ ឬរៀបចំទុកដាក់សំណល់រឹង, មិនមាននីតិវិធីណែនាំក្នុងការបោះចោល ឬបំផ្លាញសំណល់រឹងតាមប្រភេទផ្សេងៗ, មិនមានគោលការណ៍ណែនាំក្នុងការការប្រមូល និងដឹកជញ្ជូនសំណល់រឹងតាមប្រភេទនីមួយៗ និងគោលនយោបាយក្នុងការអនុវត្តយុទ្ធសាស្ត្រ ៣R មិនទាន់ឃើញមានការអនុម័តដើម្បីឱ្យអនុវត្តពេញលេញនៅឡើយ។ល។

ទន្ទឹមនឹងការខ្វះខាតនៃលិខិតបទដ្ឋានគតិយុត្តហើយនោះ ចំពោះយន្តការក្នុងការពង្រឹងការអនុវត្តលិខិតបទដ្ឋានក៏នៅពុំទាន់មានប្រសិទ្ធភាពផងដែរ។ ជាទូទៅ ការអនុវត្តខុសនីតិវិធី ឬខុសពីសេចក្ដីណែនាំនានា គឺជារឿងធម្មតាទៅហើយសម្រាប់ស្ថានភាពក្នុងប្រទេសកម្ពុជាដូចជា ករណីគ្រោះថ្នាក់ចរាចរណ៍ និងអវត្តមានពីការងារជាដើម។ ប្រជាពលរដ្ឋទូទៅ រួមទាំងមន្ត្រីរាជការ សុទ្ធតែបានទទួលស្គាល់ការពិតនៃបែបបទនៃការរស់នៅ

របៀបនេះ។ ចំពោះករណីគ្រប់គ្រងសំណល់រឹង ការយកកម្រៃលើសពីចំនួនកំណត់ ការមិនបង់ប្រាក់កម្រៃ ការគេចវេសពីការផាកពិន័យដោយសារមិនចង់គោរពតាមគោលការណ៍ច្បាប់ និងប្រព័ន្ធត្រួតពិនិត្យនានា ឬចរចាឱ្យផាកពិន័យតិចតួច ឬមិនមានការផាកពិន័យតាមច្បាប់កំណត់ ព្រមទាំងការយល់ដឹងអំពីនីតិវិធី និងបទបញ្ញាទាំងឡាយនៅមានកម្រិត សុទ្ធសឹងតែជាបញ្ហាបន្តចោទមានយ៉ាងច្រើន។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាពីរបបនៃការគ្រប់គ្រងសំណល់រឹងរវាងកម្ពុជា និងជប៉ុនរួមមក យើងឃើញថាការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា នៅតែមានភាពអន់ខ្សោយដោយសារតែកត្តាមួយចំនួនដូចជា ចំណេះដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងនៅមានកម្រិត មានថវិកាតិចតួចសម្រាប់យកមករៀបចំធ្វើគម្រោង ខ្វះខាតឧបករណ៍គ្រប់គ្រងប្រភេទដែលគេត្រូវការចាំបាច់សម្រាប់ដឹកជញ្ជូន ប្រមូល និងស្តុកទុកសំណល់រឹង រីឯច្បាប់មិនទាន់មានភាពទូលំទូលាយ និងគំនាប់សង្កត់នៅមិនទាន់មានប្រសិទ្ធភាព ហើយមិនមានគម្រោងគ្រប់គ្រងឱ្យបានច្បាស់លាស់។ រីឯប្រទេសជប៉ុន ប្រជាពលរដ្ឋរបស់គេមានការយល់ដឹងខ្ពស់ទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងនេះ មិនតែប៉ុណ្ណោះគេប្រើប្រាស់បច្ចេកទំនើបៗសម្រាប់ការគ្រប់គ្រងសំណល់រឹងរបស់គេ(ឧទាហរណ៍៖ រោងចក្របម្លែងសំណល់រឹងទៅជាថាមពលជាដើម) ព្រមទាំងមានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងច្រើន និងទូលំទូលាយ ហើយការអនុវត្តច្បាប់មានប្រសិទ្ធភាពខ្ពស់។

ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា បើទោះបីមិនមានការសិក្សាជាក់លាក់ណាមួយទៅលើផលប៉ះពាល់នៃការចោលសំណល់រឹងនៅទីសាធារណៈ ការដុតសំណល់រឹង ការមិនបែងចែកប្រភេទនៃសំណល់រឹង ការបោះចោលសំណល់រឹងនៅទីលានចាក់សម្រាមក៏ដោយ ក៏ជាទូទៅគេសង្កេតឃើញថា កាអនុវត្តនៃការគ្រប់គ្រងសំណល់រឹងបែបនេះទំនងជាមានផលប៉ះពាល់អវិជ្ជមានច្រើនទៅលើបរិស្ថាន និងសុខភាពរបស់មនុស្ស។ រីប្រទេសជប៉ុន ចំពោះផលប៉ះពាល់ដែលបណ្តាលមកពីសំណល់រឹង គឺមានកម្រិតតិចតួចប៉ុណ្ណោះ ដោយសារតែប្រជាពលរដ្ឋរបស់គេមានការគ្រប់គ្រងសំណល់រឹងរបស់ពួកគេបានត្រឹមត្រូវល្អ ដូចជា៖ ការបែងចែកប្រភេទសំណល់រឹងនៅប្រភពដើម, ការវេចខ្ចប់ និងទុកដាក់ត្រឹមត្រូវតាមពេលវេលា និងទីកន្លែងកំណត់។ល។ មិនតែប៉ុណ្ណោះ ប្រព័ន្ធនៃការគ្រប់គ្រងសំណល់រឹងរបស់អាជ្ញាធរជប៉ុនមានភាពលម្អិត និងមានប្រព័ន្ធអប់រំ និងផ្សព្វផ្សាយទូលំទូលាយ មានការចូលរួមយុទ្ធសាស្ត្រ ៣R ទូទាំងប្រទេស ជាពិសេសមានការប្រើប្រាស់ឧបករណ៍ទំនើបៗ និងប្រកបដោយបច្ចេកទេសត្រឹមត្រូវនិងអាចទាញផលប្រយោជន៍មកវិញបានច្រើនពីសំណល់រឹងទាំងនោះ។

បើពាក់ព័ន្ធនឹងគោលនយោបាយ និងកម្មវិធីនានាចំពោះការគ្រប់គ្រងសំណល់រឹង នៅប្រទេសកម្ពុជាបានរៀបចំនូវបទបញ្ញត្តិ គោលនយោបាយ និងកម្មវិធីមួយចំនួនសម្រាប់ការគ្រប់គ្រងសំណល់រឹង ប៉ុន្តែការអនុវត្តហាក់បីដូចជានៅមានកម្រិតនៅឡើយ។ រីឯប្រទេសជប៉ុនវិញ យើងអាចនិយាយបានថា គេមានប្រព័ន្ធច្បាប់ក្នុងការគ្រប់គ្រងសំណល់រឹងដែលមានភាពល្អប្រសើរ និងរឹងមាំយូរឆ្នាំមកហើយ។ ភាគច្រើននៃប្រព័ន្ធច្បាប់របស់ជប៉ុន គេផ្តោតទៅលើការចែងអំពីតួនាទី និងកាតព្វកិច្ចរបស់អ្នកពាក់ព័ន្ធទាំងអស់ និងមានការញែកដាច់

ដោយឡែកពីគ្នានូវប្រភេទនៃសំណល់រឹង ដោយក្នុងគោលបំណង់ធ្វើយ៉ាងណាឱ្យមានការកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ នៃប្រភេទសំណល់រឹងដែលពួកគេបានបង្កើតឡើង។

# អនុសាសន៍

ដោយផ្អែកលើការសិក្សាទាំងករណីកម្ពុជា និង ជប៉ុនខាងលើរួចមក ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួន ដើម្បីជាយោបល់មួយក្នុងការជួយពង្រឹងនូវការគ្រប់គ្រងសំណល់រឹងនៅក្នុងប្រទេសកម្ពុជា ឱ្យកាន់តែមានភាពល្អប្រសើរ។ ប្រទេសកម្ពុជាគួរតែពិនិត្យមើលបទពិសោធន៍នានាដែលមានក្នុងប្រទេសជប៉ុន ហើយយកមកអនុវត្តនូវបច្ចេកទេស និងកម្មវិធីផ្សេងៗដែលមានលក្ខណៈសមស្របបំផុត ហើយអាចយកមកអនុវត្តឱ្យសមស្របទៅនឹងបរិបទកម្ពុជា។ ឧទាហរណ៍៖ កម្មវិធីផ្សព្វផ្សាយ អប់រំនានាសម្រាប់យុវជន និងប្រជាពលរដ្ឋ ទូទៅពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងសំណលរឹង ជាពិសេសយុទ្ធសាស្ត្រ ៣R ដែលវាអាចសកម្មភាពមួយក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងសំណល់រឹងឱ្យបានល្អសម្រាប់ប្រទេសកម្ពុជា។ លើសពីនេះទៀត ប្រទេសកម្ពុជាក៏អាចរៀនសូត្រពីប្រទេសជប៉ុនផងដែរចំពោះរបៀបនៃការកសាងស្ថានីយផ្ទេរសំណល់រឹង, ការរចនាទីលានចាក់សម្រាម និងរោងចក្រដុតសម្រាមដែលមានលក្ខណៈអនាម័យជាដើម។ បើកាលដែលកម្ពុជាអាចធ្វើបានដូច្នេះ ផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីសំណល់រឹងដូចជា ភាពកខ្វក់, ភាពអណាធិបតេយ្យនៃសំណល់រឹង, សារធាតុពុលដែលកើតចេញពីសំណល់រឹង និងបញ្ហាអវិជ្ជមានជាច្រើនទៀតទៅលើបរិស្ថាន សុខភាពមនុស្ស និងការរំខានដល់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋដែលកើតចេញពីសំណល់រឹងនឹងត្រូវបានកាត់បន្ថយ។

# ឯកសារយោង

1) អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពី ការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩។
2) អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។
3) របាយការណ៍គោលនយោបាយ IGES-2011-06 «មគ្គុទេសក៍សម្រាប់ជាជំនួយស្មារតីក្នុងការធ្វើ សេចក្តីសម្រេចជ្រើសរើស និងអនុវត្តន៍គម្រោងទាញយកផលប្រយោជន៍ពីសំណល់សរីរាង្គនៅកម្ពុជា»។
4) ឯកសារស្រាវជ្រាវ «បញ្ហាប្រឈមនៃការគ្រប់គ្រងសម្រាមនៅកម្ពុជា និងបទពិសោធន៍នៃការគ្រប់គ្រងសម្រាមនៅប្រទេសផ្សេងៗ» រក្សាសិទ្ធិដោយៈ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ខែឧសភា ឆ្នាំ២០១៥។
5) របាយការណ៍លទ្ធផលនៃការអង្កេតស្តីពី«ការអនុវត្តការគ្រប់គ្រងសម្រាម និងសំណល់រឹងនៅ រដ្ឋបាលក្រុងស្រុក» និពន្ធដោយៈ លោក មិន មុនី ទីប្រឹក្សាឯករាជ្យ , រៀបរៀងដោយៈ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
6) គោលការណ៍ណែនាំបរិស្ថានស្តីពី «ការគ្រប់គ្រងសំណល់រឹងនៃព្រះរាជាណាចក្រកម្ពុជា» រៀបចំដោយៈ ក្រសួងបរិស្ថាន និងអង្គការកែឆ្នៃសម្រាមនិងការសិក្សានៅកម្ពុជា (COMPED) ។
7) របាយការអំពីការពិនិត្យមើលលើការគ្រប់គ្រងកាកសំណល់នៅតាមដងផ្លូវស្តីពី «អភិបាលកិច្ចទីក្រុងៈ ការគ្រប់គ្រងកាកសំណល់នៅក្នុងរាជធានីភ្នំពេញ» បោះពុម្ពផ្សាយដោយៈ សមាគមន៍ធាងត្នោត ខែមករា ឆ្នាំ២០១៩។
8) សៀវភៅណែនាំស្តីអំពី ការគ្រប់គ្រងកាកសំណល់សម្រាប់សហគមន៍ក្រីក្រនៅក្នុងទីក្រុង , បោះពុម្ពផ្សាយដោយៈ សមាគមន៍ធាងត្នោត ។
9) អត្ថបទ «ការគ្រប់គ្រង និងការប្រមូលសំណល់រឹង ៖ ទីតាំងលំនៅឋានមួយចំនួននៅក្នុងរាជធានីភ្នំពេញដែលត្រូវបានបំភ្លេចចោល» បោះពុម្ពផ្សាយដោយៈ សមាគមន៍ធាងត្នោត ខែកក្កដា ឆ្នាំ២០១៥។

# ឯកសារយោង អ៊ីនធឺណែត


1) http://mekonginfo.org/assets/midocs/0002192-environment-solid-waste-managementtraining-material.pdf
2) https://www.researchgate.net/publication/326293569_State_of_Waste_Management_in_Phnom_Penh_Cambodia
3) https://www.iges.or.jp/en/publication_documents/pub/policysubmission/en/6688/Phnom+Penh+Waste+management+strategy+and+action+plan+2018-2035_web.pdf
4) http://asiafoundation.org/wp-content/uploads/2016/06/Working-Politically-and-Flexibly-to-Reform-Solid-Waste-Management-in-Phnom-Penh.pdf
5) https://www.comped-cam.org/documents.php
6) https://urbanvoicecambodia.net/waste-management-in-phnom-penh/
7) http://www.xinhuanet.com/english/2019-07/08/c_138209510.htm
8) https://seylanote.wordpress.com/2012/07/12/
9) https://www.tandfonline.com/doi/abs/10.1080/00022470.1986.10466189
10) https://www.conserve-energy-future.com/advantages-and-disadvantages-incineration.php
11) http://www.kleanindustries.com/s/environmental_market_industry_news.asp?ReportID=341815
12) https://www.sciencedirect.com/topics/earth-and-planetary-sciences/waste-transport
13) https://www.slideshare.net/akashtk/solid-waste-management-process

# ឧបសម្ព័ន្ធទី១

# អនុក្រឹត្យលេខ៣៦

# អនុក្រ.បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩

# ស្តីពីការគ្រប់គ្រងសំណល់រឹង។

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

722
10-5-99

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៣៦ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

៚៙៚

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ២ ខែមេសា ឆ្នាំ១៩៩៩ ។

# សម្រេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១** អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុកប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- " **សំណល់រឹង** " គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ- " **សំរាម** " គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ- " **សំណល់ប្រកបដោយគ្រោះថ្នាក់** " គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈនិងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

មាត្រា ៤ ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

មាត្រា ៥ ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

មាត្រា ៦ ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

មាត្រា ៧ ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា ៨ ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ៩ ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

មាត្រា ១០ ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ១១ ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

មាត្រា ១២ ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី ការកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

មាត្រា ១៣ ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព ។

មាត្រា ១៤ ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក- ប្រភេទ និងបរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

មាត្រា ១៥ ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភពឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

មាត្រា ១៦ ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សង្កាត់ មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាននិងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា ១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

មាត្រា ១៧ ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ១៨ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក- ប្រភេទ និងបរិមាណសំណល់

ខ- ប្រភពដើមរបស់សំណល់

គ- ការដឹកជញ្ជូន និងមធ្យោបាយវេចខ្ចប់

ឃ- ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

មាត្រា ១៩ ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ២០ ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពី ការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ១៩៩២ ។

មាត្រា ២១ ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ៤

## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច

## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ២២ ការត្រួតពិនិត្យលើការបញ្ចេញ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ២៣ ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ២៣ នេះ ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

មាត្រា ២៤ ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជូនបរិស្ថាន ។

មាត្រា ២៥ ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនិតិវិធី ដែលមានចែងខាងក្រោម :

ក - បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ - ត្រូវធ្វើនៅទីងកន្លែង នូវកំណត់ហេតុនិងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ - ត្រូវសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវព័ត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ - ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

មាត្រា ២៦ ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៏មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសបញ្ញត្តិ

មាត្រា ២៧ ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ ស្តីពី *កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ* ។

មាត្រា ២៨ មន្ត្រីឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិន គោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។ .

**មាត្រា ២៩** កំណត់ហេតុនិងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

**មាត្រា ៣០** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣២** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣១
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក ម៉ារ៉េត

## ឧបសម្ព័ន្ធ

### ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១ - សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ ( ក្នុងករណីយកទៅដុត )

២ - សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស

៣ - សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និងទឹកល្អ

៤ - សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម

៥ - សំណល់ចាស្ទិច "ប៉ូលីវីនិលក្លរ"

៦ - សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតបីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល។

៧ - សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៉ុយទីលីន

៨ - សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩ - សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០- សំណល់ដែលមានផ្ទុកជាតិបាស

១១- សំណល់លោហៈ និងសមាសធាតុរបស់វា រួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២- លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣- សំណល់អំពូលអគ្គិសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤- សំណល់អាគុយ និងថ្មពិល

១៥- សំណល់ថ្នាំលាបនិងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦- សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧- សំណល់គ្រឿងផ្ទុះ

១៨- សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩- សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០- សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១- ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់ ។

២២- សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣- សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤- សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥- សំណល់ដែលជាសមាសធាតុសរីរាង្គក្លុយអរីន

២៦- សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧- សំណល់ដែលជាសមាសធាតុអាសបេស្តូស

២៨- សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$ )

២៩- សំណល់ដែលជាសមាសធាតុអេទែ ( R-COO-$R_1$ )

៣០- សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១- សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២- សំណល់ធាតុវិទ្យុសកម្ម

៣៣- សារធាតុ ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែង ពីចំនុចទី ១ ដល់ទី ៣២

# ឧបសម្ព័ន្ធទី២

# អនុក្រឹត្យលេខ១១៣

# អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

# ស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.១១៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

# សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យដាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាលដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋានទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្គាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ )ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញតិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្តិ៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស្តុកសំណល់** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើលទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

# ឧបសម្ព័ន្ធទី៣
# ប្រភព និង ប្រភេទសំណល់រឹងផ្សេងៗ
# ដែលបានបង្កើតក្នុងប្រទេសកម្ពុជា

## តារាងបែងចែកប្រភេទសំណល់រឹង

| ល.រ | ប្រភព និង ប្រភេទសំណល់រឹង |
|---|---|
| ១. | **សំណល់តាមផ្ទះ** |
| | • សំណល់ផ្ទះបាយដែលកើតឡើងតាមរយៈសកម្មភាពដាំស្ល<br>• សំណល់ប្លាស្ទិកក្រោយពេលដែលគេឈប់ប្រើប្រាស់សម្រាប់វេចខ្ចប់*<br>• សំណល់ក្រណាត់ដែលកើតឡើងតាមរយៈសកម្មភាពកាត់ដេរបន្តិចបន្តួច ឬកន្ទបសម្រាប់ជូតចានឆ្នាំង ឬជូតផ្ទះជាដើម<br>• សំណល់សម្លៀកបំពាក់ចាស់ៗដែលគេឈប់ប្រើប្រាស់<br>• សំណល់លោហៈ*<br>• សំណល់កែវ មានដប កែវបែក កញ្ចក់ជាដើម<br>• សំណល់ក្រដាសដែលកើតចេញពីការវេចខ្ចប់ កាសែតអាន ។ល។<br>• សំណល់ក្រដាសកាតុង<br>• សំណល់ឈើមិនមានថ្នាំលាបដូចជា គ្រឿងសង្ហារិមដែលបាក់បែកដែលគេឈប់ប្រើប្រាស់<br>• សំណល់ឈើមានថ្នាំលាប*<br>• សំណល់ស្បែកដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរដែលឈប់ប្រើប្រាស់ ។ល។<br>• សំណល់កៅស៊ូដូចជា កៅស៊ូកង កៅស៊ូកង់យានយន្ត និងសំណល់ផ្សេងៗទៀតដែលធ្វើអំពីកៅស៊ូ ។ល។<br>• សំណល់ថ្មពិល*<br>• សំណល់អាគុយ*<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់គ្រឿងអេឡិចត្រូនិច*<br>• សំណល់បៃតងដូចជា ផ្លែឈើ ស្មៅ មែកឈើ ស្លឹកឈើ ។ល។<br>• សំណល់ព័រសឺឡែន មានចាន ប៉ាន់ ពែងដែលបែកបាក់ជាដើម<br>• សំណល់ថ្នាំពេទ្យ* ដែលឈប់ប្រើប្រាស់សម្រាប់គ្រួសារ<br>• សំណល់ភក់ចេញពីអាងស្តុក (អាងសាបទិក)<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ២. | **សំណល់នៅតាមផ្សារ** |
| | • សំណល់ប្លាស្ទិក*<br>• សំណល់លោហៈ*<br>• សំណល់កែវដូចជា ដប កែវបែក កញ្ចក់<br>• សំណល់ក្រដាស<br>• សំណល់កាតុង |

| | |
|---|---|
| | • សំណល់ស្បែកដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរដែលឈប់ប្រើប្រាស់ ។ល។<br>• សំណល់កៅស៊ូ<br>• សំណល់ថ្មពិល*<br>• សំណល់អាគុយ*<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់គ្រឿងអេឡិចត្រូនិច*<br>• សំណល់បៃតង<br>• សំណល់ព័រសីឡែន<br>• សំណល់សាច់ និងឆ្អឹងដែលសល់ពីសកម្មភាពលក់ដូរ<br>• សំណល់ភក់ចេញពីបង្គន់<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ៣. | **សំណល់រឹងតាមភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ កន្លែងលំហែកាយ និងកន្លែងគោរពបូជា** |
| | • រាល់សំណល់ផ្ទះបាយដែលកើតចេញពីសកម្មភាពដាំស្ល<br>• សំណល់ស្រដៀងសំណល់ផ្ទះបាយ<br>• សំណល់បៃតង<br>• សំណល់ប្លាស្ទិក*<br>• សំណល់លោហៈ<br>• សំណល់កែវដូចជា ដបកែវ កែវបែក កញ្ចក់បែកបាក់ជាដើម<br>• សំណល់ក្រដាស ក្រដាសជូតមាត់ ស្រោមចង្កឹះជាដើម<br>• សំណល់ក្រណាត់ដូចជា កំរាលតុ ក្រណាត់ជូតដៃជាដើម<br>• សំណល់កាតុង<br>• សំណល់ផេះ<br>• សំណល់កៅស៊ូ<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់គ្រឿងអេឡិចត្រូនិក*<br>• សំណល់ព័រសីឡែនដូចជា ចាន ប៉ាន់ ពែងបែកបាក់ជាដើម<br>• សំណល់ភក់ចេញពីបង្គន់<br>• សំណល់ឈើដូចជា តុ ទូ កៅអីដែលមិនមានលាបថ្នាំ<br>• សំណល់ឈើដូចជា តុ ទូ កៅអីដែលមានលាបថ្នាំ*<br>• សំណល់ថ្មពិល*<br>• សំណល់អាគុយ*<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ និងសំណល់ដែលចេញពីតាមផ្ទះ |

| ៤. | សំណល់រឹងតាមរយៈសេវាសុខភាពដូចជា តាមមន្ទីរពេទ្យ ពហុព្យាបាល មណ្ឌលសុខភាព |
|---|---|
| | • សំណល់ស្រដៀងសំណល់ផ្ទះបាយដែលសល់ពីការហូបចុករបស់អ្នកជម្ងឺ<br>• សំណល់មុតស្រួច* ដូចជាម្ជុល ឡាមជាដើម<br>• សំណល់ឆ្លងរោគ*<br>• សំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម*<br>• សំណល់ថ្នាំពេទ្យ*<br>• សំណល់មន្ទីរពេទ្យផ្សេងៗទៀត* |
| ៥. | សំណល់រឹងនៅតាមអាគាររដ្ឋបាល និងសាលារៀន |
| | • សំណល់ស្រដៀងនឹងសំណល់ផ្ទះបាយដែលសល់ពីការហូបចុក<br>• សំណល់ប្លាស្ទិក*<br>• សំណល់កៅស៊ូ<br>• សំណល់ក្រដាស<br>• សំណល់កាតុង<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់គ្រឿងអេឡិចត្រូនិក*<br>• សំណល់ឈើដូចជា តុ ទូ កៅអីដែលមិនមានលាបថ្នាំ<br>• សំណល់ឈើដូចជា តុ ទូ កៅអីដែលមានលាបថ្នាំ*<br>• សំណល់លោហៈ*<br>• សំណល់កែវ<br>• សំណល់ព័រសឺឡែន<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ និងសំណល់ដែលចេញពីតាមផ្ទះ |
| ៦. | សំណល់រឹងនៅកន្លែងសេវាកម្មលាង ឬជួសជុលរថយន្ត និងជួសជុលគ្រឿងអេឡិចត្រូនិច |
| | • សំណល់លោហៈ*<br>• សំណល់កៅស៊ូដូចជា សំបកកង់យានយន្តចាស់ៗជាដើម<br>• សំណល់ប្លាស្ទិក*<br>• សំណល់ថ្នាំបាញ់*<br>• សំណល់អាគុយ*<br>• សំណក់កញ្ចក់ដូចជា កញ្ចក់យានយន្ត ។ល។<br>• សំណល់គ្រឿងអេឡិចត្រូនិក*<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់ភក់តាមរយៈសកម្មភាពលាងយានយន្ត |

| | |
|---|---|
| | • សំណល់ក្រណាត់ដែលប្រើប្រាស់សម្រាប់ជូត<br>• សំណល់ក្រណាត់ដែលប្រើប្រាស់សម្រាប់ជូតមានប្រលាក់ប្រេងម៉ាស៊ីន*<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ៧. | **សំណល់រឹងដែលកើតចេញពីកន្លែងសត្តឃាដ** |
| | • សំណល់លាមកសត្វក្រោយការសម្លាប់<br>• សំណល់រោមសត្វក្រោយការសម្លាប់<br>• សំណល់ឆ្អឹង និងសាច់ដែលគេមិនត្រូវការ<br>• សំណល់ភក់តាមរយៈសកម្មភាពសម្អាត<br>• សំណល់លោហៈ*<br>• សំណល់ផេះ<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ៨. | **សំណល់រឹងដែលកើតចេញពីសកម្មភាពកសិកម្ម** |
| | • សំណល់ឈើដូចជា អាចម៍រណា មែកឈើតូចៗជាដើម<br>• សំណល់លាមកសត្វ (កន្លែងចិញ្ចឹមសត្វ)<br>• សំណល់សាកសពសត្វ<br>• សំណល់វេជ្ជសាស្ត្រ* ចេញពីសកម្មភាពព្យាបាលសត្វ<br>• សំណល់ប្លាស្ទិក*<br>• សំណល់បៃតង<br>• សំណល់ចំណីសត្វ<br>• សំណល់ភក់ដែលកើតចេញពីសកម្មភាពដុសលាងសត្វ និងក្រោល<br>• សំណល់លោហៈ* ដែលចេញពីផ្នែកនៃម៉ាស៊ីនកសិកម្ម<br>• សំណល់សំបកដប ឬកំប៉ុងដែលមានជាប់ជាតិថ្នាំពុលកសិកម្ម*<br>• សំណល់កៅស៊ូ<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ៩. | **សំណល់រឹងឧស្សាហកម្ម និងរ៉ែ** |
| | • សំណល់ក្រណាត់<br>• សំណល់ស្បែកនៅតាមរោងចក្រកាត់ដេរស្បែកជើង<br>• សំណល់ប្លាស្ទិកសម្រាប់វេចខ្ចប់វត្ថុធាតុដើម*<br>• សំណល់ក្រដាសនៅក្នុងការិយាល័យ កន្លែងបោះពុម្ព កន្លែងកាត់ពុម្ពខោអាវ |

| | |
|---|---|
| | • សំណល់កាតុងតាមរយៈការវេចខ្ចប់<br>• សំណល់លោហៈ* គ្រឿងបន្លាស់ម៉ាស៊ីន<br>• សំណល់ភក់តាមរយៈការធ្វើប្រព្រឹត្តកម្មទឹកសំអុយ*<br>• សំណល់ធុង ឬកំប៉ុងដែលដាក់សារធាតុគីមី*<br>• សំណល់ថ្នាំជ្រលក់ តាមយៈសកម្មភាពជ្រលក់ពណ៌ក្រណាត់*<br>• សំណល់ជ័រកាវ*<br>• សំណល់ប្លាស្ទិករឹង*<br>• សំណល់គ្រឿងអេឡិចត្រូនិក*<br>• សំណល់គ្រឿងអគ្គិសនី*<br>• សំណល់កែវ នៅតាមរោងចក្រផលិតភេសជ្ជៈ ឬសិប្បកម្មផលិតទឹកត្រី ទឹកស៊ីអីវ<br>• សំណល់បាយស្រា<br>• សំណល់ស្រដៀងសំណល់ផ្ទះបាយ<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ១០. | **សំណល់រឹងសំណង់** |
| | • សំណល់ប្លាស្ទិក*<br>• សំណល់ឈើ<br>• សំណល់ឈើមានថ្នាំលាប*<br>• សំណល់កំទេចថ្មគ្រប់ប្រភេទ<br>• សំណល់ដែលជីកចោល<br>• សំណល់កាតុងចេញពីការវេចខ្ចប់<br>• សំណល់លោហៈ*<br>• សំណល់ព័រសឺឡែន<br>• សំណល់ថ្នាំលាប*<br>• សំណល់ស៊ីម៉ង់*<br>• សំណល់កំបោរ*<br>• សំណល់ជ័រកាវ*<br>• សំណល់កែវ<br>• សំណល់គ្រឿងអេឡិចត្រូនិក*<br>• សំណល់ប្លាស្ទិករឹង*<br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |

| ១១. | **សំណល់រឹងចេញពីមន្ទីរពិសោធន៍** |
| --- | --- |
| | • សំណល់កែវ* <br>• សំណល់សារធាតុគីមី* <br>• សំណល់សំណាក* <br>• សំណល់លោហៈ* <br>• សំណល់គ្រឿងអេឡិចត្រូនិក* <br>• សំណល់គ្រឿងអគ្គិសនី* <br>• សំណល់កៅស៊ូ* <br>• សំណល់ខោអាវ ក្រណាត់* <br>• សំណល់ដែលមានសារធាតុវិទ្យុសកម្ម* <br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ១២. | **សំណល់រឹងនៅតាមថ្នល់ និងសួនច្បារ** |
| | • សំណល់ប្លាស្ទិក* <br>• សំណល់ក្រដាស <br>• សំណល់កាតុង <br>• សំណល់លោហៈ* <br>• សំណល់ឈើ <br>• សំណល់បែតុង <br>• សំណល់ដី ថ្ម <br>• សំណល់កែវ <br>• សំណល់សាកសពសត្វ <br>• សំណល់លាមកសត្វ <br>• សំណល់ផ្សេងៗទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |

**សម្គាល់** សំណល់ដែលមានសញ្ញាផ្កាយ ( * ) ជាសំណល់ប្រកបដោយគ្រោះថ្នាក់។